រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា
និងអធិការកិច្ច

# របាយការណ៍បូកសរុប
# ការងារ ឆ្នាំ២០២០
# និងទិសដៅឆ្នាំ២០២១









2021

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទំនាក់ទំនងជាមួយ
រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

# របាយការណ៍

## បូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១

## របស់

## ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ឆ្នាំ ២០២១

# មាតិកា


**ក-សេចក្តីផ្តើម** ........ 1

**ខ-សមិទ្ធផលការងារ** ........ 2

១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ ........ 2

១-១-ការងាររដ្ឋបាល ........ 2

១.២.ការងារបុគ្គលិក និងធនធានមនុស្ស ........ 3

១.៣.ការងារបណ្តុះបណ្តាល ........ 4

១.៤.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ........ 4

១.៥.ការងារផែនការ និងស្ថិតិ ........ 5

១.៦.ការងារសហប្រតិបត្តិការអន្តរជាតិ ........ 6

២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 8

២.១.ការងារនីតិកម្ម ........ 8

២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់ ........ 8

២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល ........ 9

២.៤.ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 9

៣.សកម្មភាពការងារអធិការកិច្ច ........ 9

៣.១.ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច ........ 9

៣.២.ការងារអធិការកិច្ចលើវិស័យរដ្ឋបាលទូទៅ ........ 10

៣.៣.ការងារអធិការកិច្ចលើវិស័យសង្គមកិច្ច ........ 11

៣.៤.ការងារតាមដានការអនុវត្តច្បាប់ ........ 11

៣.៥.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ........ 13

៣.៦.លទ្ធផលការងារអធិការកិច្ច ........ 14

៤-សកម្មភាពការងារសវនកម្មផ្ទៃក្នុង ........ 25

៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច ........ 26

៦.ការងារផ្សេងៗ ........ 27

៦.១.សកម្មភាពការងារយេនឌ័រ ........ 27

៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព ........ 27

៦.៣. សមាគមសង្គហមិត្តភាព ........ 28

៦.៤.សកម្មភាពក្រុមការងាររៀតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ........ 28

៦.៥.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង ........ 29

៦.៦.សកម្មភាពការងារអ្នកនាំពាក្យក្រសួង ........ 29

៦.៧.សកម្មភាពការងារគេហទំព័រ www.monasri.gov.kh និង MONASRI App ........ 30

**គ-បញ្ហាប្រឈម** ........ 32
**ឃ.ទិសដៅការងារឆ្នាំ ២០២១** ........ 33
១. រដ្ឋបាលកិច្ចការទូទៅ ........ 33
១-១-ការងាររដ្ឋបាល ........ 33
១-២-ការងារបុគ្គលិក និងធនធានមនុស្ស ........ 33
១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ........ 33
១-៤-ការងារផែនការ និងស្ថិតិ ........ 34
១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ ........ 35
២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា ........ 35
២-១-ការងារនីតិកម្ម ........ 35
២-២-ការងារអប់រំផ្សព្វផ្សាយច្បាប់ ........ 35
២-៣-ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ........ 35
៣.ការងារអធិការកិច្ច ........ 36
៣.១.ការងារអធិការកិច្ច(វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច) ........ 36
៣.២.ការងារតាមដានការអនុវត្តច្បាប់ ........ 36
៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ........ 36
៤.ការងារសវនកម្មផ្ទៃក្នុង ........ 36
៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច ........ 36
៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ ........ 36
៥.២. ការងារផែនការ និងស្រាវជ្រាវ ........ 37
៥.៣. ការងារបណ្តុះបណ្តាល ........ 37
៥.៤. ការងារទំនាក់ទំនងសាធារណៈ ........ 37
៦.ការងារផ្សេងៗ ........ 38
៦.១.ការងារយេនឌ័រ ........ 38
៦.២.ការងារចងសម្ព័ន្ធមេត្រីភាព ........ 38
៦.៣.ការងារសមាគមសង្គហមិត្តភាព ........ 38
៦.៤.ការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ........ 38
៦.៥.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង ........ 39
៦.៦.ការងារអ្នកនាំពាក្យក្រសួង ........ 39
៦.៧.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App ........ 39
**ង-សេចក្តីសន្និដ្ឋាន** ........ 40
**ឧបសម្ព័ន្ធ ១. កម្មវិធីសន្និបាត** ........ 42
**ឧបសម្ព័ន្ធ ២. របាយការណ៍សង្ខេប** ........ 44
**ឧបសម្ព័ន្ធ ៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាតសង្ខេប** ........ 58

ឧបសម្ព័ន្ធ ៤. សុន្ទរកថាបើកសន្និបាត ........................................................................... 60
ឧបសម្ព័ន្ធ ៥. សុន្ទរកថាបិទសន្និបាត ............................................................................. 66

# ក-សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ភ្លឺស្វាង និងចក្ខុវិស័យដ៏វែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានទទួលសេចក្តីសុខ សន្តិភាព កិត្យានុភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។ កម្ពុជាដែលធ្លាប់ជាសមរភូមិ នៃការប្រទាញប្រទង់ពីសំណាក់មហាអំណាច និងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ ជាវាលពិឃាតនៃរបបប្រល័យពូជសាសន៍ បានប្រែក្លាយទៅជាទីផ្សារវិនិយោគដ៏ទាក់ទាញជារម្មណីយដ្ឋាន និងទីផ្សារទេសចរណ៍ដ៏ល្បីល្បាញលំដាប់ពិភពលោក និងជាប្រទេសមួយមានមោទនភាពជាតិស្មើមុខស្មើមាត់ជាមួយប្រទេសដទៃលើពិភពលោក។

ដើម្បីសម្រេចបានគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន រាជរដ្ឋាភិបាលកម្ពុជា បានប្រកាន់យករបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបសេដ្ឋកិច្ចបែបទីផ្សារសេរី និងបើកចំហ ដោយធ្វើការងារកំណែទម្រង់ស៊ីជម្រៅ និងដាក់ចេញយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងតំបន់ និងពិភពលោក។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាល បានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការងារចំបង គឺការទំនាក់ទំនង សម្របសម្រួលរវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែង សេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ចលើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ឆ្នាំ២០២០ ជាឆ្នាំដែលមានការប្រឈមច្រើនសម្រាប់ក្រសួង ដោយសារសភាពការណ៍ទាំងក្នុងប្រទេស និងក្រៅប្រទេសមានការប្រែប្រួល ដោយសារឥទ្ធិពលនៃការរាលដាលនៃគ្រោះមហន្តរាយនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាត និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាសកល នាំឱ្យមានឧបសគ្គដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរ នៃការធ្វើដំណើរ សេវាកម្ម ពាណិជ្ជកម្ម និងការវិនិយោគ និងជះឥទ្ធិពលអវិជ្ជមានទៅលើគ្រប់វិស័យ នៃសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយឡែក វិបត្តិជំងឺកូវីដ-១៩ក៏បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់ប្រតិបត្តិការការងាររបស់ក្រសួងយើងផងដែរ ជាពិសេសបេសកកម្មទាំងក្នុង និងក្រៅប្រទេស លទ្ធកម្ម និងការបណ្តុះបណ្តាល ដោយសាររាជរដ្ឋាភិបាលបានកាត់បន្ថយការចំណាយលើមុខសញ្ញាជាច្រើន ចាប់ពីដើមឆ្នាំ ២០២០មក ក្នុងគោលបំណងត្រៀមទប់ទល់ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។

របាយការណ៍នេះកើតចេញពីលទ្ធផលនៃសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងដែលបានប្រារព្ធធ្វើថ្ងៃទីថ្ងៃអង្គារ៍ ៥រោច ខែមាឃ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹង ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ នៅភោជនីយដ្ឋានទន្លេបាសាក់២ (លេខ ៥៣៤ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ)។

# ខ-សមិទ្ធផលការងារ

## ១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-ទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន៩០៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៨៩៤ច្បាប់។

-ថតចម្លងរាល់លិខិតចេញ-ចូលក្នុងក្រសួងតម្កល់ទុកជាឯកសារ។

-រៀបចំតាំងបដាពាក្យស្លោក ទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ នៅទីស្តីការក្រសួង។

-រៀបចំ និងបញ្ជូនសារលិខិតថ្វាយព្រះពរព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថសីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល និងធ្វើសារលិខិតជូនពរថ្នាក់ដឹកនាំកំពូលរបស់ជាតិ ក្នុងពិធីបុណ្យជាតិ-អន្តរជាតិ និងខួបកំណើត។

-រៀបចំពិធីទទួលជួបសវនាការការងារ រវាងថ្នាក់ដឹកនាំក្រសួង ជាមួយលោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំង ឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក លោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋគូបា និងឯកឧត្តមអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួង។

-រៀបចំប្រជុំតាមកម្មវិធីប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង នៅទីស្តីការក្រសួង។

-រៀបចំធ្វើសេចក្តីជូនដំណឹងពីថ្ងៃឈប់សម្រាក ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ តាមប្រតិទិនឈប់សម្រាកពីការងារ របស់រាជរដ្ឋាភិបាល។

-រៀបចំលិខិតបង្គាប់ការចាត់មន្ត្រីរាជការចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-រៀបចំបូកសរុបរបាយការណ៍របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំសម្រាប់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ។

-គ្រប់គ្រង ពិនិត្យតាមដានជាប្រចាំនូវការសរសេរ និងរូបថត សរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង។

-ត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

-តាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-រៀបចំជំនួបពិភាក្សាការងារលើការគ្រប់គ្រងបណ្ណសារ រវាងលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ណសារជាមួយនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋាននីតិកម្ម នៅទីស្តីការក្រសួង។

-អនុវត្ត ផ្សព្វផ្សាយសេចក្តីជូនដំណឹង សេចក្តីណែនាំ និងបទដ្ឋានគតិយុតនានា តាមការណែនាំរបស់លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រីជូនថ្នាក់ដឹកនាំគ្រប់អគ្គនាយកដើម្បីជ្រាប និងអនុវត្ត។

-ចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ សន្និបាតបូកសរុបលទ្ធផលការងារ ពិធីមីទ្ទីញ សិក្ខាសាលា គោរពវិញ្ញាណក្ខន្ធ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-រៀបចំប្រជុំស្តីពីវឌ្ឍនភាពការងាររបស់នាយកដ្ឋានរដ្ឋបាល នៅសាលប្រជុំទីស្តីការក្រសួង។

-ចូលរួមប្រជុំស្តីពីការត្រៀមលក្ខណៈរៀបចំពិធីបុណ្យជាតិ-អន្តរជាតិ ព្រះរាជពិធីប្រទានសញ្ញាបត្រសម្តេចប៉ុស្តិ៍សុខភាព និងការត្រៀមលក្ខណៈទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេស មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា នៅគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិចំនួន១១លើក។

## ១.២.ការងារបុគ្គលិក និងធនធានមនុស្ស

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ប្រចាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការតាំងស៊ប់បំពេញសិទ្ធិ នៅក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការដំឡើងថ្នាក់ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ២០២១ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២១។

-ទទួលប្រកាសរបស់ក្រសួងមុខងារសាធារណៈស្តីពីការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២៩៣រូប ប្រចាំឆ្នាំ២០២០។

-ធ្វើប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការចំនួន៩រូប ជាជំនួយការរដ្ឋលេខាធិការចំនួន៥រូប ប្រធានមន្ទីរចំនួន២រូប ប្រធានការិយាល័យចំនួន១រូប និងអនុប្រធានការិយាល័យចំនួន១រូប។

-ធ្វើប្រកាសស្តីពីការចាត់តាំងមន្ត្រីរាជការចំនួន៦រូប និងដាក់ឱ្យធ្វើកម្មសិក្សាសាកល្បងក្នុងក្របខ័ណ្ឌរយៈពេល១២ខែ។

-ធ្វើប្រកាសស្តីពីការទទួលក្របខ័ណ្ឌមន្ត្រីរាជការចំនួន៤រូប ពីក្រសួងមុខងារសាធារណៈចំនួន១រូប ក្រសួងផែនការចំនួន១រូប ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន១រូប និងក្រសួងមហាផ្ទៃចំនួន១រូប ឱ្យមកបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការចំនួន៤រូប ពីក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យទៅបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួន៣រូប និងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្មចំនួន១រូប។

-ធ្វើប្រកាសស្តីពីការលុបឈ្មោះមន្ត្រីរាជការចំនួន២រូប ពីក្របខ័ណ្ឌក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដោយទទួលមរណភាព និងលាឈប់ពីការងារ។

-ធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា បម្រើការងារនៅមន្ទីររាជធានី-ខេត្ត ឆ្នាំ២០២០។

-ធ្វើសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការវាយតម្លៃគ្រឿងឥស្សរិយយសក្រសួង។

-ធ្វើប្រកាសស្តីពីការប្តូរឈ្មោះមន្ត្រីជាប់កិច្ចសន្យាចំនួន២រូប។

-ធ្វើប្រកាសស្តីពីការដាក់មន្ត្រីរាជការចំនួន២រូប ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស។

-ធ្វើប្រកាសស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចំនួន១រូប ចូលបម្រើការងារវិញ។

-ធ្វើប្រកាសស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន១រូប ពីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឱ្យទៅបម្រើការងារនៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តស្វាយរៀង។

**១.៣.ការងារបណ្តុះបណ្តាល**

-រៀបចំបណ្តុះបណ្តាលមន្ត្រីរាជការចំនួន២០រូបស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ នៅទីស្តីការក្រសួង។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន៤រូប ទៅបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ ដើម្បីការកែទម្រង់នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សិង្ហបុរី។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ទៅបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការអេឡិចត្រូនិកថ្មី(E passport) នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-ចាត់បញ្ជូនមន្ត្រីរាជការក្របខ័ណ្ឌឆ្នាំ២០១៩ ចំនួន៦រូប ទៅបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល។

**១.៤.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-ចូលរួមពិនិត្យផ្តល់យោបល់ទាក់ទងចំណាយផ្ទៃក្នុងរបស់អង្គភាពក៏ដូចជាក្រសួងទាំងមូល។

-ទូទាត់ឯកសារបេសកកម្មក្នុងក្រសួងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការប្រចាំខែ។

-ទូទាត់រាជ្ជទេយ្យបុរេប្រទាន ឆ្នាំ២០២០ទាំងបួនជុំ។

-ទូទាត់ចំណាយសន្និបាតបូកសរុបលទ្ធការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារបន្តឆ្នាំ២០២០ របស់ក្រសួង។

-ទូទាត់ថ្លៃប្រើប្រាស់ទឹកចាប់ពីថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២២០២០។

-ទូទាត់ថ្លៃប្រើប្រាស់អគ្គិសនីប្រចាំខែថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩ ដល់ខែឧសភា ឆ្នាំ២០២០។

-ទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទ(Mobile) ចាប់ពីខែធ្នូ ឆ្នាំ២០១៩ ដល់ខែមិថុនា ឆ្នាំ២០២០។

-ទូទាត់ថ្លៃប្រើប្រាស់ទូរស័ព្ទ IDD ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ខែឧសភា ឆ្នាំ២០២០។

-ទូទាត់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាប្រចាំខែធ្នូ ឆ្នាំ២០២០។

-រៀបចំឯកសារស្នើសុំគោលការណ៍ធានាចំណាយទិញរថយន្ត ឆ្នាំ២០២០។

-រៀបចំឯកសារស្នើសុំគោលការណ៍ធានាចំណាយសម្ភារ និងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យាឆ្នាំ២០២០។

-រៀបចំឯកសារស្នើសុំគោលការណ៍ធានាចំណាយសម្ភារ និងសម្ភារប្រើប្រាស់ ឆ្នាំ២០២០។

-រៀបចំឯកសារពិគ្រោះថ្លៃទិញម៉ូតូប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់សង្ហារិម និងសម្ភារប្រើប្រាស់ឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់ការបោះពុម្ពសៀវភៅច្បាប់ប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់ប្រេងឥន្ធនៈប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់ការងារជួសជុលមធ្យោបាយដឹកជញ្ជូនឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់សម្ភារអនាម័យ ថែទាំអគារនឹងឧបករណ៍បច្ចេកទេសប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់សម្ភារការិយាល័យប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់សម្ភារ និងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យាប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារទូទាត់ការងារជួសជុលកែលម្អបន្ទប់សាលប្រជុំអន្តរជាតិ ដំបូលបុស្សុក ខណ្ឌកញ្ចក់បន្ទប់ទឹក និងរោងដាក់ម៉ូតូ នៅទីស្តីការក្រសួង។

-រៀបចំឯកសារស្នើសុំឥណទានបន្ថែមជំពូក៦៤ ឆ្នាំ២០២០។

-រៀបចំឯកសារតារាងសរុបផែនការលទ្ធកម្មប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារគម្រោងកម្មវិធីចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ២០២១។

-បែងចែកប្រេងឥន្ធនៈដោះស្រាយរាល់បេសកកម្ម សំណើផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-បែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់បេសកកម្ម និងសំណើផ្សេងៗជូនថ្នាក់ដឹកនាំនាយកដ្ឋានក្រោមឱវាទក្រសួង។

-បែងចែកទឹកបរិសុទ្ធសម្រាប់ប្រជុំជូនថ្នាក់ដឹកនាំ និងតាមបណ្តានាយកដ្ឋានក្រោមឱវាទក្រសួង។

-ជួសជុលសម្ភារការិយាល័យ គ្រឿងយន្ត និងបរិក្ខាបច្ចេកទេសក្នុងទីស្តីការក្រសួង។

-ចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

### ១.៥.ការងារផែនការ និងស្ថិតិ

-រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២១-២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ទទួលឯកសារពីក្រសួងផែនការស្តីពីសំណើសុំរៀបចំគម្រោងសម្រាប់ដាក់បញ្ចូលកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស) ៣ឆ្នាំរំកិល២០២១-២០២៣។

-រៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំ២០២០ ទាំងរដ្ឋបាលថ្នាក់កណ្តាល និងមន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើការផ្សព្វផ្សាយ និងរៀបចំទម្រង់បែបបទ ដើម្បីបំពេញនូវតារាងផែនការចំណាយ។

-ធ្វើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-រៀបចំគម្រោងផែនការថវិកាសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ ២០១៨-២០២០ និងផ្តល់ធាតុចូលលើផែនការដំណាក់កាលទី២ ២០២១-២០២៥ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីមនុស្សចាស់២០១៧-២០៣០។

-រៀបចំឯកសារដំឡើងថ្នាក់តាមកម្រិតសញ្ញាបត្រ និងដំឡើងថ្នាក់តាមវេនអតីតភាព របស់នាយកដ្ឋានផែនការ និងស្ថិតិ។

-ធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់រួចរាល់ និងរៀបចំចងក្រងឯកសារទៅតាមវិស័យមួយៗ ដែលបានអនុវត្តកន្លងមក ដើម្បីដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងចុះហត្ថលេខា ផ្ញើជូនវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី។

-រៀបចំផែនការក្រសួងដើម្បីដាក់ចូលក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

-បន្តកែសម្រួលទៅលើទម្រង់បែបបទ និងការរៀបចំប្រព័ន្ធទិន្នន័យ ដើម្បីងាយស្រួលក្នុងការសម្រួលព័ត៌មាន របស់មន្ត្រីរាជការគ្រប់បណ្តានាយកដ្ឋាន និងមន្ទីររាជធានី-ខេត្តចំណុះឱ្យទីស្តីការក្រសួង។

-ធ្វើការរៀបចំបញ្ចូលទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងទៅតាមវិស័យរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់ឆ្នាំ២០២០។

-បញ្ចូលទិន្នន័យជាបន្តបន្ទាប់ និងចុះតាមដានការអនុវត្តច្បាប់។

-ពិនិត្យផ្ទៀងផ្ទាត់ស្ថិតិទូទៅក្រសួង និងកែសម្រួលតាមនាយកដ្ឋាននីមួយៗ ថ្នាក់កណ្តាល ដើម្បីធ្វើបច្ចុប្បន្នភាព ឡើងវិញ។

-បន្តធ្វើការកែសម្រួលតួនាទីមន្ត្រី និងមុខងារដល់នាយកដ្ឋានផែនការ និងស្ថិតិ។

-បំពេញការងារតាមដាន និងវាយតម្លៃរាល់កិច្ចការផែនការកិច្ចប្រតិបត្តិការការងាររបស់អង្គភាព។

-បន្តរៀបចំបញ្ចូលទិន្នន័យតារាងរបាយការណ៍សមិទ្ធកម្មអនុវត្តថវិកាកម្មវិធី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ តាមអគ្គនាយកដ្ឋានទាំងបី និងតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ត្រៀមរៀបចំតារាងរបាយការណ៍សមិទ្ធកម្មអនុវត្តថវិកាកម្មវិធី សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ តាមអគ្គនាយកដ្ឋានទាំងបី និងតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-សរុបរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០នៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងមន្ទីររាជធានី-ខេត្ត។

-បន្តធ្វើការស្រង់ទិន្នន័យ និងសកម្មភាពផ្សេងៗ នៅគ្រប់បណ្តានាយកដ្ឋាន អង្គភាពដែលពាក់ព័ន្ធ និងមន្ទីររាជធានី-ខេត្ត ដើម្បីសរុបរបាយការណ៍ក្នុងការចុះតាមដាន និងវាយតម្លៃនៅការងារដែលបានអនុវត្តកន្លងមក។

-រៀបចំកែសម្រួលនូវទម្រង់បែបបទសកម្មភាពការងារនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០។

-រៀបចំរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ចូលរួមសិក្ខាសាលាស្តីពីការប្រើប្រាស់ និងរៀបចំកម្មវិធីវិនិយោគសាធារណៈ(ក.វ.ស)៣ឆ្នាំរំកិល នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប។

-ចូលរួមសិក្ខាសាលាចែករំលែកបទពិសោធន៍ និងពង្រឹងសមត្ថភាពដល់ការងារក្រុមអន្តរក្រសួងតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន២០១៦-២០៣០ នៅសណ្ឋាគារសុខាភ្នំពេញ។

-រៀបចំប្រជុំ និងចូលរួមប្រជុំ នៅទីស្តីការក្រសួង និងក្រសួង-ស្ថាប័នផ្សេងចំនួន១៥លើក។

## **១.៦.ការងារសហប្រតិបត្តិការអន្តរជាតិ**

-ចូលរួមទទួលគណៈប្រតិភូដែលបានមកជួបសម្តែងការគួរសមជាមួយលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៤លើក គឺឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ឯកឧត្តម ឯកអគ្គរាជទូតជប៉ុន លោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋបារាំង និងលោកជំទាវឯកអគ្គរដ្ឋទូតសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួង បន្ទប់ទទួលភ្ញៀវអន្តរជាតិ។

-សម្របសម្រួលលិខិត និងចូលរួមក្នុងកម្មវិធីបដិសណ្ឋារកិច្ចជូនគណៈប្រតិភូអធិការកិច្ចទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

-សម្របសម្រួល និងចាត់ចែងដំណើរទស្សនកិច្ចការងារ របស់គណៈប្រតិភូជាន់ខ្ពស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី២៦ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពឥស្សរជនជាន់ខ្ពស់ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជាចំនួន២លើក។

-ចាត់មន្ត្រីរាជការចំនួន២រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការអេឡិចត្រូនិចថ្មី(E passport) នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-ចូលរួមពិធីបុណ្យជាតិនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ចំនួន១លើក សហព័ន្ធរុស្ស៊ីចំនួន១លើក សាធារណរដ្ឋកូរ៉េចំនួន១លើក ព្រះរាជាណាចក្រជប៉ុនចំនួន១លើក និងព្រះរាជាណាចក្រថៃចំនួន១លើក នៅស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា។

-ចូលរួមពិធីទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ ដឹកនាំដោយឯកឧត្តម ប៊ុនញ៉ាំង វរជីត អគ្គលេខាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅមុខព្រះបរមរាជវាំង។

-រៀបចំគ្រឿងឥស្សរិយយសសហមេត្រីចំនួន២គ្រឿង ជូនឥស្សរជនជាន់ខ្ពស់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានស្នាដៃក្នុងការរួមចំណែកបំពេញភារកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

-សម្របសម្រួលលិខិតឆ្លងដែនជូនថ្នាក់ដឹកនាំក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន១៩ច្បាប់។

-បកប្រែលិខិតផ្សេងៗចំនួន១០ច្បាប់។

-ធ្វើសេចក្តីព្រាងនូវខ្លឹមសារនៃធាតុចូល(Input)ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យអធិការកិច្ច (Cooperation on Inspection Affairs) ផ្ញើរជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមក្នុងកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម(JC) លើកទី១៨ ឆ្នាំ២០២០។

-ចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម(JC) លើកទី១៨ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតាមប្រព័ន្ធវីដេអូConferenceចំនួន៣លើក ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស ដោយលោកជំទាវ សុភ័គ្គ ថាវី រដ្ឋលេខាធិការតំណាងឱ្យក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើខ្លឹមសារសេចក្តីព្រាងកំណត់ហេតុកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម(JC) លើកទី១៨ តាមប្រព័ន្ធវីដេអូ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០។

-រៀបចំកិច្ចប្រជុំ និងតាមដានវឌ្ឍនភាពការងាររបស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងចំនួន៤លើក។

## ២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-រៀបចំប្រជុំ និងចូលរួមប្រជុំនៅទីស្តីការក្រសួង និងក្រសួង-ស្ថាប័នផ្សេងចំនួន៣៧លើក។

-ចូលរួមការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត នៅទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន២លើក។

-បញ្ចូលឯកសារច្បាប់ចំនួន៧២ច្បាប់ ទៅក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ចូលរួមជំនួបពិភាក្សាការងារលើការគ្រប់គ្រងបណ្ណសារ របស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ណសារ ជាមួយ នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋាននីតិក ម្ម នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសណ្ឋាគារសុខាភ្នំពេញចំនួន១លើក។

-ចូលរួមពិធីអបអរសាទរខួបលើកទី១០៩ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២០ ក្រោមប្រធានបទ«មាន សន្តិភាពមានការលើកកម្ពស់យេនឌ័រ» នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមពិធីពន្លត់ទៀនជ័យ អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៧ ទិវាបុណ្យឯករាជ្យជាតិ និងទិវាកំណើត នៃកងយោធពលខេមរភូមិន្ទ នៅវិមានឯករាជ្យ។

-ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តកំពង់ធំចំនួន២លើក ដោយមានអ្នកចូលរួមចំនួន១១២នាក់ (ស្ត្រីចំនួន២៩នាក់)។

-ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ភូមិបាល នៅខេត្តកែបចំនួន១លើក ដោយមានអ្នកចូល រួមចំនួន៣២០នាក់ (ស្ត្រីចំនួន២៣៦នាក់)។

-ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅខេត្តព្រះសីហនុចំនួន៥លើក ដោយមានអ្នកចូលរួមចំនួន១៥៨នាក់ (ស្ត្រីចំនួន៦២នាក់)។

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

-ចុះផ្សព្វផ្សាយច្បាប់ចំនួន១០២លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៦លើក និងមន្ទីររាជធានី-ខេត្តចំនួន៩៦លើក) គឺច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៥៣លើក(ខេត្តព្រះសីហនុចំនួន១៥លើក កំពង់ធំចំនួន១១លើក ស្វាយរៀងចំនួន១១លើក ក្រចេះចំនួន៥លើក កំពង់ចាមចំនួន៤លើក កណ្តាលចំនួន ៣លើក ស្ទឹងត្រែងចំនួន៣លើក និងខេត្តកែបចំនួន១លើក) ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៣៥លើក (ខេត្តព្រះសីហនុចំនួន១០លើក ក្រចេះចំនួន៦លើក កំពង់ចាមចំនួន៥លើក ឧត្តរមានជ័យចំនួន៤លើក កំពង់ធំចំនួន២លើក កណ្តាលចំនួន២លើក តាកែវចំនួន២លើក ត្បូងឃ្មុំចំនួន២លើក កែបចំនួន១លើក និងខេត្តកំពតចំនួន១លើក) ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ចំនួន២លើក(ខេត្តកំពតចំនួន២លើក) ច្បាប់ភូមិបាលចំនួន២លើក(ខេត្តសៀមរាបចំនួន២លើក) ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិចំនួន១លើក(ខេត្តកំពតចំនួន១លើក) និងច្បាប់ស្តីពី

ចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៩លើក(ខេត្តព្រៃវែងចំនួន៧លើក និងខេត្តកំពង់ស្ពឺចំនួន២លើក) ដោយមានអ្នកចូលរួមចំនួន២៥,៣៤១នាក់ (ស្ត្រីចំនួន១០,៥៣៣នាក់) និងបានទទួលសំណួរចំនួន១,៥២២សំណួរ។

-ធ្វើទំនាក់ទំនងនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដើម្បីរៀបចំបន្ថែមផ្សព្វផ្សាយអនុក្រឹត្យស្តីពីការសម្រួលអនុក្រឹត្យ លេខ៨៤ អនក្រ.បក ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនិងច្បាប់ចរាចរណ៍ផ្លូវគោក។

-ធ្វើទំនាក់ទំនង និងបើកសៀវភៅពីនាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់នូវ៖

+ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ចំនួន៧០០ក្បាល។

+ច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិចំនួន៣៥០ក្បាល។

+ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១០៥០ក្បាល។

-ទទួល poster និង leaflet ពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនចំនួន២៩០០សន្លឹក។

-ទទួលសៀវភៅច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ចំនួន៧០០ក្បាល។

### ២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល

ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន៤លើក សេចក្តីព្រាងច្បាប់ចំនួន៣២លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៣៤លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន១៦លើក។

### ២.៤.ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គរបស់រដ្ឋសភា លើសេចក្តីព្រាងច្បាប់ចំនួន៣៣លើក ការបោះឆ្នោតជ្រើសតាំងចំនួន២លើក ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន១លើក និងការសម្រេចអំពីសុពលភាពចំនួន១លើក។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ចំនួន៤០លើក។

## ៣.សកម្មភាពការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច

១.ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅតាមបណ្តាមន្ទីរ-អង្គភាព ក្នុងខេត្តចំនួន១១ រួមមាន៖ ខេត្តបាត់ដំបង ស្ទឹងត្រែង កំពង់ធំ កំពង់ចាម រតនគិរី បន្ទាយមានជ័យ ព្រះសីហនុ កំពង់ស្ពឺ កោះកុង ក្រចេះ និងខេត្តព្រៃវែង។

២.ធ្វើសេចក្តីណែនាំជូនបណ្តាក្រសួង-ស្ថាប័ន ឱ្យជួយជំរុញកែលម្អចំណុចខ្វះខាតដល់មន្ទីរ-អង្គភាព ដែលស្ថិតក្រោមឱវាទបានចំនួន ១០លិខិត រួមមាន៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម សិប្បកម្ម និងនវានុវត្តន៍ និងក្រសួងពាណិជ្ជកម្ម។

៣.ទទួលលិខិតឆ្លើយតបស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតពីក្រសួង ស្ថាប័ន អង្គភាពចំនួន ៦លិខិត រួមមាន៖ អង្គភាពអគ្គិសនីខេត្តបាត់ដំបង មន្ទីររ៉ែ និងថាមពលខេត្តកំពង់ធំ តាកែវ ក្រចេះ កែប និងខេត្តត្បូងឃ្មុំ។

## ៣.២.ភារខារអធិភារកិច្ចលើវិស័យរដ្ឋបាលទូទៅ

១.ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរួមមានៈ

-ការិយបរិច្ឆេទ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួងចំនួន១ និងមន្ទីរ-អង្គភាពក្នុងខេត្តចំនួន៣ រួមមានៈ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និយ័តករទូរគមនាគមន៍ ទូរគមនាគមន៍កម្ពុជា ប្រៃសណីយ៍កម្ពុជា និងអង្គភាពក្រោមឱវាទ ខេត្តកណ្តាល ប៉ៃលិន និងខេត្តកំពង់ធំ។

-ការិយបរិច្ឆេទ២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅតាមបណ្តាមន្ទីរ-អង្គភាពក្នុងខេត្តចំនួន៤ រួមមានៈ ខេត្តព្រៃវែង កំពត តាកែវ និងខេត្តត្បូងឃ្មុំ។

២.ទទួលរបាយការណ៍ពីក្រសួងផ្សេងៗចំនួន៨ របាយការណ៍ជូនជ្រាបពីក្រសួងចំនួន៣ អង្គភាពចំនួន១ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៩គឺៈ

-របាយការណ៍ទទួលពីបណ្តាក្រសួងចំនួន៨គឺៈ

+ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន៩លើក។

+ក្រសួងការពារជាតិចំនួន៨លើក។

+ក្រសួងអប់រំ យុវជន និងកីឡាចំនួន៦លើក។

+ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន៦លើក។

+ក្រសួងមហាផ្ទៃចំនួន២លើក។

+ក្រសួងទេសចរណ៍ចំនួន២លើក។

+ក្រសួងពាណិជ្ជកម្មចំនួន២លើក។

+ក្រសួងព័ត៌មានចំនួន១លើក។

-របាយការណ៍ជូនជ្រាបតាមបណ្តាក្រសួងចំនួន៣ អង្គភាពចំនួន១ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៩គឺៈ

+ក្រសួងមុខងារសាធារណៈចំនួន៩លើក។

+ក្រសួងការពារជាតិចំនួន២លើក។

+ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈចំនួន២លើក។

+អាជ្ញាធរអគ្គិសនីកម្ពុជាចំនួន១លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកោះកុងចំនួន១០លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តត្បូងឃ្មុំចំនួន១០លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបាត់ដំបងចំនួន១០លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានីភ្នំពេញចំនួន៩លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តពោធិ៍សាត់ចំនួន៩លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តតាកែវចំនួន៩លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តស្វាយរៀងចំនួន៨លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកែបចំនួន៨លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ចាមចំនួន៧លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ស្ពឺចំនួន៧លើក។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តក្រចេះចំនួន៧លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តរតនគិរីចំនួន៧លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបន្ទាយមានជ័យចំនួន៧លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំងចំនួន៦លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តស្ទឹងត្រែងចំនួន៦លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកណ្តាលចំនួន៥លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពតចំនួន៥លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ធំចំនួន១លើក។
+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តព្រះសីហនុចំនួន១លើក។

### ៣.៣.ការងារអធិការកិច្ចលើវិស័យសង្គមកិច្ច

១.ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួងចំនួន៣ គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងធម្មការ និងសាសនា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

២.ធ្វើលិខិតជូនដំណឹងស្តីពីការជំរុញឱ្យកែលម្អនូវចំណុចខ្វះខាតដែលប្រតិភូបានរកឃើញ ក្នុងការិយបរិច្ឆេទ ២០១៨ ទៅក្រសួងចំនួន១ និងមន្ទីរ-អង្គភាពក្នុងខេត្តចំនួន១៩ រួមមាន៖ ក្រសួងកិច្ចការនារី ខេត្តពោធិ៍សាត់ កំពង់ចាម ព្រៃវែង ស្វាយរៀង ប៉ៃលិន បាត់ដំបង កោះកុង កំពត តាកែវ ព្រះសីហនុ បន្ទាយមានជ័យ កែប ព្រះវិហារ ស្ទឹងត្រែង កណ្តាល ត្បូងឃ្មុំ មណ្ឌលគិរី កំពង់ស្ពឺ និងខេត្តក្រចេះ។

៣.ទទួលលិខិតឆ្លើយតបស្តីពីការជំរុញការកែលម្អនូវចំណុចខ្វះខាតដែលប្រតិភូបានរកឃើញពីក្រសួង-ស្ថាប័ន និងមន្ទីរ-អង្គភាពចំនួន៦លិខិតរួមមាន៖ ក្រសួងកិច្ចការនារី មន្ទីរធម្មការ និងសាសនាខេត្តកំពង់ស្ពឺ មណ្ឌលគិរី កណ្តាល និងខេត្តត្បូងឃ្មុំ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តរតនគិរី។

### ៣.៤.ការងារតាមដានការអនុវត្តច្បាប់

១.ចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងការិយបរិច្ឆេទ២០១៩ ចំនួន៤លើក ប៉ុន្តែត្រូវបានផ្អាកសកម្មភាពជាបណ្តោះអាសន្នរួមមាន៖

-ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ អនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យ លេខ៨៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសាលាជាតិកសិកម្មព្រែកលៀប ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល អនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើត វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពក្រោមឱវាទ។

-អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យ លេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអង្គភាពក្រោមឱវាទ។

-ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី នៅខេត្តកំពង់ស្ពឺ។

-ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ប្រកាសលេខ០៨៧ អ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី នៅខេត្តកំពង់ឆ្នាំង។

២.ចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់(មន្ទីររាជធានី-ខេត្ត)៖

-នៅតាមដេប៉ូឈើ សិប្បកម្មកែច្នៃឈើ ចរាចរផល-អនុផលព្រៃឈើបានចំនួន៦កន្លែង និងសិប្បកម្មផលិតទឹកបរិសុទ្ធបានចំនួន៣កន្លែង នៅខេត្តកែប។

-ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនបានចំនួន៣លើក អនុក្រឹត្យលេខ៣៩ ស្តីពីការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកបានចំនួន១០លើក និងច្បាប់ស្តីពីជលផលបានចំនួន១១លើក នៅខេត្តកំពង់ធំ។

-ច្បាប់ស្តីពីជលផល និងអង្កេតស្រាវជ្រាវបទល្មើសនេសាទខុសច្បាប់ក្នុងដែនបឹងទន្លេសាប ក្នុងឃុំព្រៃចាស់ ស្រុកឯកភ្នំ នៅខេត្តបាត់ដំបង។

-ច្បាប់ស្តីពីព្រៃឈើ ការវិនិយោគ ការធ្វើអាជីវកម្មយកភាស៊ី ការធ្វើអាជីវកម្មផល-អនុផលព្រៃឈើ ការអនុវត្តលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តឧត្តរមានជ័យ។

-ការគ្រប់គ្រងផ្សារ និងការប្រមូលចំណូលភាស៊ី នៅតាមផ្សាររដ្ឋ នៅរាជធានីភ្នំពេញ។

-ការវិនិយោគសាងសង់ទីសត្តឃាត និងការអនុវត្តសៀវភៅបន្ទុកភាស៊ីសត្តឃាត នៅតាមបណ្តាស្រុកមួយចំនួន ក្នុងខេត្តកំពត។

-ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជន ក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីព្រៃឈើ សិប្បកម្មផលិតទឹកស៊ីអ៊ីវ ទឹកត្រី ទឹកបរិសុទ្ធ ការគ្រប់គ្រងភាស៊ីគ្រប់ប្រភេទ ឡសត្តឃាតដ្ឋាន អនាម័យសត្វ ចំណតរថយន្ត ចំណតទូក នៅខេត្តស្វាយរៀង។

-ការគ្រប់គ្រងថវិកាដំណើរការសាលារៀន គម្រោងមជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ គម្រោងមជ្ឈមណ្ឌលសិក្សាសហគមន៍ នៅតាមសាលារៀន ក្នុងស្រុកសំរោង ក្រុងដូនកែវ ស្រុកទ្រាំង និងស្រុកព្រៃកប្បាស ក្នុងខេត្តតាកែវ។

-ការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅសាលារៀន និងអង្គភាពស្ថិតក្រោមចំណុះមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម នៅស្រុកព្រៃឈរ ស្រុកជើងព្រៃ និងស្រុកបាធាយ ក្នុងខេត្តកំពង់ចាម។

៣.ផ្ញើសេចក្តីជូនដំណឹងស្តីពីការជំរុញកែលម្អចំណុចខ្វះខាតទៅតាមក្រសួង-ស្ថាប័នសរុបចំនួន២៦ រួមមាន៖ ថ្នាក់ជាតិចំនួន១៦លើក និងថ្នាក់ក្រោមជាតិចំនួន១០លើក។

៤.ទទួលលិខិតឆ្លើយតបរបស់ក្រសួង-ស្ថាប័នសរុបចំនួន៥លិខិត រួមមានថ្នាក់ជាតិចំនួន២លិខិត និងថ្នាក់ក្រោមជាតិចំនួន៣លិខិត។

## ៣.៥.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន១២៩បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៨បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១០១បណ្តឹង)ក្នុងនោះ៖

-ពាក្យបណ្តឹងដែលកំពុងត្រូវបានពិនិត្យមានចំនួន១បណ្តឹង(ឆ្នាំ២០២០ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងដែលត្រូវបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន២១បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១៩បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២បណ្តឹង ក្នុងនោះឆ្នាំ២០១៩ ចំនួន៦បណ្តឹង ឆ្នាំ២០២០ ចំនួន១៥បណ្តឹង)។

-ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី-ខេត្តមានចំនួន៩៥បណ្តឹង(ឆ្នាំ២០២០ ចំនួន៩៥បណ្តឹង)។

-ពាក្យបណ្តឹង ដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការមានចំនួន ៣បណ្តឹង(ឆ្នាំ២០១៩ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹង ដែលមន្ទីររាជធានី-ខេត្តសម្រេចតម្កល់ទុកមិនចាត់ការមានចំនួន៥បណ្តឹង (ឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន៣បណ្តឹង)។

-ពាក្យបណ្តឹងដែលបានបញ្ជូនទៅឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺពិនិត្យ និងសម្រេចមានចំនួន៦បណ្តឹង (មន្ទីររាជធានី-ខេត្តចំនួន៦បណ្តឹង ក្នុងនោះឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង)។

-ពាក្យបណ្តឹង ដែលម្ចាស់បណ្តឹងបានបោះបង់ចោលមានចំនួន១បណ្តឹង (មន្ទីររាជធានី-ខេត្តឆ្នាំ២០២០ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងដែលកំពុងត្រូវបានសម្របសម្រួលនៅថ្នាក់ក្រសួងចំនួនចំនួន២បណ្តឹង(ឆ្នាំ២០២០ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹង ដែលបានអង្កេតស្រាវជ្រាវចប់មានចំនួន៧បណ្តឹង (មន្ទីររាជធានី-ខេត្តចំនួន៧បណ្តឹង ក្នុងនោះឆ្នាំ២០១៨ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន៥បណ្តឹង)។

-ពាក្យបណ្តឹង ដែលកំពុងអង្កេតស្រាវស្រាវចំនួន៥៤បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៣បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៣១បណ្តឹង ក្នុងនោះឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៧ ចំនួន៣បណ្តឹង ឆ្នាំ២០១៨ ចំនួន៣បណ្តឹង ឆ្នាំ២០១៩ ចំនួន១៥បណ្តឹង ឆ្នាំ២០២០ ចំនួន៣២បណ្តឹង)។

-ពាក្យបណ្តឹងដែលត្រូវបានត្រៀមចុះអង្កេតស្រាវស្រាវចំនួន៣បណ្តឹង (ឆ្នាំ២០១៩ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង)។

-ពាក្យបណ្តឹងដែលបានទទួលការឆ្លើយតបមានចំនួន៩បណ្តឹង(ឆ្នាំ២០១៤ ចំនួន១បណ្តឹង ឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន៧បណ្តឹង)។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយមានចំនួន៤បណ្តឹង ដោយម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយមានចំនួន៦លើក(ឆ្នាំ២០១៦ ចំនួន២បណ្តឹង ឆ្នាំ២០១៩ ចំនួន២បណ្តឹង)។

-ក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយចំនួន៤បណ្តឹង ដោយបានធ្វើលិខិតជំរុញការដោះស្រាយចំនួន៨លើក (ឆ្នាំ២០១៦ ចំនួន២បណ្តឹង ឆ្នាំ២០១៩ ចំនួន២បណ្តឹង)។

-ក្រសួងបានបញ្ចប់ការដោះស្រាយចំនួន៥៧បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២១បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៣៦បណ្តឹង ក្នុងនោះឆ្នាំ២០១៤ ចំនួន៥បណ្តឹង ឆ្នាំ២០១៦ ចំនួន១បណ្តឹង

ឆ្នាំ២០១៧ ចំនួន៤បណ្តឹង ឆ្នាំ២០១៨ ចំនួន៥បណ្តឹង ឆ្នាំ២០១៩ ចំនួន៩បណ្តឹង ឆ្នាំ២០២០ ចំនួន៣៣ បណ្តឹង)។

### ៣.៦.លទ្ធផលការងារអធិការកិច្ច

ឆ្លងតាមការធ្វើអធិការកិច្ចក្នុងឆ្នាំ២០២០ បានពិនិត្យឃើញថាក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព តាមបណ្តារាជធានី ខេត្តបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានបានល្អប្រសើរ។ ទន្ទឹមនឹងនោះ ក៏នៅមានចំណុចអវិជ្ជមានមួយចំនួនដែលត្រូវបានពិនិត្យឃើញ និងបានជំរុញឱ្យកែលម្អដូចខាងក្រោម៖

៣.៦.១-ការងារអធិការកិច្ច៖

ការគ្រប់គ្រងរដ្ឋបាល

-ការគ្រប់គ្រងសៀវភៅចុះលេខលិខិតចេញ-ចូល នៅតាមក្រសួង មន្ទីរ-អង្គភាពមួយចំនួន នៅមានកម្រិតត្រូវបានចុះលេខលិខិតស្ទួន ចុះលេខលិខិតរំលង ចុះលេខរៀងលិខិតមិនតាមលំដាប់លំដោយ ចុះលេខលិខិតដោយពុំបានបញ្ជាក់ខ្លឹមសារ និងពុំបានបិទបញ្ជីសៀវភៅចុះលេខលិខិតចេញ-ចូលប្រចាំឆ្នាំ ឱ្យបានត្រឹមត្រូវ។

-ការគ្រប់គ្រងវត្តមានមន្ត្រីរាជការ នៅតាមក្រសួង មន្ទីរ-អង្គភាពមួយចំនួន ពុំទាន់បានត្រឹមត្រូវស្របតាមអនុក្រឹត្យលេខ៥៦ អនក្រ. បក ចុះថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា។

-មន្ត្រីរាជការនៅតាមក្រសួង មន្ទីរ-អង្គភាពមួយចំនួនមានឈ្មោះចុះបេសកកម្ម ប៉ុន្តែបានចុះហត្ថលេខាលើបញ្ជីវត្តមាន ឬឯកសាររដ្ឋបាលនៅមន្ទីរ-អង្គភាពក្នុងកាលបរិច្ឆេទដូចគ្នា។

-មន្ទីរសាធារណការ និងដឹកជញ្ជូនមួយចំនួន មានភាពយឺតយ៉ាវក្នុងការស្រង់ស្ថិតិមធ្យោបាយដឹកជញ្ជូននៅក្នុងខេត្ត ដើម្បីគ្រប់គ្រងការងារដឹកជញ្ជូន និងឡជីសស្ទីកផ្លូវគោក។

-មន្ទីរសាធារណការ និងដឹកជញ្ជូនមួយចំនួន ពុំទាន់ជំរុញ ក៏ដូចជាមានវិធានការឱ្យម្ចាស់យានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃតម្លើងយានយន្តមកចុះបញ្ជី និងសុំលិខិតអនុញ្ញាតអាជីវកម្ម។

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីមួយចំនួន ពុំទាន់បានរៀបចំចងក្រងបញ្ជីតម្លៃពលកម្ម សម្ភារបរិក្ខារ និងគ្រឿងសំណង់។

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីមួយចំនួន ពុំបានចុះត្រួតពិនិត្យស្ថិតិក្រុមជាង និងស្ថិតិសំណង់ទូទាំងខេត្តនៅក្នុងដែនដីរបស់ខ្លួននៅឡើយ។

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីមួយចំនួន ពុំទាន់ជំរុញ និងមានវិធានការ ចំពោះម្ចាស់ការដ្ឋានសំណង់ដែលបានសាងសង់ដោយគ្មានលិខិតអនុញ្ញាតសាងសង់។

-សាខាពន្ធដារខេត្តមួយចំនួន ពុំទាន់ប្រើប្រាស់អស់លទ្ធភាពលើការធ្វើសវនកម្មសហគ្រាស ពុំទាន់បានព្យួរទុកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមរបស់ក្រុមហ៊ុនសហគ្រាសមួយចំនួន ដែលបានដាក់លិខិតប្រកាសពន្ធសូន្យ និងពុំទាន់ ប្រើប្រាស់អស់លទ្ធភាពលើការប្រមូលពន្ធអចលនទ្រព្យប្រចាំឆ្នាំ។

-ប្រភពបំពុលរបស់រោងចក្រ សហគ្រាសជាច្រើន ដែលមានទីតាំងនៅមូលដ្ឋានក្នុងខេត្តមួយចំនួន ពុំទាន់បានបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំតាមការស្ម័គ្រចិត្តសម្រាប់ការស្តារបរិស្ថានឡើងវិញ។

-រដ្ឋបាលខេត្តមួយចំនួន ពុំទាន់បានស្រង់ស្ថិតិមូលដ្ឋានអាជីវកម្ម និងផលិតកម្មគ្រប់ប្រភេទដែលមានមូលដ្ឋានក្នុងខេត្ត។

-រដ្ឋបាលខេត្តមួយចំនួន ពុំទាន់មានទិន្នន័យបច្ចុប្បន្នភាពផ្ទាំងប៉ាណូអចល័តទូទាំងខេត្ត។

**ការគ្រប់គ្រងហិរញ្ញវត្ថុ**

-ភាពយឺតយ៉ាវក្នុងការបង់ចំណូលមិនមែនសារពើពន្ធចូលថវិការដ្ឋ។

-បានរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសចំនួនកំណត់។

-ការគ្រប់គ្រង និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី ពុំមានរៀបចំឯកសារយុត្តិការពាក់ព័ន្ធឱ្យបានត្រឹមត្រូវ។

-ពុំបានប្រើប្រាស់បង្កាន់ដៃទទួលប្រាក់មានទម្រង់ឯកភាពដែលបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប្រើប្រាស់ពុំទាន់សមស្របតាមសារាចរណែនាំលេខ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់។

-បានចំណាយថវិការដ្ឋសម្រាប់ទូទាត់ការជួសជុលមធ្យោបាយដឹកជញ្ជូន និងបរិក្ខារបច្ចេកទេស មួយចំនួន ពុំបានបញ្ជាក់ពីអត្តសញ្ញាណ និងពុំមានឯកសារយុត្តិការពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

-ការចំណាយថវិការដ្ឋសម្រាប់ទូទាត់លើការរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងទទួលភ្ញៀវជាតិអន្តរជាតិ ពុំមានឯកសារយុត្តិការពាក់ព័ន្ធ ឱ្យបានគ្រប់គ្រាន់ ច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

-បានបញ្ចេញប្រេងឥន្ធនៈ និងសម្ភារការិយាល័យ ដោយពុំមានឯកសារពាក់ព័ន្ធ ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

-របបស្លៀកពាក់ និងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនសម្រាប់ពិរុទ្ធជន និងទណ្ឌិត ដែលជាប់ឃុំនៅក្នុងពន្ធនាគារខេត្តមួយចំនួនមានភាពយឺតយ៉ាវ។

-ថវិកាសម្រាប់ជូនទណ្ឌិតដែលត្រូវដោះលែងនៅតាមពន្ធនាគារខេត្តមួយចំនួនមានភាពយឺតយ៉ាវ។

-សាខាពន្ធដារខេត្តមួយចំនួន មានភាពយឺតយ៉ាវក្នុងការផ្តល់សេវាសាធារណៈពន្ធលើឈ្នួលផ្ទះ/ដី និងពុំទាន់មានវិធានការតាមនីតិវិធីច្បាប់លើមូលដ្ឋានអាជីវកម្ម ដែលមិនទាន់ដាក់លិខិតប្រកាស។

-ពុំទាន់បានចាត់វិធានការតឹងទារបំណុល ស្របតាមអនុក្រឹត្យលេខ៧២ អនក្រ. ប្រក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

-ពុំបានធ្វើរបាយការណ៍សមិទ្ធិកម្ម និងការអនុវត្តថវិកាកម្មវិធី ពុំស្របតាមប្រកាសលេខ១៩១១ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី។

-ក្រុមលទ្ធកម្មមន្ទីរខ្លះអនុវត្តកិច្ចលទ្ធកម្មមួយចំនួន នៅមានចំណុចខ្វះខាតមួយចំនួនដូចជា៖

+ពុំបានធ្វើការផ្សព្វផ្សាយជាសាធារណៈតាមរយៈសារពត៌មាននៅឡើយ។

+ពុំទាន់បានធ្វើបច្ចុប្បន្នភាពក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ និងក្រមសីលធម៌លទ្ធកម្ម របស់ក្រុមលទ្ធកម្ម។

+ពុំទាន់បានចាត់ចែងរៀបចំតារាងទិន្នន័យតម្លៃទីផ្សារនៃសមាសធាតុលទ្ធកម្ម សម្រាប់ទុកជាព័ត៌មានបន្ថែមក្នុងការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា។

+យឺតយ៉ាវក្នុងការអនុវត្តតាមពេលវេលានៃកិច្ចលទ្ធកម្មដែលមានក្នុងផែនការលទ្ធកម្មឆ្នាំ២០១៩។

+ពុំទាន់បានធ្វើបច្ចុប្បន្នភាពឯកសារដេញថ្លៃនៅឡើយ។

+បានរៀបចំទម្រង់ឯកសារកិច្ចសន្យាលទ្ធកម្មជាមួយអ្នកផ្គត់ផ្គង់ ឬអ្នកទទួលម៉ៅការ ពុំបានឱ្យគ្រប់ភាគីពាក់ព័ន្ធ ចុះហត្ថលេខាខ្ទីលើកិច្ចសន្យាឡើយ។

+ពុំបានបញ្ចូលព័ត៌មានបញ្ជាក់អំពីលេខគណនីធនាគាររបស់អ្នកផ្គត់ផ្គង់ ឬអ្នកទទួលម៉ៅការ។

+បានចេញសេចក្តីជូនដំណឹងស្តីពីការសម្រេចប្រគល់កិច្ចសន្យា ទៅឱ្យក្រុមហ៊ុនដេញថ្លៃឈ្នះ ដោយពុំបានចម្លងជូនក្រុមហ៊ុនដែលដេញថ្លៃចាញ់។

+យឺតយ៉ាវចេញលិខិតជូនដំណឹងស្តីពីការអនុញ្ញាតដកប្រាក់កក់ធានាការធានាការពិគ្រោះថ្លៃ/ដេញថ្លៃ និងប្រាក់កក់ ធានាការអនុវត្តកិច្ចសន្យា ជូនក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ។

+ពុំបានចេញវិញ្ញាបនបត្របញ្ចប់ការងារ(ការទទួលយកបណ្តោះអាសន្ន) និងវិញ្ញាបនបត្រទទួលខុសត្រូវលើសុពលភាពសំណង់(ការទទួលយកជាស្ថាពរ)។

+ពុំទាន់បានថែរក្សាសំណុំឯកសារកិច្ចលទ្ធកម្មមួយចំនួនឱ្យបានគត់មត់។

+បានធ្វើការប្រគល់-ទទួលការងារសំណង់ ដោយពុំស្របតាមប្រតិទិនការងារដែលមានកំណត់ក្នុងកិច្ចសន្យា។

**ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

-កង្វះខាតក្នុងការធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុពុំស្របតាមអនុក្រឹត្យលេខ៦៦ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមានកម្រិត ជាពិសេសនៅតាមសាលាខេត្តមួយចំនួន ត្រូវប្រជាជនទន្ទ្រានកាន់កាប់ មួយចំនួនទៀតត្រូវបានអតីតមន្ត្រី និងមន្ត្រីក្នុងរដ្ឋបាលខេត្ត មានផ្ទះក្នុងបរិវេណខេត្ត និងកំពុងស្នាក់នៅ។

-មានភាពយឺតយ៉ាវក្នុងការស្នើសុំគោលការណ៍ជម្រះចេញពីបញ្ជីសារពើភណ្ឌ នូវទ្រព្យសម្បត្តិដែលចាស់ទ្រុឌទ្រោម ខូចគុណភាពប្រើប្រាស់លែងកើត ពុំស្របតាមអនុក្រឹត្យលេខ៦៦អនក្រ. បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

-ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះប្រចាំឆ្នាំ ពុំទាន់ពេលវេលា និងត្រឹមត្រូវស្របតាមសារាចរណែនាំលេខ០៧ សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

-ការកត់ត្រាសម្ភារបរិក្ខារបច្ចេកទេស ដែលទិញតាមរយៈរដ្ឋទេយ្យបុរេប្រទាននិងក្រសួងផ្តល់ឱ្យចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ស្របតាមសារាចរណែនាំលេខ០៧. សរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

-ពុំបានបង់លេខសម្គាល់លើសម្ភារ បរិក្ខារ និងគ្រឿងសង្ហារិមឱ្យបានច្បាស់លាស់ និងត្រឹមត្រូវនៅឡើយ។

**៦.១.២. ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

ក្រសួងបានទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ បានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដោយបានទទួលពាក្យបណ្តឹងសរុបចំនួន១២៩បណ្តឹង (អគ្គនាយដ្ឋានអធិការកិច្ចចំនួន២៨បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១០១បណ្តឹង) ក្នុងនោះបណ្តឹងដែលបានបញ្ចប់ការដោះស្រាយចំនួន៥៧បណ្តឹង(អគ្គនាយដ្ឋានអធិការកិច្ចចំនួន២១បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៣៦បណ្តឹង) ដែលបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយទំនាស់ក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋ៖

១.ករណីវិវាទដីធ្លីរវាងប្រជាពលរដ្ឋ និងឧកញ៉ា លឹម ទាឡេង នៅភូមិទួលពង្រ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលបានលើកឡើងដោយអនុប្រធានប្រតិភូគណបក្សខ្មែរតែមួយ (ករណីនេះ បានបញ្ចប់ដោយការសម្របសម្រួល)។

២.លោក ស៊ុន បណ្ឌូល ប្ដឹងលោកឧត្តមសេនីយ៍ ដុម ហាក់ បានឃុបឃិតគ្នាជាមួយអាជ្ញាធរភូមិ ស្រុក លួចយកដីរបស់គាត់ទំហំ៦ហិកតាយកទៅលក់ឱ្យឧកញ៉ា លឹម ទាឡេង (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣.ករណីតម្រុយនៃភាពមិនប្រក្រតីក្នុងបំណងរឹបអូសយកដីមណ្ឌលកុមារកំព្រា និងសាលានៃក្ដីសង្ឃឹម សាខាក្រុងកំពង់សោម របស់អង្គការ Assemblies of God ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលបានលើកឡើងដោយប្រធានប្រតិភូគណបក្សខ្មែរក្រោក(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៤.ឈ្មោះ ប៉ែន ច័ន្ទសេង នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្ដឹងអាជ្ញាធរឃុំប៉ោយប៉ែត អាជ្ញាធរស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលបានចុះហត្ថលេខាលើលិខិតលក់-ទិញដីរបស់ឈ្មោះ ហេង ពៅ និងឈ្មោះ សាយ សុធុល និងប្ដឹងមន្ត្រីការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងប៉ោយប៉ែត ដែលបានចុះវាស់វែងដីអោយឈ្មោះ ហេង ពៅ និងឈ្មោះ សាយ សុធុល ជាន់លើដីរបស់ខ្លួនទំហំ៣ហិកតា ស្ថិតនៅភូមិស្ទឹងបត់ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៥.ឈ្មោះ សេង ស៊ីដារ៉ា នៅផ្ទះលេខ៤៤B ផ្លូវលេខ៤៤០ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ និងលោកស្រី ខៃ ស្រីមាស នៅផ្ទះលេខ៧៤E ផ្លូវលេខ២៤៤ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្ដឹងអាជ្ញាធរឃុំប៉ោយប៉ែត អាជ្ញាធរស្រុកអូរជ្រៅ បានឃុបឃិតគ្នាលក់ដីរបស់ពួកគាត់ ស្ថិតនៅភូមិស្ទឹងបត់ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៦.លោក យ៉ង់ ធី ប្ដឹងលោក យឹម នីរ៉ា ដែលរួមជាមួយតតិយជនបានរំលោភបំពាន និងធ្វើការសាងសង់ផ្ទះខុសច្បាប់លើដីក្រុមគ្រួសារគាត់មួយកន្លែង ស្ថិតនៅភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល (ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

៧.ឈ្មោះ ឡុង តារា ប្ដឹងឧកញ៉ា ជួន កន ឧកញ៉ា ប៊ុន ជេស និងឈ្មោះ ស្រ៊ុន ឆេង បានប្រើអំណាចឃុបឃិតគ្នាកសាងឯកសារបន្លំយកដីទំហំ២២,១៣៤ម៉ែត្រការ៉េ ស្ថិតនៅភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

៨.លោក ស៊ី យាងហា ស្នើសុំសម្ដេចតេជោ នាយករដ្ឋមន្ត្រី ជួយអន្តរាគមន៍មកក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះដោះស្រាយដីឱ្យក្រុមហ៊ុនគាត់បានគ្រប់គ្រង និងកាន់កាប់ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ស្ថិតនៅភូមិ៦ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត) ។

៩.អ្នកស្រី ស ស៊ន់ ប្ដឹងឈ្មោះ ឡ ហេងហួត បានឃុបឃិតគ្នារំលោភយកដីរបស់ខ្លួនទំហំ២៨,៨៤២ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃល្វា សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១០.ពាក្យសុំអន្តរាគមន៍ឈ្មោះ តែ ចាងហួ ស្នើសុំកាន់កាប់ដីជាកម្មសិទ្ធិស្របច្បាប់របស់ក្រុមហ៊ុនចេងដឹង អាយឺធេកឈ័រ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន១២៦ប័ណ្ណ ទំហំសរុប៥,៦៣៤,៨៦៤

ម៉ែត្រការ៉េ ស្ថិតនៅភូមិពូធឿង សង្កាត់បិទត្រាង ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ ដែលត្រូវបានជនខិលខូចមួយចំនួនរំលោភកាន់កាប់ ដោយខុសច្បាប់ ធ្វើឱ្យក្រុមហ៊ុនមិនអាចយកដីទាំងនោះមកកាន់កាប់គ្រប់គ្រង ផ្ទេរសិទ្ធិ និងអភិវឌ្ឍន៍បាន(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១១.ឈ្មោះ យឹម សារ៉ុម តំណាងឱ្យឈ្មោះ ម៉ិញ ឈុំ និងឈ្មោះ ម៉ិញ ឈឹម នៅភូមិព្រៃក្តី សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ហេង សុថារិទ្ធ មន្ត្រីរដ្ឋបាលព្រៃឈើ បានឃុបឃិតជាមួយអាជ្ញាធរសង្កាត់ច្បារមន បានបោះបង្គោលរំលោភយកដីរបស់ឈ្មោះ ម៉ិញ ឈុំ និងឈ្មោះ ម៉ិញ ឈឹម ចំនួន២ក្បាលដី គឺក្បាលដីលេខ៥៨៨ និងលេខ៥៨៩(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១២.លោក ឆេង សារី រស់នៅភូមិអូរកន្សែង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្តឹងឈ្មោះ ជា ម៉េងសែ ថាបានឃុបឃិតគ្នាយកដីរបស់គាត់ទំហំ២០ម៉ែត្រx៤០ម៉ែត្រការ៉េ ស្ថិតនៅភូមិព្រៃគុក ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១៣.ពាក្យសុំអន្តរាគមន៍ឈ្មោះ ឡុង ហៀង និងអ្នកស្រី សូ សាម៉េត តំណាងប្រជាពលរដ្ឋចំនួន២៥គ្រួសារ នៅខេត្តកំពង់ចាម ស្នើសុំឱ្យក្រសួងរ៉ែ និងថាមពល ចាត់គណៈប្រតិភូចុះដល់ទីតាំងដីដាក់ស្តែង ព្រោះមិនពេញចិត្តនឹងលិខិតឆ្លើយតបរបស់ក្រសួងរ៉ែ និងថាមពល លេខ ១៨៦៥រថ.អរថ ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលធ្វើឱ្យពួកគាត់រងអយុត្តិធម៌(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១៤.ឈ្មោះ តាន់ តាត់ តំណាងឈ្មោះ តេង ឡាយ ប្តឹងឈ្មោះ ថោង សូលីម និងឈ្មោះ កែវ វ៉ាលី បានឃុបឃិតគ្នាជាមួយអាជ្ញាធរមានសមត្ថកិច្ច រំលោភយកដីកម្មសិទ្ធិស្របច្បាប់របស់ឈ្មោះ តេង ឡាយ ទំហំ ៣៥,៣៦០ម៉ែត្រការ៉េ ស្ថិតនៅភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១៥.ពាក្យសុំអន្តរាគមន៍របស់លោកស្រី រិទ្ធ សុគន្ធា ករណីលោក រ៉េន រើក មេឃុំកំពង់ស្វាយ និងលោក សំ អឿន អនុប្រធានសាសនាគ្រឹស្ត បានក្លែងបន្លំឯកសាររំលោភយកដីរបស់គាត់ទំហំ២៩ម៉ែត្រx៣០ម៉ែត្រ នៅភូមិខ្លាកូនចាស់ ឃុំកំពង់ស្វាយ ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ(ករណីនេះបានបញ្ចប់ដោយថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកលែងចាត់ការបន្ត)។

១៦.ឈ្មោះ មុំ ឡាង នៅភូមិកណ្តាល ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ប្តឹងឈ្មោះ ទូច វុត្ថា និងប្រពន្ធឈ្មោះ សៀង រ៉ាវី បានរំលោភយកដីរបស់ខ្លួនចំនួន២កន្លែង ស្ថិតនៅភូមិអូរស្ពាន ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី(ករណីនេះបានបញ្ចប់ដោយបង្វែរទៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី)។

១៧.ឈ្មោះ ទូច វុត្ថា និងប្រពន្ធឈ្មោះ សៀង រ៉ាវី ប្តឹងឈ្មោះ ដៀប សាម៉ន និងឈ្មោះ មុំ ឡាង បានសូកប៉ាន់មន្ត្រីដើម្បីបំភាន់ការពិតធ្វើអោយប៉ះពាល់ដល់កិត្តិយសមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ព្រមទាំងគ្រួសាររបស់ពួកគាត់ ពាក់ព័ន្ធករណីទំនាស់ដី ស្ថិតនៅភូមិអូរស្ពាន ឃុំស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី(ករណីនេះបានបញ្ចប់ដោយបង្វែរទៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី)។

១៨.ឈ្មោះ ថៃ ឃីន និងប្រពន្ធឈ្មោះ អ៊ឹង ចន្ធូ ប្តឹងទាមទារដីទំហំ២,០៣៥ម៉ែត្រការ៉េ ស្ថិតនៅភូមិដើមស្រល់ សង្កាត់សែនមនោរម្យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី(ករណីនេះបានបញ្ចប់ដោយបង្វែរទៅសាលាខេត្តមណ្ឌលគិរី)។

១៩.ពាក្យសុំអន្តរាគមន៍ឈ្មោះ តិប ពិចិត្រ នៅរាជធានីភ្នំពេញ ករណីមន្ត្រីជំនាញខេត្តកែប រួមនឹងអាជ្ញាធរពាក់ព័ន្ធ បានឃុបឃិតគ្នាបិទផ្លូវសារធារណៈយកធ្វើប្លង់កម្មសិទ្ធិឯកជន រួចបានគូសប្លង់លើដីកម្មសិទ្ធិរបស់គាត់ (ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺសាលាខេត្តកែប)។

២០.ប្រជាពលរដ្ឋចំនួន១៦គ្រួសារ នៅភូមិត្រុំ ឃុំឡាមិញ និងភូមិឃើន ឃុំកក់ ស្រុកបរកែវ ខេត្តរតនគិរី ប្តឹងក្រុមហ៊ុនតាយសេង និងក្រុមហ៊ុនស្វ៊ាបើរ លីមីតធីត បានឈូសឆាយរំលោភយកដីចំការកៅស៊ូរបស់ពួកគាត់ (ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់)។

២១.ឈ្មោះ ម៉េង គង់មឿន ប្តឹងឈ្មោះ ផន សុភ័ក្ត្រ ជាមន្ត្រីយោធា និងបក្ខពួក បានឃុបឃិតគ្នាជាមួយអាជ្ញាធរមានសមត្ថកិច្ច រំលោភយកដីរបស់គាត់ទំហំ៨,៥៤៩ម៉ែត្រការ៉េ តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ005412070104 ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៦ ស្ថិតនៅភូមិ អន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ (ករណីនេះបានបញ្ចប់ដោយបង្វែរទៅស្ថាប័នផ្សេងដោះស្រាយ គឺសាលារាជធានីភ្នំពេញ)។

២២.ពាក្យបណ្តឹងឈ្មោះ សយ សុជាតិ និងឈ្មោះ ជី សុជា តំណាងឱ្យឈ្មោះ សូ ហែម ជាម្ចាស់ដីទំនាស់នៅភូមិផ្សារតាឡាត់ចាស់ ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ តាំង គឹមចេង ឈ្មោះ ធឹង សារ៉ែង ឈ្មោះ កាន សំបូរ ឈ្មោះ ឡុង មុំ ឈ្មោះ អ៊ួង សោភ័ណ្ឌ ឈ្មោះ សួស សារ៉ាត់ ឈ្មោះ មក ភឿង ឈ្មោះ សឿន ឈ្មោះ ចាន់ ស៊ីន បានឃុបឃិតគ្នារំលោភយកដីរបស់គាត់ ទៅលក់ឱ្យឈ្មោះ ស្រ៊ុន សុខលី នៅផ្សារថ្នល់ទទឹង (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៣.ពាក្យបណ្តឹងឈ្មោះ អ៊ិត សារឿន និងប្រពន្ធឈ្មោះ ទឹម សុធី នៅភូមិស្រែគុយ ឃុំពោធិ៍ចំរើន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ញឹម វណ្ណ នៅភូមិស្រែគុយ ឃុំពោធិ៍ចំរើន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ និងឈ្មោះ មាស សុផានី នៅភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ អ្នកទាំងពីរបានបោកប្រាស់យកដីរបស់គាត់ទំហំ២៣,៤៩១ម៉ែត្រការ៉េ នៅភូមិស្រែគុយ ឃុំពោធិ៍ចំរើន ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ទៅលក់ឱ្យក្រុមហ៊ុនបូមខ្សាច់(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៤-បណ្តឹងឈ្មោះ នៅ សុខន និងឈ្មោះ ម៉ម សារ៉េម (ជាកូន) នៅភូមិកំណាប់ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ គីម សុភា និងឈ្មោះ អ៊ិត គឹមសៀម អ្នកទាំងពីរនៅរាជធានីភ្នំពេញ បានលួចធ្វើប័ណ្ណកម្មសិទ្ធិដោយរំលោភយកដីរបស់ពួកគាត់មានទំហំ៧ម៉ែត្រx៤០ម៉ែត្រ ស្ថិតនៅភូមិកំណាប់ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៥-បណ្តឹងឈ្មោះ សុត លី នៅភូមិគោក ឃុំសង្កែសាទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សួង សឿន នៅភូមិអូរផ្តៅ ឃុំស្នើសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ បានលួចវាស់យកដីរបស់គាត់ធ្វើប័ណ្ណកម្មសិទ្ធិទំហំប្រហែល១៤៧ម៉ែត្រx១៧០ម៉ែត្រ ស្ថិតនៅភូមិអូរផ្តៅ ឃុំស្នើសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៦-ពាក្យបណ្តឹងឈ្មោះ ជា ផល្លា និងឈ្មោះ ឡោ សុខា (ប្តីប្រពន្ធ) នៅភូមិសាលា ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ជុំ តុង (ហៅ សុខ គា) នៅភូមិដូង ឃុំជាំសង្កែ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ បានរំលោភយកដីចំការរបស់គាត់ទំហំប្រហែល២ហិកតាទៅលក់(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៧.ឈ្មោះ ឆាយ ជាលីម មន្ត្រីរដ្ឋបាលព្រៃឈើ សង្កាត់ថ្កូង ស្នើសុំឱ្យមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ស្ពឺ ជួយអន្តរាគមន៍ដោយឈ្មោះ តេង វណ្ណារ័ត្ន នាយសង្កាត់រដ្ឋបាលព្រៃឈើថ្កូង បានរាយការណ៍ ទៅប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ដករូបគាត់ចេញពីមន្ត្រីប្រចាំការនៅសង្កាត់រដ្ឋបាលព្រៃឈើថ្កូង ទៅមន្ត្រីប្រចាំការនៅសង្កាត់រដ្ឋបាលព្រៃឈើគីរីរ័ន្ត ដោយគ្មានមូលហេតុ និងគ្មានកំហុសក្នុងការងារ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៨.ឈ្មោះ សំអាង ផានិត នៅភូមិបុរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ផិត សេរីវឌ្ឍន៍ នៅផ្ទះលេខ៨៨អា ផ្លូវលេខ៣១៧ សង្កាត់បឹងកេងកង២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ និងឈ្មោះ ថា សុមុនី នៅផ្ទះលេខ២២២ ផ្លូវ២២៣ ភូមិព្រែកកាត់ សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល បានប៉ុនប៉ងរំលោភយកដី របស់គាត់ទំហំ៣,០៨០ម៉ែត្រការ៉េ ស្ថិតនៅភូមិសុវណ្ណគីរី ឃុំខ្ទុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

២៩.ឈ្មោះ ម៉ែន ប៊ុនធួន នៅភូមិទួលគោក សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ង៉ែត ស៊ីណង់ នៅភូមិកែក ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានឃុបឃិតគ្នាជាមួយអ្នកគួកដេរដីឈ្មោះ ម៉ែន ប៊ុនធឿន ដោយមានចេតនារំលោភយកដីរបស់គាត់ និងមិនព្រមប្រគល់ប្រាក់តាមកិច្ចសន្យាក្នុងលិខិតទិញ-លក់ដីទំហំ២,២៣៦ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣០.ឈ្មោះ ឃិន គឹមហួយ នៅភូមិតារាជ ឃុំកក់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ប្តឹងប្តីប្រពន្ធឈ្មោះ សាន ស្រីជា នៅភូមិតារាជ ឃុំកក់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ បានធ្វើរបងរំលោភយកដីរបស់គាត់ ដែលមានទទឹងប្រវែង ០.៥ម៉ែត្រ និងបណ្តោយប្រវែង២០០ម៉ែត្រ ស្ថិតនៅភូមិតារាជ ឃុំកក់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣១.ឈ្មោះ អ៊ុង គង្គា នៅភូមិទឹកថ្លា ឃុំគោកព្រីង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ប្តឹងឈ្មោះ ដេត ដុំ នៅភូមិមុខខេត្ត សង្កាត់រកាធំ ក្រុមច្បារមន ខេត្តកំពង់ស្ពឺ បានរំលោភឈូសឆាយយកដីរបស់គាត់មានទំហំប្រហែល៣ហិកតា ស្ថិតនៅភូមិប្រចៀវបាត ឃុំទំព័រមាស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣២.ឈ្មោះ ផាត់ ណាវី នៅភូមិកំពង់ចុះវារ ឃុំវិហារលួង ស្រុកពញាឮ ខេត្តកណ្តាល ប្តឹងឈ្មោះ ឌីន ដា ឈ្មោះឌីន ដុប ឈ្មោះ ឌីន ឡង់ឌី ឈ្មោះ ឌីន ដេត ឈ្មោះ ឌីន សារឿន ឈ្មោះ ឌីន សារិន អ្នកទាំងប្រាំមួយនាក់ នៅភូមិត្រពាំងក្អែក ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ និងឈ្មោះ ហ៊ិន ដន នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បានឃុបឃិតគ្នារំលោភយកដីកម្មសិទ្ធិរបស់គាត់ដោយចេតនាទំហំ១.៨ហិកតា ស្ថិតនៅភូមិត្រពាំងក្អែក ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣៣.ឈ្មោះ ប្រាក់ ផាន និងប្រពន្ធឈ្មោះ ស៊ូ នួន នៅភូមិទំពូង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សៀង សុខយន និងប្រពន្ធឈ្មោះ ខាន់ ចរិយា នៅភូមិទំពូង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺបានលួចធ្វើប័ណ្ណកម្មសិទ្ធិយកដីស្រែរបស់គាត់ ដែលមានក្បាលដីលេខ៤៥២ ទំហំ៧៦៨ម៉ែត្រការ៉េ ស្ថិតនៅភូមិទំពូង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣៤.ឈ្មោះ កែវ សុភា នៅភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ង៉ែត ស៊ីណង់ នៅភូមិកែក ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានលុបអូរចាស់លួចកាយអូរថ្មីបង្វៀងទឹក

ដើម្បីយកដីពុះដីឡូត៍លក់ធ្វើឱ្យបាក់ដីស្រែគាត់ដែលមានទទឹង១ម៉ែត្រ បណ្តោយប្រហែល១០០ម៉ែត្រ ស្ថិតនៅភូមិត្រស់សាលា សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣៥.ឈ្មោះ អ៊ុង គង្គា នៅភូមិទឹកថ្លា ឃុំគោកព្រីង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ប្តឹងឈ្មោះ ឆាវ អ៊ីនទ័រ នៅក្រុងតាខ្មៅ ខេត្តកណ្តាលបានរំលោភលើកិច្ចសន្យាទិញ-លក់ដី មានចេតនារំលោភយកដីរបស់គាត់ចំនួន ១១ហិតា នៅភូមិសុវណ្ណគិរី ឃុំខ្ទុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣៦.ឈ្មោះ ឈុន ម៉េត នៅភូមិកប់ចិន ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សុខ ចន្ទី និងឈ្មោះព្រាម ផានិត (ឪពុក និងកូន) នៅភូមិកប់ចិន ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ បានរំលោភយកដីរបស់គាត់ដោយចេតនា ដោយមិនព្រមប្រគល់នូវប្រាក់បង្គ្រប់ថ្លៃលក់-ទិញ ដែលមានដីទំហំ៣,០១៧ ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងកន្ទួត ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល) ។

៣៧.ឈ្មោះ ជ័យ សាវ៉ាន ឈ្មោះ អ៊ឹម ឌឹន និងឈ្មោះ អ៊ុំ សៅគា តំណាងឱ្យប្រជាពលរដ្ឋចំនួន៣៦គ្រួសារ នៅភូមិតាំងរបង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ប្តឹងក្រុមហ៊ុនហ្វ៉ូជូណា មេភូមិតាំងរបង និងមេឃុំហោងសំណំ ដោយក្រុមហ៊ុនបានកាយប្រឡាយផ្តាច់ផ្លូវ និងស្ពានរបស់ប្រជាពលរដ្ឋឆ្លងកាត់ទៅធ្វើស្រែមានចំនួន៣៦គ្រួសារ ហើយលោកមេភូមិ និងលោកស្រីមេឃុំ មិនព្រមចេញមុខដោះស្រាយជូនប្រជាពលរដ្ឋ ស្ថិតនៅភូមិតាំងរបង ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣៨.ឈ្មោះ មៀច ម៉ាក្សឡេណា ឈ្មោះ វ៉ាន់ សាវី តំណាងឱ្យប្រជាពលរដ្ឋចំនួន៧គ្រួសារ នៅភូមិថ្មសំលៀង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សួង ផល្លា ឈ្មោះ បួ សាលួត នៅភូមិថ្មសំលៀង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងឈ្មោះ ធុំ ម៉ៅ នៅផ្សារថ្នល់ទទឹង ដោយចោទអ្នកទាំងបីបានធ្វើរបងរំលោភយកដីផ្លូវសាធារណៈ ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគាត់ មានទំហំប្រហែល១ម៉ែត្រx ២០០ម៉ែត្រ ស្ថិតនៅភូមិថ្មសំលៀង ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៣៩.ឈ្មោះអ៊ឹម អិត នៅភូមិត្រពាំងកកោះ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ឆេង ស៊ា នៅរាជធានីភ្នំពេញ និងឈ្មោះ វ៉ែន រី នៅភូមិកណ្តុរធំ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ អ្នកទាំងពីរបានឃុបឃិតគ្នាកែឯកសារបង្កាន់ដៃដី ដែលក្រុមចុះវាស់វែងជាប្រព័ន្ធពីឈ្មោះរបស់គាត់ទៅឱ្យឈ្មោះ ឆេង ស៊ា ដែលមានក្បាលដីលេខ៣៩៣ ទំហំ៣,២៦២ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងកកោះ ឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ(ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)។

៤០.ឈ្មោះ ញឹម ដារ៉ា នៅភូមិថ្នល់បែក សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ ប្តឹងឈ្មោះ អ៊ូច រិទ្ធមុន្នី និងឈ្មោះ វង់ ភារី នៅភូមិថ្នល់បែក សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ បានរារាំងការសាងសង់របងលើដីកម្មសិទ្ធិ ស្របច្បាប់របស់គាត់ ករណីនេះដោយភាគីដើមបណ្តឹងព្រមទទួលយកដីទំនាស់៣០% និងចុងចម្លើយព្រមទទួលយក៧០% នៃទំហំដីដែលមានទំនាស់។

៤១.ប្រជាពលរដ្ឋចំនួន៤គ្រួសារ នៅភូមិវះពោះ ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវបានស្នើសុំឱ្យមានការតាមដាន និងជួយជំរុញការចេញវិញ្ញាបនបត្រសម្គាល់អចលនវត្ថុដែលមានការយឺតយ៉ាវ (រត់ការ) តាមរយៈមន្ត្រីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ។ ករណីដោយភាគីចុងចម្លើយយល់ព្រម

ប្រគល់ឯកសារពាក់ព័ន្ធប្លង់ដី កិច្ចសន្យាទិញ-លក់ និងថវិកាចំនួន១,៤០០ដុល្លារអាមេរិក (ថ្លៃសេវាក្រៅប្រព័ន្ធ) ជូនទៅភាគីដើមបណ្តឹងវិញ ដើម្បីបញ្ចប់ទំនាស់។

៤២.ប្រជាពលរដ្ឋចំនួន៤គ្រួសារ នៅភូមិជ្រោយសំពេង សង្កាត់បារាយណ៍ ក្រុងដូនកែវ ខេត្តតាកែវ ស្នើសុំពិនិត្យភាពមិនប្រក្រតីរបស់ម្ចាស់កម្មសិទ្ធិក្បាលដីលេខ៨៣៤ និងលេខ៨៣៥ ដែលបានសាងសង់របងថ្មចូលមកលើដីផ្លូវ ក្នុងពេលដែលខ្លួនមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិនៅឡើយ ករណីនេះក្រុមការងារបានធ្វើលិខិតឆ្លើយតបទៅដើមបណ្តឹង ដោយពិនិត្យឃើញថា ការចេញប័ណ្ណកម្មសិទ្ធសម្គាល់អចលនទ្រព្យរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ ពិតជាអនុវត្តបានត្រឹមត្រូវតាមនីតិវិធី។

៤៣.ប្រជាពលរដ្ឋចំនួន៦គ្រួសារ នៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ប្តឹងឈ្មោះ សឹង សីហា នៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ដែលបានចាក់ដីលុបរំលោភចូលចំណុចអំហាចមុខស្ពាន និងចំណីផ្លូវមុខស្ពានប្រឡាយ៩២ ស្ថិតនៅភូមិកំពង់ជ្រៃ ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ ករណីនេះភាគីចុងចម្លើយបានចាក់ដីលុបនៅលើទំហំដីដែលជាកម្មសិទ្ធស្របច្បាប់ ដូចមាននៅក្នុងប័ណ្ណសម្គាល់អចលទ្រព្យរបស់គាត់ ដែលចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តតាកែវ។

៤៤.ឈ្មោះ ចន ភាន់ និងឈ្មោះ ជៀប កំសត់ តំណាងប្រជាពលរដ្ឋចំនួន៣១គ្រួសារ នៅភូមិជំទាវជ្រែង ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំងប្តឹងសុំជួយដោះស្រាយបញ្ហាដីធ្លីមួយកន្លែង ស្ថិតនៅតំបន់ក្រាំងត្នោត ក្នុងភូមិរលុង ឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ពួកគាត់ទាំងអស់គ្នាចំនួន៣១គ្រួសារ បានកាន់កាប់តាំងពីឆ្នាំ១៩៩៣ រហូតមក ករណីនេះក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង សហការជាមួយអាជ្ញាធរភូមិ-ឃុំ បានធ្វើការសម្រសម្រួលបញ្ចាប់ទំនាស់ ដោយភាគីមានប័ណ្ណដោះស្រាយជាគោលនយោបាយជូនប្រជាពលរដ្ឋក្នុងមួយគ្រួសារចំនួន៣០០ដុល្លារអាមេរិក ដើម្បីបញ្ចប់ទំនាស់ ហើយភាគីប្រជាពលរដ្ឋចំនួន៣១គ្រួសារ យល់ព្រមទទួលយកការដោះស្រាយគោលនយោបាយនេះ។

៤៥.ឈ្មោះ មិន រិត នៅភូមិថ្មី ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង (ផ្ទេរឱ្យកូនប្រុសឈ្មោះ សួន ចំរើន នៅភូមិ-ឃុំខាងលើ ជាតំណាងដោះស្រាយបណ្តឹងនេះ) ប្តឹងឈ្មោះ រស់ គីម ឈ្មោះ ចក់ ភាច ឈ្មោះ ស៊ុំ សែន ឈ្មោះ រ៉ិត គង់ និងឈ្មោះ សុត សឿងដែលបាននាំគ្នាមកទាមទារដីកេរ្តិ៍មរកតរបស់ លោក រស់ សឿន ដែលត្រូវជាប្តី និងឪពុកចិញ្ចឹមរបស់គាត់។ ករណីនេះក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង សហការជាមួយអាជ្ញាធរភូមិ-ឃុំ បានសម្របសម្រួលបញ្ចប់ទំនាស់ ដោយឈ្មោះ សួន ចំរើន ព្រមប្រគល់ដីដែលមានក្បាលដីលេខ១២០៣ ឱ្យទៅឈ្មោះ រស់ គីម ដើម្បីបំពេញឯកសារធ្វើប័ណ្ណកម្មសិទ្ធិ រីឯភាគីឈ្មោះ ចក់ ភាច និងប្រពន្ធឈ្មោះ រស់ គីម ព្រមប្រគល់ដីដែលមានក្បាលដីលេខ៩១១ ឱ្យទៅឈ្មោះ សួន ចំរើន ដើម្បីបំពេញឯកសារធ្វើប័ណ្ណកម្មសិទ្ធិផងដែរ។

៤៦.ប្រជាពលរដ្ឋចំនួន៥គ្រួសារ តំណាងឱ្យប្រជាពលរដ្ឋចំនួន២០៨គ្រួសារ នៅភូមិត្រពាំងពោធិ៍ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងទប់ស្កាត់ការលក់ដីរួមភូមិទំហំ៦ហិកតា ស្ថិតនៅភូមិត្រពាំងពោធិ៍ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ករណីនេះក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង សហការជាមួយអាជ្ញាធរមូលដ្ឋានបានធ្វើការសម្របសម្រួលជាមួយប្រជាពលរដ្ឋ ហើយព្រមទទួលយកតាមការសម្របសម្រួលរបស់ក្រុមការងារ និងព្រមដកពាក្យបណ្តឹងពីគ្រប់ស្ថាប័នដែលដាក់កន្លងមក។

៤៧.ឈ្មោះ ស៊ឹម សារិន នៅរាជធានីភ្នំពេញ ស្នើសុំអន្តរាគមន៍ដីកស្រះចំនួន៣ សម្រាប់ចិញ្ចឹមត្រី និងសត្វផ្សេងៗ លក្ខណៈបច្ចេកទេសវារីវប្បកម្ម ស្ថិតនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ករណីនេះក្រុមការងារចម្រុះខេត្តយល់ឃើញថា៖

-ទីតាំងដែលជីកស្រះនេះពុំមានទំនាស់ទេ ហើយក៏មិនជាប់ពាក់ព័ន្ធសហគមន៍នេសាទ តំបន់អភិរក្សជលផលនាទីព្រៃលិចទឹក និងដែនអតីតឡូត៍នេសាទដែលប្រជាពលរដ្ឋបានប្រើប្រាស់ អាស្រ័យផលស្រែប្រាំង និងចម្ការក្នុងរដូវទឹកសម្រក។

-ដីទំហំ៣២ហិកតានេះ ឈ្មោះ ស៊ឹម សារិនបានប្រមូលទិញពីប្រជាពលរដ្ឋចំនួន២០គ្រួសារ ដែលមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរភូមិ-សង្កាត់។

-មកដល់ពេលនេះ ឯកឧត្តមអភិបាលខេត្តកំពង់ឆ្នាំង បានអនុញ្ញាតជាគោលការណ៍ឱ្យឈ្មោះ ស៊ឹម សារិន ដំណើរការជីកស្រះចំនួន៣ខាងលើស្របតាមនីតិវិធី។

៤៨.ឈ្មោះ ងួន សឿន និងប្រពន្ធឈ្មោះ ឡេង យុន ប្តឹងតវ៉ាដោយចោទឈ្មោះ តា ឃីពីវ ថា បានឃុបឃិតផ្សំគំនិតជាមួយឈ្មោះ សឿ ស៊ីន (ជនល្ងងតាឃីពីវ) លួចធ្វើប័ណ្ណកាន់កាប់តួបល្វែងលេខ២៥B ឱ្យទៅឈ្មោះ ហុក ថៃ (ត្រូវជាកូនបង្កើតរបស់តាឃីពីវ) ស្ថិតនៅផ្សារលើ ក្នុងភូមិត្រពាំងបី សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ករណីនេះក្រុមការងាររកឃើញថា៖

-ការចោទប្រកាន់នេះ គឺមិនត្រឹមត្រូវទេ ព្រោះតាឃីពីវ បានពិនិត្យឃើញថា ការកាត់ផ្ទេរឈ្មោះត្រឹមត្រូវហើយ ទើបគាត់ប្រគល់លុយឱ្យគ្រប់ចំនួន។

-ភាគីទាំងពីរបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ និងព្រមដកពាក្យបណ្តឹងពីគ្រប់ស្ថាប័នទាំងអស់។

៤៩.ឈ្មោះ គង់ ទីសាម៉ា និងប្តីឈ្មោះ ប៊ិត ចាន់វិបុល នៅភូមិខ្វិត ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹង ឈ្មោះ ហ៊ីង ពុធថា (ហៅចាន់ថា) នៅភូមិអណ្តូងពោធិ៍ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្រើល្បិចឃុបឃិតជាមួយមន្ត្រីសុរិយោដី លួចធ្វើប្លង់រឹងយកដី និងផ្ទះរបស់គាត់ ស្ថិតនៅភូមិខ្វិត ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងករណីនេះក្រុមការងាររកឃើញថា៖

-ទំនាស់កើតចេញពីការខ្ចីលុយ ហើយយកដីទៅដាក់បញ្ចាំ នៅពេលដែលគ្មានលុយសងម្ចាស់បំណុលបានកាត់យកដី រួចធ្វើប័ណ្ណកម្មសិទ្ធិ ដោយពុំមានការឯកភាពពីកូនបំណុល។

-មន្ត្រីជំនាញពាក់ព័ន្ធនឹងការចេញប័ណ្ណជាលក្ខណៈប្រព័ន្ធ មានការធ្វេសប្រហែស ដោយសារតែពុំបានសួរនាំឱ្យបានច្បាស់លាស់ពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ដីបច្ចុប្បន្ន។

-ភាគីទាំងពីរបានឯកភាពគ្នាបញ្ចប់ទំនាស់ ដោយភាគីម្ចាស់បំណុលសុខចិត្តផ្ទេរឈ្មោះឱ្យទៅកូនបំណុលវិញ ដែលជាម្ចាស់ដី ព្រមទាំងមិនទាមទារលុយដែលជំពាក់ ដោយឡែកមន្ត្រីដែលពាក់ព័ន្ធនឹងការចេញប័ណ្ណនេះ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំងស្នើសុំត្រឹមតែអប់រំឱ្យមានការប្រុងប្រយ័ត្នខ្ពស់។

៥០.ឈ្មោះ ចយ ចាន់សុវត្ថិ និងប្រពន្ធឈ្មោះ ម៉ក់ ចន្ថា ឈ្មោះ យ៉ង់ ហួន ឈ្មោះ យ៉ង់ វង់ និងប្រពន្ធឈ្មោះ ខុន សុខ និងឈ្មោះ ប៊ុន សារី ជាប្រជាពលរដ្ឋនៅខេត្តកំពង់ឆ្នាំង ប្តឹងសុំជួយដោះស្រាយករណីប៉ូលីសសេដ្ឋកិច្ច និងមន្ត្រីជំនាញរដ្ឋបាលព្រៃឈើ បានចាប់ត្រាក់ទ័ររបស់ពួកគាត់ចំនួន៣គ្រឿង និងតែកុងចំនួន៣នាក់ ឃុំខ្លួនក្នុង ឃុំពន្ធនាគារខេត្តកំពង់ឆ្នាំង បានឈូសដីព្រៃមានរបងព័ទ្ធជុំវិញ ស្ថិតនៅភូមិទំនប់ថ្មី ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ករណីនេះក្រុមការងាររកឃើញថា៖

-ស្ថានភាពដី មិនមែនជាការឈូសឆាយដីថ្មីទេ គឺមានលក្ខណៈក្ទួរដីចាស់មានរបង និងខ្ទម លើផ្ទៃដីប្រហែល ២០ហិកតា ជាក់ស្តែងមិនមានព្រៃ ជាដីស្រែរបស់ប្រជាពលរដ្ឋកំពុងអាស្រ័យផល។

-បច្ចុប្បន្ននេះ ម្ចាស់ត្រាក់ទ័រ តៃកុងត្រាក់ទ័រ និងត្រាក់ទ័រ ត្រូវបានដោះលែងឱ្យមានសេរីភាពហើយ។

៥១.ឈ្មោះ ខេង បុរី នៅភូមិកែងតាសុខ ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ប្តឹងមេភូមិមេឃុំ និងឈ្មោះ វុធ វ៉ាន់ថៃ បានរួមគំនិតគ្នាដកហូតដីកម្មសិទ្ធិរបស់គាត់ ស្ថិតនៅភូមិកែងតាសុខ ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ករណីនេះក្រោមការសម្របសម្រួលរបស់ក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង ភាគីទាំងពីរព្រមបញ្ចប់ទំនាស់ ដោយភាគីដើមបណ្តឹងព្រមសងលុយដែលជំពាក់ទាំងដើម ទាំងការចំនួន១៨,៦៥៥ដុល្លារអាមេរិក ឱ្យទៅភាគីចុងបណ្តឹង ហើយភាគីចុងបណ្តឹងព្រមប្រគល់ប័ណ្ណកម្មសិទ្ធិឱ្យភាគីដើមបណ្តឹងវិញ។

៥២.ឈ្មោះ សុខ សារិទ្ធិ និងប្រពន្ធឈ្មោះ យន ចាន់ថន នៅភូមិកំពង់បឹង ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ វុធ វ៉ាន់ថៃ នៅភូមិ៧ ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង បានលក់ដីដែលបានទំនាស់ ធ្វើឱ្យគាត់មិនមានសិទ្ធិគ្រប់គ្រងលើដីដែលបានទិញ ហើយឈ្មោះ វុធ វ៉ាន់ថៃ មានចេតនាគេចវេះ មិនទទួលខុសត្រូវក្នុងការដោះស្រាយ ករណីនេះក្រោមការសម្របសម្រួលរបស់ក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង ភាគីទាំងពីរព្រមបញ្ចប់ទំនាស់ ដោយភាគីដើមបណ្តឹងយល់ព្រមទទួលយកលុយពីភាគីចុងបណ្តឹងចំនួន៣១,២៨០ដុល្លារអាមេរិក និងព្រមប្រគល់ដីឱ្យភាគីចុងបណ្តឹងវិញដើម្បីប្រគល់ជូនទៅម្ចាស់ដីដើម។

៥៣.ប្រជាពលរដ្ឋចំនួនជាង១០០គ្រួសារ នៅឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្តឹងក្រុមហ៊ុនមួយបានជីកយកអាចម៍ដីលើដីស្រែប្រាំង និងដីដាំឈូក ព្រមទាំងលុបប្រឡាយទឹក ធ្វើឱ្យប៉ះពាល់ចរន្តផ្លូវទឹកដែលពួកគាត់យកទៅស្រោចស្រពដំណាំ ស្ថិតនៅចំណុចបឹងកន្លែងឆ្មោរ បឹងកន្លែងរមាស និងបឹងសន្ទួស ក្នុងភូមិកំពង់ក្តារ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ ករណីនេះក្រុមការងាររកឃើញថា៖

-ក្រុមហ៊ុនមិនបានលុបបឹង និងប្រឡាយទឹកទេ គ្រាន់តែជីកស្តារបឹងឱ្យជ្រៅស្តុបទឹកឱ្យបានច្រើនជាងមុន និងពង្រីកប្រឡាយបន្ថែម ដើម្បីបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋតាមការបញ្ជាក់ពីមន្ទីរជំនាញ និងតំណាងក្រុមហ៊ុន។

-ចំពោះប្រជាពលរដ្ឋចំនួន៤គ្រួសារ ដែលរងផលប៉ះពាល់ដោយការជីកយកអាចម៍ដីត្រូវតែបានសំណង ពីក្រុមហ៊ុន។ ភាគីក្រុមហ៊ុនបានដោះស្រាយប្រគល់លុយសំណងគ្រប់ចំនួនរួចរាល់ហើយ។

-ក្រុមហ៊ុនបានប្រមូលទិញដីពីប្រជាពលរដ្ឋក្នុងតំបន់នោះ ដើម្បីអភិវឌ្ឍន៍ជាវារីវប្បកម្ម(ចិញ្ចឹមត្រី) ក្នុងគោលបំណងលើកកម្ពស់វិស័យជលផល ក្នុងខេត្តកំពង់ឆ្នាំង ឱ្យមានការរីកចម្រើន ឆ្លើយតបតាមតម្រូវការផ្គត់ផ្គង់ការហូបចុកក្នុងស្រុក និងនាំចេញបាន។

-ការបោះបង្គោលព្រំកំណត់ផ្ទៃបឹង ដោយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីជំនាញ ពុំសូវមានតម្លាភាពព្រោះប្រជាពលរដ្ឋដែលបានលក់ដីឱ្យក្រុមហ៊ុនមិនជាប់ផ្ទៃដីចំណីបឹង ចំណែកប្រជាពលរដ្ឋដែលមិនបានលក់ឱ្យក្រុមហ៊ុនបែរជាជាប់ដីចំណីបឹង បើពិនិត្យមើលស្ថានភាពដីមានលក្ខណៈដូចៗគ្នា។

៥៤.ប្រជាពលរដ្ឋចំនួន៦គ្រួសារ នៅភូមិត្រពាំងផ្គាំ ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ប្តឹងតវ៉ាដោយចោទប្រកាន់មេភូមិត្រពាំងផ្គាំ បានដកហូតដីដែលពួកគាត់ បានកាន់កាប់អាស្រ័យផលជាង២០ឆ្នាំមកហើយ ដើម្បីយកទៅបែងចែកឱ្យទៅប្រជាពលរដ្ឋដទៃក្នុងភូមិទៅវិញ ករណីនេះក្រុមការងាររកឃើញថា៖

-តាមការបំភ្លឺរបស់មេភូមិត្រពាំងផ្គាំ កន្លងមកគាត់បានស្នើសុំប្រជាពលរដ្ឋដែលបានកាន់កាប់ដីទំហំធំជាច្រើនគ្រួសារ ចែករំលែកដីខ្លះឱ្យទៅប្រជាពលរដ្ឋដែលអត់មានដី តាមរយៈមេភូមិ ក្នុងនោះប្រជាពលរដ្ឋចំនួន៥០គ្រួសារ បានយល់ព្រមមានតែ៦គ្រួសារទេ ដែលមិនយល់ព្រមទើបមានការតវ៉ា។

-បច្ចុប្បន្នប្រជាពលរដ្ឋចំនួន៥០គ្រួសារ ទទួលការបែងចែកដី និងវាស់វែងចេញប័ណ្ណរួចហើយ ចំណែកប្រជាពលរដ្ឋចំនួន៦គ្រួសារ មិនតម្រូវឱ្យបែងចែកដីឡើងវិញទេ ដាក់ស្តែងគាត់កាន់កាប់ប៉ុណ្ណា ឱ្យគាត់បន្តកាន់កាប់ដីប៉ុណ្ណឹងទៅ (តាមការលើកឡើងរបស់អាជ្ញាធរឃុំ និងស្រុក)។

-មកដល់ពេលនេះ ប្រជាពលរដ្ឋចំនួន៥គ្រួសារ ទទួលបានការវាស់វែងរួចហើយ ដើម្បីចេញប័ណ្ណដោយឡែក ចំនួន១គ្រួសារទៀតមិនទាន់បានវាស់វែងទេ រងចាំវគ្គក្រោយ ព្រោះគាត់មិនបានចូលរួម។

៥៥.ឈ្មោះ យឹម សុខា និងប្រពន្ធឈ្មោះ ហួត វណ្ណី នៅភូមិសំរោង សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំងប្តឹងឈ្មោះ ស៊ុយ ម៉ារ៉ាន់ នៅភូមិកណ្តាល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បានខ្ចីលុយគាត់ចំនួន១០,៥០០ដុល្លារអាមេរិក ក្រោយមកបុគ្គលនេះ មិនមានទំនួលខុសត្រូវ មានចេតនាទុច្ចរិត មិនព្រមសងលុយ និងមិនគោរពតាមកិច្ចសន្យា ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ករណីនេះក្រោមការសម្របសម្រួលរបស់ក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តកំពង់ឆ្នាំង ភាគីទាំងពីរបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ ដោយឈ្មោះ ស៊ុយ ម៉ារ៉ាន់ សងប្រាក់ឱ្យទៅឈ្មោះ យឹម សុខា និងប្រពន្ធឈ្មោះ ហួត វណ្ណី ក្នុងខែចំនួន១៥០ដុល្លារអាមេរិក។

៥៦.ឈ្មោះ សូ សំណាង ប្តឹងស្នើសុំធ្វើប័ណ្ណទុតិយតាចំនួន១២ប័ណ្ណ(ដែលបានជ្រុះបាត់) ស្ថិតនៅភូមិដំណាក់អំពិល ឃុំកុលសែនជ័យ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ករណីនេះឈ្មោះ សូ សំណាង បានទទួលប័ណ្ណទុតិយតា រួចហើយ ចំពោះទំនាស់ជាមួយប្រជាពលរដ្ឋនឹងដោះស្រាយតាមផ្លូវច្បាប់។

៥៧. ករណីពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន៤២គ្រួសារ រស់នៅភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្ត កំពត ប្តឹងឈ្មោះ គឹម ចាន់ ឈ្មោះ យ៉ែម ឈឿន និងឈ្មោះ យូ ស៊ីឈាន ដែលជាមេក្លោងកែនប្រជាពលរដ្ឋចំនួន៧៩គ្រួសារ ក្នុងចំណោមចំនួន២២៦គ្រួសារ មកពីភូមិវាលក្រសាំង ឃុំតាកែន និងភូមិតេជោអង្គាញ់ ឃុំតេជោអភិវឌ្ឍន៍ និងភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត មករុករានយកដីរបស់ពួកគាត់ដែលបានអាស្រ័យផលកន្លងមកមានទំហំ២៧៨ហិកតា ស្ថិតនៅចំនុចថ្មងោក និងវាលឥន្ទ្រី ក្នុងភូមិព្រៃពាយ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត។ **ករណីពាក្យបណ្តឹងនេះ** មន្ទីរទេរពអខេត្តកំពត បានចុះអង្កេតស្រាវជ្រាវជាមួយក្រុមការងារខេត្ត និងបានធ្វើរបាយការណ៍គោរពជូនខេត្តមួយជំហានរួចហើយ ប៉ុន្តែដោយសារការរាតត្បាតជំងឺកូវីដ១៩ ទើបមន្ទីរពន្យាពេល ដោយរងចាំនៅពេលចប់កូវីដ១៩ មន្ទីរ និងក្រុមការងារខេត្តនឹងធ្វើការសម្របសម្រួល (យុទ្ធសាស្ត្រឈ្នះ ឈ្នះទាំងអស់គ្នា) រវាងប្រជាពលរដ្ឋ៤២គ្រួសារ និងប្រជាពលរដ្ឋ៧៩គ្រួសារ ដើម្បីបញ្ចប់ទំនាស់តាមនីតិវិធី។

## ៤-សកម្មភាពការងារសវនកម្មផ្ទៃក្នុង

-ចុះតាមដានអនុសាសន៍របស់សវនករ ក្នុងការិយបរិច្ឆេទ២០១៨ នៅតាមបណ្តាសវនដ្ឋានចំនួន២មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ។

-ចុះធ្វើសវនកម្ម ក្នុងការិយបរិច្ឆេទ២០១៩ នៅតាមទីសវនដ្ឋានចំនួន២មន្ទីរ គឺមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

-ចូលរួមវគ្គបណ្តុះបណ្តាលអនឡាញលើគោលការណ៍ណែនាំស្តីពីសវនកម្មសមិទ្ធកម្ម សវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន ដែលរៀបចំឡើងដោយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចូលរួមក្នុងអង្គសិក្ខាសាលាស្តីពីការអភិវឌ្ឍដោយចីរភាពប្រចាំឆ្នាំ២០២០ និងលើកទិសដៅអនុវត្តឆ្នាំ២០២១ ដែលរៀបចំឡើងដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៅក្រសួងបរិស្ថាន។

-ផ្តល់អនុសាសន៍ ចែករំលែកបទពិសោធន៍ និងធ្វើការណែនាំដល់មន្ទីរទាំងអស់ ឱ្យអនុវត្តការងារបច្ចេកទេស ការដឹកនាំគ្រប់គ្រងមន្ត្រីរាជការ និងការងារហិរញ្ញវត្ថុជាពិសេសការចំណាយផ្សេងៗនៅក្នុងសាម៉ីមន្ទីរឱ្យបានត្រឹមត្រូវ មានលក្ខណៈសមស្រប អនុលោមទៅតាមច្បាប់ សារាចរណ៍ណែនាំផ្សេងៗ និងនីតិវិធីហិរញ្ញវត្ថុ តាមបណ្តាឆ្នាំនីមួយៗ។

-ការគ្រប់គ្រង និងប្រើប្រាស់សម្ភារ បរិក្ខាបច្ចេកទេស សង្ហារិម និងទ្រព្យសម្បត្តិរដ្ឋដទៃទៀត របស់មន្ទីរទាំងអស់មានលក្ខណៈល្អប្រសើរ ជាងបណ្តាឆ្នាំកន្លងមក។

-ការងារដឹកនាំ គ្រប់គ្រង និងការបែងចែកតួនាទីភារកិច្ចនៃការទទួលខុសត្រូវរបស់មន្ត្រីរាជការ នៅតាមបណ្តាមន្ទីរបានល្អប្រសើរ។

-ការគ្រប់គ្រង និងប្រើប្រាស់កញ្ចប់ថវិការបស់មន្ទីរនានាអនុវត្តបានត្រឹមត្រូវមានការសន្សំសំចៃ ហើយសម្រេចបានល្អប្រសើរ។

## ៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច

-រៀបចំសេចក្តីព្រាងបឋមនូវបទបញ្ជាផ្ទៃក្នុង វិធីសាស្ត្រជ្រើសរើសសិក្ខាកាម គ្រូឧទ្ទេស សាស្ត្រាចារ្យ និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

-លើកស្លាកសញ្ញាវិទ្យាស្ថាន និងបំពាក់ឧបករណ៍មូលដ្ឋាននៅសាលសិក្សា។

-កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន។

-ធ្វើស៊ីញ(និមិត្តសញ្ញាវិទ្យាស្ថាន) និងស្លាកឈ្មោះ សម្រាប់មន្ត្រីរាជការវិទ្យាស្ថាន។

-រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់វិទ្យាស្ថាន។

-ធ្វើផែនការសកម្មភាពឆ្នាំ២០២១ របស់វិទ្យាស្ថាន។

-រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចឆ្នាំ២០២១ របស់វិទ្យាស្ថាន។

-ពិនិត្យ និងកែសម្រួលសេចក្តីព្រាងអំពីកម្រិត និងប្រធានបទសម្រាប់ការបណ្តុះបណ្តាល។

-លើកសំណើដើម្បីប្រកាសជ្រើសរើសគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ចចំនួន៩រូប សម្រាប់វិទ្យាស្ថានជាតិអធិការកិច្ច។

-ចុះសិក្សាស្រាវជ្រាវអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ចនៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១២លើក។

-ទទួលមន្ត្រីរាជការចំនួន៥រូប (ស្ត្រីចំនួន២រូប) ក្នុងនោះស្នើសុំតាំងស៊ប់ចំនួន៤រូប។

-រៀបចំសេចក្តីព្រាងទម្រង់ចុះឈ្មោះចូលរៀនតាមប្រព័ន្ធអនឡាញ (Online)។
-រៀបំបំពាក់គ្រឿងសង្ហារិម ក្នុងបណ្ណាល័យវិទ្យាស្ថាន។
-ទំនាក់ទំនង និងទទួលសៀវភៅចម្រុះមុខវិជ្ជាសរុបចំនួន២០ក្បាល។
-ស្រាវជ្រាវ រៀបចំចងក្រងជាឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមឋានានុក្រម និងប្រភេទ។

## ៦.ការងារផ្សេងៗ

### ៦.១.សកម្មភាពការងារយេនឌ័រ

-ចាត់បញ្ជូនស្ត្រីចំនួន៣រូប ក្នុងក្រុមការងារបច្ចេកទេសយេនឌ័រចូលរួមស្តាប់សេចក្តីណែនាំផ្សព្វផ្សាយអំពីការដាក់ពាក្យប្រលងសុំអាហារូបករណ៍នៅប្រទេសអូស្ត្រាលី ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅក្រសួងកិច្ចការនារី។

-ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងបានរៀបចំពិធីអបអរសាទរខួបទី១០៩ ទិវាអន្តរជាតិនារី៨មីនា ក្រោមប្រធានបទ «មានសន្តិភាពមានការលើកកម្ពស់យេនឌ័រ» នៅទីស្តីការក្រសួង។

-ចូលរួមមីទ្ទីញរំលឹកថ្ងៃឆ្ពោះទៅផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យឈានទៅរំដោះជាតិទាំងស្រុងរបស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅភូមិកោះថ្ម ឃុំទន្លូង ស្រុកសន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។

-ចាត់បញ្ជូនមន្ត្រីជាស្ត្រីចំនួន២រូប ទៅបណ្តុះបណ្តាលស្តីពីស្ត្រីភាពជាអ្នកដឹកនាំ នៅសាលាភូមិន្ទរដ្ឋបាល។

-ចាត់បញ្ជូនមន្ត្រីជាស្ត្រីចំនួន៤រូប ទៅបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សឹង្ហបូរី។

-សម្របសម្រួលជាមួយមន្ទីរពេទ្យព្រះកេតុមាលាបញ្ជូនអ្នកជំងឺចំនួន៧នាក់ ទទួលការព្យាបាលតាមការចុះអនុស្សរណៈ យោគយល់ជាមួយគ្នា។

-ចាត់ប្រតិភូចុះសួរសុខទុក្ខស្ត្រីជាមន្ត្រីរាជការសម្រាលមាតុភាពចំនួន៧នាក់ និងប្រគល់ជូនថវិកាឧបត្ថម្ភរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ចំពោះស្ត្រីចំនួន៥០ម៉ឺនរៀល និងរបស់ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងម្នាក់២០ម៉ឺនរៀល បន្ថែមលើប្រាក់ឧបត្ថម្ភរបស់ក្រសួង។

-អមដំណើរលោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី ចុះចែកអំណោយជូនប្រជាជនដែលរងគ្រោះដោយទឹកជំនន់ចំនួន២លើក នៅខណ្ឌដង្កោ រាជធានីភ្នំពេញ ចុះសួរសុខទុក្ខអ្នកជំងឺនៅមន្ទីពេទ្យចំនួន៣លើក ចូលរួមពេលមានខ្យល់កន្ត្រាក់នៅខេត្តស្វាយរៀង ចូលរួមជួបប្រជាពលរដ្ឋនៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងចូលរួមពិធីបុណ្យសពចំនួន៣លើក។

-ចូលរួមជាមួយលោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ចែកថវិកា ស្បៀង និងម៉ាស ជូនមន្ត្រីរាជការមួយចំនួនក្នុងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

### ៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងបានរៀបចំបេសកកម្ម រួមមានប្រមែប្រមូលថវិកា និងគ្រឿងឧបភោគ បរិភោគដើម្បីចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយកងកម្លាំងជួរមុខវរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ និងវរសេនា

គួចនគរបាលការពារព្រំដែនគោកលេខ៨២៧ នៃគណៈបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគ៣។ តែដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ គម្រោងចុះសួរសុខទុក្ខត្រូវផ្អាក។

### ៦.៣. សមាគមសង្គហមិត្តភាព

សមាគមសង្គហមិត្តភាពរបស់ក្រសួងដែលបានបង្កើតនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧បានឧបត្ថម្ភថវិកាចំនួនមួយលានរៀលជូនឯកឧត្តម វ៉ាត ហេង ទីប្រឹក្សាក្រសួង ដើម្បីចូលបុណ្យសពភរិយាគាត់ លោកជំទាវ ឡេង សឿនដែលបានទទួលមរណភាព នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០។

### ៦.៤.សកម្មភាពក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

#### ៦.៤.១.សកម្មភាពការងារ

-រៀបចំកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាបន្តលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ដោយមានការចូលរួមពីតំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ និងសមាជិកក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការក្រសួងចំនួន៣លើក។

-រៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ដោយមានការចូលរួមពីអនុប្រធាន និងសមាជិក សមាជិកា នៃក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការក្រសួងចំនួន៣លើក។

-រៀបចំកិច្ចប្រជុំស្តីពីវឌ្ឍនភាពការងារ និងទិសដៅការងារបន្តរបស់ក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដោយមានការអញ្ជើញចូលរួមពីអនុប្រធាន និងសមាជិក សមាជិកា នៃក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចលើកទី៣ ទី៤ និងទី៥ ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន៣លើក ដោយបានការពារនូវបេសកកម្ម និងតួនាទីភារកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ចូលរួមការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន២លើក។

-រៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីមុខងារ ភារកិច្ច របស់សវនកម្ម និងអធិការកិច្ច នៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២លើក។

-រៀបចំប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងជំនួយស្មារតីសម្រាប់កិច្ចប្រជុំអន្តរក្រសួងចង្អៀតលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការក្រសួងចំនួន១១លើក។

-ដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចពិភាក្សាផ្លាស់ប្តូរបទពិសោធន៍លើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការងារអធិការកិច្ចជាមួយអគ្គអធិការកិច្ចរដ្ឋាភិបាល សាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីក្រុងហូជីមិញចំនួន១លើក។

#### ៦.៤.២.វឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច

-បញ្ចប់កិច្ចប្រជុំកម្រិតបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-រៀបចំកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន២លើក។

-រៀបចំកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅទីស្តីការក្រសួងចំនួន៣លើក។

**៦.៤.៣.វឌ្ឍនភាពរបស់តួនាទី ភារកិច្ចលើវិស័យអធិការកិច្ចរបស់ក្រសួង**

យោងតាមក្រឹត្យលេខ០៣អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងយោងតាមអនុក្រឹត្យលេខ១៦៨ អនក្រ.បក ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជាអធិការកិច្ចរបស់រាជរដ្ឋាភិបាល មានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់វិស័យ និងដោយផ្អែកលើអភិក្រមដូចខាងក្រោម៖

-តាមបណ្តឹងតវ៉ា និងបណ្តឹងបរិហារពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន។

-តាមបណ្តឹងស្ថាប័នរងអធិការកិច្ចលើលទ្ធផលអធិការកិច្ចរបស់ក្រសួង-ស្ថាប័ន។

-ផ្អែកលើហានិភ័យ បណ្តឹងតវ៉ា ឬភាពចាំបាច់ក្នុងការផ្ទៀតផ្ទាត់ព័ត៌មាន ឬរបាយការណ៍ពាក់ព័ន្ធ។

-តាមសំណើរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

-មានភាពមិនប្រក្រតីលើរបាយការណ៍លទ្ធផលអធិការកិច្ច។

-តាមដាននូវរាល់វិធានការដែលអធិការកិច្ចបានដាក់ចេញដល់ស្ថាប័នរងអធិការកិច្ច និងតាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

## ៦.៥.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

ស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួងចំនួន១៣២នាក់។

## ៦.៦.សកម្មភាពការងារអ្នកនាំពាក្យក្រសួង

-ចូលរួមតាមការអញ្ជើញរបស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដើម្បីធ្វើសន្និសីទសារព័ត៌មាន នៅទីស្តីការគណៈរដ្ឋមន្ត្រីដែលជាឱកាសឱ្យអ្នកនាំពាក្យបានផ្សព្វផ្សាយពីប្រវត្តិរបស់ក្រសួង តួនាទីភារកិច្ច និងវឌ្ឍនភាពការងារឆ្នាំ២០១៩ និងទិសដៅភារកិច្ចឆ្នាំ២០២០ ក្រោមការដឹកនាំរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។ សន្និសីទនេះធ្វើឡើងដោយមានការគាំទ្រ និងសម្របសម្រួលពីឯកឧត្តម ផៃ ស៊ីផាន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងមានការផ្សាយផ្ទាល់តាមរយៈផេកហ្វេសប៊ុករបស់អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា អង្គភាពសារព័មានFreshNews និងបណ្តាញសារព័ត៌មានទូរទស្សន៍ កាសែត វិទ្យុ និងទូរទស្សន៍ អនឡាញ ជាច្រើនទៀតផងដែរ។

-បញ្ជូនលទ្ធផលបច្ចុប្បន្នភាពនៃសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ រួមនឹងសកម្មភាពមន្ត្រីជំនាញ ទៅកាន់សាធារណៈជនបានដឹង តាមរយៈបណ្តាញសារព័ត៌មាន និងបណ្តាញសង្គម ដូចជាការធ្វើអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការដោះស្រាយបណ្តឹង ការអប់រំផ្សព្វផ្សាយច្បាប់ ការចូលរួមសម្របសម្រួលលើកិច្ចរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិនានា ជាមួយរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា។

-ប្រមូលទិន្នន័យដែលទាក់ទងនឹងសារជារណៈមតិ ដែលបានលើកឡើងពាក់ព័ន្ធនឹងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលផ្សព្វផ្សាយនៅតាមបណ្តាញសារព័ត៌មាន និងបណ្តាញសង្គមមកពិនិត្យ និងឆ្លើយតប។

**៦.៧.សកម្មភាពការងារគេហទំព័រ www.monasri.gov.kh និង MONASRI App**

**៦.៧.១.ការងារតាមដានការចុះផ្សាយព័ត៌មាននៅក្នុងទំព័រហ្វេសប៊ុក (Facebook Page)**

ក្រសួងបានផ្សព្វផ្សាយព័ត៌មានតាមប្រភពដូចខាងក្រោម៖

-ទំព័រហ្វេសប៊ុកផ្លូវការ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច Ministry of National Assembly Senate Relations and Inspection (https://www.facebook.com/monasri.gov.kh) ។

-ទំព័រហ្វេសប៊ុកផ្លូវការ របស់លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី Men Sam An Cambodia Deputy Prime Minister (https://www.facebook.com/Men-Sam-An-Cambodia-Deputy-Prime-Minister-123242678054443) ។

-ទំព័រហ្វេសប៊ុកផ្លូវការ របស់វិទ្យាស្ថានជាតិអធិការអធិការកិច្ច National Institute of Inspection (https://www.facebook.com/ វិទ្យាស្ថានជាតិអធិការកិច្ច National-Institute-of-Inspection-218426792294478)

**៦.៧.២.ការងារគ្រប់គ្រង Website និង MONASRI App**

ក្រសួងបានផ្សព្វផ្សាយព័ត៌មានបញ្ចូលព័ត៌មាន សេចក្តីជូនដំណឹង និងឯកសារផ្លូវការផ្សេងៗតាមប្រភពគេហទំព័រ ឬវិបសាយ ផ្លូវការរបស់ក្រសួង គឺ http://monasri.gov.kh/ ។

ក្រសួងក៏បានតម្លើងអែប (Application) សម្រាប់មើលព័ត៌មាន និងដាក់ពាក្យបណ្តឹងអនឡាញតាមរយៈ MONASRI App។

-ធ្វើការ backup ទិន្នន័យនៅក្នុង Website ទុកជាប្រចាំសប្តាហ៍ និងខែ។

-ត្រួតពិនិត្យផ្នែកបច្ចេកទេស ស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពរបស់ Website និង MONASRI App។

-កែសម្រួលមាតិកា ឬទម្រង់ Website ស្របទៅតាមតម្រូវការថ្នាក់ដឹកនាំ និងបច្ចេកវិទ្យាបច្ចុប្បន្ន។

-រៀបចំប្រព័ន្ធទទួលពាក្យបណ្តឹងតាមរយៈ Online។

-រៀបចំ និងស្នើសុំប្រើប្រាស់ប្រព័ន្ធអ៊ីម៉ែល ក្នុងវិធីសម្រាប់ឧបករណ៍ឆ្លាតវៃដាក់ដំណើរការក្នុងប្រព័ន្ធគេទំព័រ www.monasri.gov.kh លើម៉ាស៊ីនបង្ហោះគេហទំព័ររដ្ឋាភិបាល គ្រប់គ្រងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

-ផ្សព្វផ្សាយព័ត៌មានពី Website ទៅកាន់បណ្តាញផ្សព្វផ្សាយសង្គមដូចជា Facebook និង Telegram។

**៦.៧.៣.លទ្ធផលការងារ**

-ផ្សព្វផ្សាយព័ត៌មាន និងឯកសារផ្សេងៗ ក្នុង Website និង MONASRI App សរុបចំនួន : ៦១២

+លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ២៦៩។

+ថ្នាក់ដឹកនាំក្រសួង ៨៤។

+វិទ្យាស្ថានជាតិអធិការកិច្ច ៤៥។

+មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រាជធានី-ខេត្ត ១៦៥។

+លិខិតផ្សេងៗ ៤៩។

-ធ្វើបច្ចុប្បន្នភាព (Update) ក្នុងវិធីលើ

+ Website ៣ ដង។

+ MONASRI App ៤ ដង។

-អ្នកទាញយក MONASRI App ប្រើប្រាស់ក្នុងទូរស័ព្ទដៃ មានចំនួនៈ ២៧៧

+ Google Play Store ១៦៩។

+ App Store ១០៨។

# គ-បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

១.ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅមិនទាន់អនុម័តនៅឡើយ។

២.ការដោះស្រាយថវិកា និងប្រេងឥន្ធនៈសម្រាប់បេសកកម្ម នៅមានការខ្វះខាត និងយឺតយ៉ាវ។

៣. កង្វះមធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យាសម្រាប់ចុះបេសកកម្មនៅមានកំរិត។

៤.សមត្ថភាពរបស់មន្ត្រីរាជការអធិការកិច្ចមួយចំនួនតូចនៅមានកម្រិត។

៥.ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

៦.កិច្ចសហការជាមួយអគ្គាធិការ អធិការតាមក្រសួង ស្ថាប័ន នៅមានកម្រិត។

៧.កិច្ចសហការរបស់ក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួន លើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារអង្កេតស្រាវជ្រាវពាក្យបណ្តឹងនៅមានកម្រិត។

៨. សម្ភារ បរិក្ខាមួយចំនួន នៅតាមនាយកដ្ឋាន ដូចជា តុ កៅអី ម៉ាស៊ីនថតចំលង ចាប់ផ្តើមខូចខាត និងចាស់ទ្រុឌទ្រោមជាបន្តបន្ទាប់។

៩. របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យឆ្លងប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ចចុះហត្ថលេខាយល់ព្រមលើលទ្ធផលអធិការកិច្ច។

១០. នៅមានភាពមិនច្បាស់លាស់ និងស្រពិចស្រពិលអំពីតួនាទីអធិការកិច្ច ជាពិសេសអធិការកិច្ចផ្អែកលើហានិភ័យក្រោយពីការចេញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដោយសារតួនាទីរបស់ក្រសួង ស្រដៀងគ្នានឹងស្ថាប័នមួយចំនួន ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គាធិការតាមក្រសួង ស្ថាប័ន។

១១. សូចនាករ វាស់វែងបាន នៅមានកំរិត ក្នុងលទ្ធផលការងារ។

១២. ថវិកាក្រសួង ជាពិសេសបេសកកម្ម និងខ្ទង់មួយចំនួនទៀតនៅមានកំរិត និងត្រូវកាត់បន្ថយ ដោយបញ្ហាកូវីដ-១៩។

១៣. វិន័យការងារ និងក្រមសីលធម៌របស់មន្ត្រីរាជការមួយចំនួននៅមានការខ្វះខាត។

១៤. ការងារដោះស្រាយពាក្យបណ្តឹង នៅមានភាពស្មុគ្រស្មាញ និងអូសបន្លាយ។

១៥. វិទ្យាស្ថានជាតិអធិការកិច្ចខ្វះគ្រូ និងឯកសារមេរៀនគោលដែលជាលក្ខណៈជាតិ។

១៦. ភារកិច្ច និងសកម្មភាពតាមផែន ឬនាយកដ្ឋានមួយចំនួន មិនសូវមានដំណើរការមមាញឹក។

# ឃ.ទិសដៅការងារឆ្នាំ ២០២១

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាពដូចខាងក្រោម៖

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាលសាធារណៈ ឱ្យស្របតាមតួនាទី ភារកិច្ចរបស់ក្រសួង និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១-២-ការងារបុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

### ១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-ត្រៀមទូទាត់លើការប្រើប្រាស់អគ្គិសនី ទឹក ទូរស័ព្ទ តាមវិក័យបត្រជាក់ស្តែង។

-បន្តពិនិត្យ និងចូលរួមយោបល់ទាក់ទងតម្រូវការចំណាយផ្សេងៗក្នុងក្រសួង។

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំខែ ឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំធានាចំណាយប្រេងឥន្ធនៈប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយសម្ភារថែទាំអគារ និងថែទាំសម្ភារឧបករណ៍ប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយសង្ហារឹម និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំនាយសម្ភារ និងឧបករណ៍ដឹកជញ្ជូនប្រចាំឆ្នា២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយការងារជួសជុលលាបថ្នាំបន្ទប់អគារទីស្តីការ ក្រសួង (ABC) និងជួសជុលស្ថាបនាអគារឱ្យសន្តិសុខស្នាក់នៅប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយការងារជួសជុល និងមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំ២០២១។

-ត្រៀមបែងចែកប្រេងឥន្ធនៈ ដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

-ត្រៀមរៀបចំបែងចែកសម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់សំណើផ្សេងៗជូនថ្នាក់ដឹកនាំគ្រប់នាយកដ្ឋាន។

-ត្រៀមបែងចែកសម្ភារអនាម័យតាមបណ្តានាយកដ្ឋាន។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

-ត្រៀមរៀបចំបែងចែកទឹកបរិសុទ្ធសម្រាប់ប្រជុំជូនថ្នាក់ដឹកនាំ និងតាមនាយកដ្ឋាន។

-ត្រៀមរៀបចំការងារជួសជុលសម្ភារការិយាល័យ ជួសជុលអគារការិយាល័យគ្រឿងយន្ត និងបរិក្ខាបច្ចេកទេសក្នុងទីស្តីការក្រសួង។

### ១-៤-ការងារផែនការ និងស្ថិតិ

-រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី១ ២០១៨-២០២០ និងផ្តល់ធាតុចូលលើផែនការដំណាក់កាលទី២ ២០២១-២០២៥ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយជាតិស្តីពីមនុស្សចាស់២០១៧-២០៣០។

-បន្តរៀបចំសម្របសម្រួលលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តរៀបចំផែនការថវិកាឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ចុះណែនាំការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តបញ្ចូលទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ និងពិនិត្យឡើងវិញជាបណ្តើរៗ។

-ពិនិត្យតាមដាន និងវាយតម្លៃលើប្រតិទិនការងារសម្រាប់ការិយាល័យដើម្បីអនុវត្តឆ្នាំ២០២១។

-រៀបចំតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលលើការងារកសាងផែនការឱ្យកាន់តែមានប្រសិទ្ធភាព។

-រៀបចំរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-កំពុងបន្តរៀបចំគម្រោងផែនការថវិកាឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-រៀបចំកែសម្រួលនូវទម្រង់បែបបទសកម្មភាពការងារនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២០។

-រៀបចំរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តកម្មវិធីឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

### ១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្តាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២-១-ការងារនីតិកម្ម

-ចូលរួមសិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង។

-បន្តកសាងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

-បន្តបញ្ចូលច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ចុះស្ទង់មតិប្រជាពលរដ្ឋពាក់ព័ន្ធនឹងការយល់ដឹងផ្នែកច្បាប់ នៅតាមបណ្តាខេត្តគោលដៅ។

### ២-២-ការងារអប់រំផ្សព្វផ្សាយច្បាប់

-រៀបចំឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ផ្គត់ផ្គង់ការផ្សព្វផ្សាយច្បាប់។

-សិក្សាស្រាវជ្រាវឯកសារ ឬលិខិតបទដ្ឋានពាក់ព័ន្ធនឹងច្បាប់។

-ចុះផ្សព្វផ្សាយច្បាប់នៅតាមបណ្តាខេត្តគោលដៅ ដែលបានកំណត់ក្នុងផែនការ។

-ចុះសិក្សាស្រាវជ្រាវមុន និងក្រោយការផ្សព្វផ្សាយច្បាប់។

### ២-៣-ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា

-ចូលរួមប្រជុំអន្តរក្រសួង និងតាមក្រសួង-ស្ថាប័ន។

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គ និងវិសាមញ្ញ នៅរដ្ឋសភា និងនៅព្រឹទ្ធសភា។

-ចុះអមដំណើរសមាជិកព្រឹទ្ធសភា និងរដ្ឋសភា តាមភូមិភាគ និងមណ្ឌលរាជធានី-ខេត្ត។

-សិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារវេទិកាសាធារណៈ។

-ចុះរៀបចំវេទិកាសាធារណៈ នៅតាមបណ្តាខេត្តគោលដៅ។

## ៣.ការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ច( វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច )

-បន្តអនុវត្តការងារអធិការកិច្ចដែលពុំទាន់បានបញ្ចប់ក្នុងឆ្នាំ២០២០។

-រៀបចំ និងកែសម្រួលផែនការប្រតិបត្តិអធិការកិច្ច ឱ្យស្របតាមស្ថានភាពការងារជាក់ស្តែង។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២១។

-ប្រមូលចងក្រងឯកសារគតិយុត្តទាំងឡាយដែលមានប្រយោជន៍ដល់ការងារអធិការកិច្ច។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.២.ការងារតាមដានការអនុវត្តច្បាប់

-បន្តចុះតាមដានត្រួតពិនិត្យរាល់ការអនុវត្តច្បាប់ អនុក្រឹត្យ សារាចរណែនាំ សេចក្តីជូនដំណឹង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី។

-ត្រៀមរៀបចំសេចក្តីជូនដំណឹង ស្តីពីការជំរុញកែលម្អលើចំណុចខ្វះខាតទៅបណ្តាក្រសួង-ស្ថាប័ន។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២១។

-ប្រមូលចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ចុះការងារតាមដាន។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

-បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២១។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

-បន្តចុះអង្កេតស្រាវជ្រាវ និងដោះស្រាយបណ្តឹងដែលនៅសេសសល់ឆ្នាំ២០២០។

## ៤.ការងារសវនកម្មផ្ទៃក្នុង

-បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

### ៥.១.ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ

៥.១.១. អភិវឌ្ឍ និងពង្រឹងសមត្ថភាពស្ថាប័ន

-រៀបចំបញ្ចប់នូវបទបញ្ញាផ្ទៃក្នុង រៀបចំវិធីសាស្ត្រនៃការជ្រើសរើសសិក្ខាកាម គ្រូឧទ្ទេស សាស្ត្រាចារ្យ និងយន្តការ តាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់វិទ្យាស្ថាន។

-កែលម្អរចនាសម្ព័ន្ធគ្រប់គ្រង និងរបៀបរបបបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។

-ពង្រឹងសមត្ថភាពមន្ត្រីរាជការវិទ្យាស្ថានទៅលើមុខជំនាញពាក់ព័ន្ធ។

-ស្នើសុំបង្កើតក្រុមគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ចសម្រាប់វិទ្យាស្ថាន។

### ៥.១.២. ពង្រឹងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក និង ហិរញ្ញវត្ថុ

-ស្នើសុំបង្កើតអង្គភាពថវិកាវិទ្យាស្ថានជាតិអធិការកិច្ចដើម្បីសម្រួល និងពន្លឿនចរន្តការងារឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

-ពង្រឹងការគ្រប់គ្រងចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារ បរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន។

-ពង្រឹងការគ្រប់គ្រងបុគ្គលិក ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភរបស់សាស្ត្រាចារ្យ និងគ្រូ។

-ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

## ៥.២. ការងារផែនការ និងស្រាវជ្រាវ

### ៥.២.១. ពង្រឹងការគ្រប់គ្រងផែនការ

-ធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់វិទ្យាស្ថាន។

-រៀបចំកែលម្អផែនការសកម្មភាពរបស់វិទ្យាស្ថាន។

-រៀបចំកែលម្អផែនការថវិការបស់វិទ្យាស្ថាន។

-បកប្រែឯកសារសំខាន់ៗពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

### ៥.២.២. ពង្រឹងការគ្រប់គ្រងការសិក្សាស្រាវជ្រាវ

-ស្រាវជ្រាវ និងប្រមូលផ្តុំឯកសារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-តាមដានអំពីវឌ្ឍនភាព និងប្រសិទ្ធភាពការងារមន្ត្រីរាជការដែលទទួលបានទទួលការ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច។

-ស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារធិការកិច្ច។

## ៥.៣. ការងារបណ្តុះបណ្តាល

-ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចដល់មន្ត្រីរាជការក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួង ស្ថាប័ននានា។

-រៀបចំកែលម្អកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចសម្រាប់ឆ្នាំ២០២២។

## ៥.៤. ការងារទំនាក់ទំនងសាធារណៈ

### ៥.៤.១. ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថានទូតនានា។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា។

### ៥.៤.២. ពង្រឹងការគ្រប់គ្រងព័ត៌មានវិទ្យា និងបណ្ណាល័យ

-បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថាន។

-រៀបចំ និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបណ្ណាល័យ។

-រៀបចំបង្កើតពេងពុម្ព និងបោះពុម្ពឯកសារ។

## ៦.ការងារផ្សេងៗ

### ៦.១.ការងារយេនឌ័រ

-ក្រុមការងារបញ្ជ្រាបយេនឌ័រសំដៅលើកកម្ពស់សមត្ថភាពផ្នែកបទដ្ឋានគតិយុត្តិ ផ្សព្វផ្សាយច្បាប់ចរាចរណ៍ ណែនាំ និងអនុសាសន៍សំខាន់ៗរបស់ថ្នាក់ដឹកនាំ។

-រៀបចំកែសម្រួល និងអនុវត្តផែនការយុទ្ធសាស្ត្រ បញ្ជ្រាបយេនឌ័រតាមវិស័យ ក្នុងការចូលរួមធ្វើអធិការកិច្ច រៀនសូត្របន្ថែមការងារជំនាញនីមួយៗសំដៅឆ្លើយតបនឹងសេចក្តីត្រូវការចំពោះមុខ។

-រៀបចំផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោង និងគោលនយោបាយតាមវិស័យ រួមទាំងលិខិតបទដ្ឋាននានា ដែលឆ្លើយតបនឹងយេនឌ័រ។

-រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ស្ថាប័ន និងបញ្ជ្រាបយេនឌ័រតាមវិស័យ។

-ចលនាស្ត្រីក្នុងការងារលើកកម្ពស់សមត្ថភាពសីលធម៌ និងភាពអង់អាចដល់ស្ត្រីក្នុងក្រសួង ស្ថាប័ន និងអង្គភាពជុំវិញក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច មានលក្ខណៈជាអ្នកដឹកនាំដើម្បីឆ្លើយតបនឹងរបាយការណ៍វេទិកាសេដ្ឋកិច្ចពិភពលោកចំណាត់ថ្នាក់លេខ៨៩ លើប្រទេសចំនួន១៥៣ ក្នុងឆ្នាំ២០១៨។ ដោយឡែក ក្រុមការងារក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានរៀបចំផែនការសកម្មភាពជាប្រចាំទទួលបាននូវថវិកាគាំទ្រ ស្មារតីឧបត្ថម្ភគាំទ្រពីថ្នាក់ដឹកនាំ ធ្វើឱ្យក្រុមការងារសម្រេចបានការងារអនុវត្តន៍ជាប្រចាំ តាមការណែនាំរបស់ក្រសួងកិច្ចការនារី និងផែនការអភិវឌ្ឍន៍ជាតិអនុលោមតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ៦.២.ការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាពជាមួយកងវរសេនាតូចនគរបាលព្រំដែន ដែលឈរជើងនៅខេត្តកោះកុងទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ ក្នុងន័យផ្តល់កម្លាំងចិត្ត និងសម្ភារដើម្បីបង្កើន ជីវភាពរស់នៅ របស់គាត់ឱ្យកាន់តែមានភាពប្រសើរឡើង និងដើម្បីរួមចំណែកថែរក្សាការពារទឹកដីរបស់យើងឱ្យមានសុខសន្តិភាពយូរអង្វែងតរៀងទៅ។

### ៦.៣.ការងារសមាគមសង្គហមិត្តភាព

-បន្តទទួលសមាជិក សមាជិកាថ្មី ក្នុងសមាគមសង្គហមិត្តភាពក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-បន្តទទួលថវិកាពីសមាជិក សមាជិកា ដើម្បីយកមកដំណើរការសមាគមសង្គហមិត្តភាពក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

### ៦.៤.ការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-បន្តប្រជុំ ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅគ្រប់ដំណាក់កាល។

-បន្តរៀបចំគ្រប់លិខិតបទដ្ឋានគតិយុត្តដែលថ្នាក់ដឹកនាំប្រគល់ជូន។

-ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តជាអាទិភាពដែលបានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

-ត្រៀមចូលរួមប្រជុំជាមួយបណ្តាក្រសួង ស្ថាប័ន តាមការចាត់តែងរបស់ថ្នាក់ដឹកនាំក្រសួង ដើម្បីការពារនូវតួនាទី ភារកិច្ចរបស់ក្រសួង។

**៦.៥.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង**

បន្តស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួង។

**៦.៦.ការងារអ្នកនាំពាក្យក្រសួង**

-ក្រុមអ្នកនាំពាក្យ បន្តបង្កើនប្រសិទ្ធិភាព ក្នុងកិច្ចការងារគ្រប់គ្រងសាធារណៈមតិ ដើម្បីការពារភាពត្រឹមត្រូវរបស់ថ្នាក់ដឹកនាំ និងស្ថាប័ន តាមរយៈនៃការបញ្ចេញព័ត៌មានពិត បន្សាបព័ត៌មានក្លែងក្លាយដែលមានចរិកធ្វើឱ្យប៉ះពាល់កិត្តិយសថ្នាក់ដឹកនាំ និងស្ថាប័ន។

-បង្កើនការតាមដានសាធារណៈមតិ ដែលបានលើកឡើងនៅលើបណ្តាញសារព័ត៌មាន ឬបណ្តាញសង្គម ដែលពាក់ព័ន្ធនឹងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំ និងអង្គភាពជំនាញពិនិត្យនឹងឆ្លើយតបបានទាន់ពេលវេលា។

-បង្កើនប្រសិទ្ធភាពនៃការបញ្ចេញព័ត៌មានពិត លឿន ខ្លី ខ្លឹម ស្តីពីសកម្មភាពរួមនឹងលទ្ធផលការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ព្រមទាំងតួនាទីភារកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ទៅកាន់សាធារណៈជនបានជ្រាប និងយល់ដឹង។

**៦.៧.ការងារគេហទំព័រ** MONASRI.GOV.KH **និង** MONASRI App

-ធ្វើការតាមដានការចុះផ្សាយព័ត៌មាននៅក្នុងទំព័រហ្វេសប៊ុកសំខាន់ទាំង៣ ដើម្បីបញ្ចូលក្នុង Website ឱ្យបានទាន់ពេលវេលា។

-ធ្វើការ backup ទិន្នន័យនៅក្នុង Website ជាប្រចាំ ដើម្បីរក្សាទុករាល់ទិន្នន័យដែលមានកន្លងមកឱ្យមានសុវត្ថិភាព។

-បាន និងកំពុងរៀបចំទម្រង់ Website របស់មួយទៀតជាភាសាអង់គ្លេស។

-ពិភាក្សា និងសម្របសម្រួលផ្នែកបច្ចេកទេសជាមួយក្រុមការងាររបស់វិទ្យាស្ថានជាតិអធិការកិច្ច ដើម្បីរៀបចំ Website របស់វិទ្យាស្ថានជាតិអធិការកិច្ច។

-បន្តសិក្សាស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពរបស់ Website និង MONASRI App ឱ្យកាន់តែរឹងមាំ។

# ខ-សេចក្តីសន្និដ្ឋាន

ក្រសួងបានបំពេញភារកិច្ច ប្រកបដោយទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព និងជោគជ័យ ទោះជាការងារខ្លះមានការលំបាក ស្មុគស្មាញមានភាពរសើប និងភាពចម្រូងចម្រាស់ក្តី។ សមិទ្ធផលការងារ ដូចបានរៀបរាប់ខាងដើមបានមកដោយសារមានការដឹកនាំ និងការតម្រង់ទិសប្រកបដោយបញ្ញាញាណដ៏ភ្លឺស្វាង និងវាងវៃ របស់លោកជំទាវកិត្តិសង្គហបណ្ឌិតឧបរដ្ឋមន្ត្រី និងដោយសារ ការប្រឹងប្រែងអនុវត្ត ការបំពេញការងារប្រកបដោយសមត្ថភាពពេញលេញ និងជំនាញច្បាស់លាស់ ការយល់ដឹងផ្នែកច្បាប់ និងក្រមសីលធម៌ស្អាតស្អំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ។

ជាការពិត បុគ្គល និងស្ថាប័នមួយចំនួនមិនចូលចិត្ត មិនសប្បាយចិត្ត និងមិនផ្តល់កិច្ចសហការពេញលេញដល់ក្រុមការងារក្រសួង ជាពិសេសក្រុមការងារអធិការកិច្ច ដែលត្រូវចុះទៅបំពេញបេសកកម្ម នៅតាមស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រោះគេខ្លាចយើងរកឃើញកំហុសឆ្គងនានា ដែលនាំមកនៅបញ្ហាផ្សេងដល់ពួកគាត់។ ទន្ទឹមនឹងនេះ ក្រសួងនៅមានបញ្ហាប្រឈមជាច្រើន ដូចជានៅតាមស្ថាប័នរដ្ឋមួយចំនួន មិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ និងមានក្រសួង ស្ថាប័នរដ្ឋមួយចំនួន មានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នាដូចជាគណៈកម្មាធិការដោះស្រាយទំនាស់ដីធ្លី អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ និងអគ្គាធិការដ្ឋាននៃក្រសួងស្ថាប័នមួយចំនួនទៀត។ ម្យ៉ាងទៀតការអនុវត្តក្រមសីលធម៌របស់ក្រុមការងារចុះបំពេញបេសកកម្មអធិការកិច្ច ក៏នៅមានការខ្វះខាត និងជួបបញ្ហាខ្លះ។

ទោះជាយ៉ាងនេះក្តី ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅតាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើង ពិតជាជួយធានាការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាពនិងសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅជាដើម។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានតម្រង់ទិស និងណែនាំឱ្យក្រសួង ស្ថាប័ន និងអង្គភាពរដ្ឋ បង្កើនការប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ ក្នុងសកម្មភាពការងាររបស់ខ្លួន ស្របតាមការកែទម្រង់ ស៊ីជម្រៅ ការពង្រឹងនីតិរដ្ឋ និងអភិបាលកិច្ចល្អ។ ដូច្នេះការងារអធិការកិច្ច ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន ដើម្បីបម្រើឱ្យផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋយើង ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ទទួលបានសុខសន្តិភាពយ៉ាងពិតប្រាកដ និងការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រមុខ។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានធ្វើឱ្យតួនាទីភារកិច្ចការទទួលខុសត្រូវរបស់ក្រសួងមានសារៈសំខាន់ និងរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើគឺដោយសារមានការគាំទ្រ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទទាំងអស់។

លើសពីនេះក្រសួងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងជោគជ័យ អាស្រ័យដោយមានការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដែលតែងតែគាំទ្រវាល់សកម្មភាពការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវខ្ពស់ ក៏ដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋស្ថាប័នមិនមែនរដ្ឋ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

យើងសង្ឃឹមថា ក្នុងឆ្នាំ២០២១ ខាងមុខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមានូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

# ឧបសម្ព័ន្ធ ១. កម្មវិធីសន្និបាត

**កម្មវិធីបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និង ទិសដៅការងារ ឆ្នាំ២០២១**
**របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

ថ្ងៃអង្គារ៍ ៥រោច ខែមាឃ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹង ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១
ភោជនីយដ្ឋានទន្លេបាសាក់២ (លេខ ៥៣៤ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ)

| **ម៉ោង** | **កម្មវិធី** | **គណៈអធិបតី/ថ្នាក់ដឹកនាំ** |
|---|---|---|
| **ពេលព្រឹក** | | |
| ៧.៣០ - ៨.១៥ | សមាជិក សមាជិកា សន្និបាតមកដល់ និងចុះឈ្មោះ | |
| ៨.១៥ - ៨.៣០ | គណៈអធិបតីអញ្ជើញដល់ | |
| ៨.៣០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| **ពិធីបើកសន្និបាត** | | |
| ៨.៣០ - ៩.៣០ | - ប្រកាសហេតុ<br>- គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា<br>- សុន្ទរកថាបើកសន្និបាតដោយ**លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី<br>- អានរបាយការណ៍សង្ខេបស្តីពីលទ្ធផលការងារ ឆ្នាំ ២០២០និងទិសដៅការងារឆ្នាំ២០២១ ក្រសួងទរពអ ដោយ**ឯកឧត្តម ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ៩.៣០ - ៩.៤៥ | សម្រាក ពិសាភេសជ្ជៈ និងអាហារសម្រន់ | |
| **ដំណើរការសន្និបាតដឹកនាំដោយលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** | | |
| ៩.៤៥ - ១១.០០ | ចំណាប់អារម្មណ៍ ពីមន្ទីរទរពអ រាជធានី ខេត្ត | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១១.០០- ១១.៣០ | -របាយការណ៍លទ្ធផលការងារ និងទិសដៅ វិទ្យាស្ថានជាតិអធិការកិច្ចដោយបណ្ឌិត **សោម ប៊ូរ៉ាន់** នាយកវិទ្យាស្ថានជាតិអធិការកិច្ច<br>-ពិភាក្សាលើរបាយការណ៍ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១១.៣០- ១៣.៣០ | សម្រាកអាហារថ្ងៃត្រង់ Buffet នៅភោជនីយដ្ឋានទន្លេបាសាក់២ | |

| ម៉ោង | កម្មវិធី | គណៈអធិបតី/ថ្នាក់ដឹកនាំ |
|---|---|---|
| **ពេលរសៀល** | | |
| ១៣.៣០- ១៤.០០ | - បទអន្តរាគមន៍ របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ<br>- ពិភាក្សាលើបទអន្តរាគមន៍ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៤.០០- ១៤.៣០ | - បទអន្តរាគមន៍របស់អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា<br>- ពិភាក្សាលើបទអន្តរាគមន៍ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៤:៣០ - ១៥.០០ | - បទអន្តរាគមន៍របស់អគ្គនាយកដ្ឋានអធិការកិច្ច<br>- ពិភាក្សាលើបទអន្តរាគមន៍ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៥.០០ - ១៥.២០ | -របាយការណ៍លទ្ធផលការងារ និងទិសដៅលើការតាក់តែងច្បាប់ដោយលោកជំទាវ**សុខ វិឡាយ** រដ្ឋលេខាធិការ<br>-ពិភាក្សាលើរបាយការណ៍ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៥.២០ - ១៥.៤០ | សម្រាក ពិសាភេសជ្ជៈនិងអាហារសម្រន់ | |
| | **ពិធីបិទសន្និបាត** | |
| ១៥.៤០ | លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ អញ្ជើញដល់ | |
| ១៥.៤០-១៦.០០ | - របាយការណ៍បូកសរុបលទ្ធផលសន្និបាតដោយ ឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៦.០០- ១៦.៣០ | -សុន្ទរកថាបិទសន្និបាតដោយ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ | -លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទរពអ<br>-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ |
| ១៦.៣០ | -គោរពភ្លេងជាតិបិទកម្មវិធី។ | |

***កំណត់សំគាល់៖***

១) គណៈកម្មាធិការរៀបចំសន្និបាតសូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់។

២) សម្លៀកបំពាក់៖ បុរស៖ អាវធំ ក្រវ៉ាត់ក នារី៖ ប្រពៃណី។

៣) សូមទាក់ទងទូរស័ព្ទ ឯកឧត្តម កឹម សុខជា៖ ០១៧៤៦៩៦៩៩ និង លោក ស្រ៊ុន សារ៉ន៖ ០៨៩៧២៩២៩២

# ឧបសម្ព័ន្ធ ២. របាយការណ៍សង្ខេប

## ស្តីពី
## ការបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១
## របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

*(អានដោយឯកឧត្តម **ឆេង សារឿន** រដ្ឋលេខាធិការប្រចាំការ)*

## ក-សេចក្តីផ្តើម

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលបានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការងារចំបង គឺការទំនាក់ទំនង សម្របសម្រួល រវាងរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា ការចូលរួមតាក់តែងសេចក្តីព្រាងច្បាប់ ការអប់រំផ្សព្វផ្សាយច្បាប់ ការទទួល និងដោះស្រាយពាក្យបណ្តឹង របស់ប្រជាពលរដ្ឋ ការតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងធ្វើអធិការកិច្ចលើគ្រប់វិស័យ សំដៅ បង្ការ ទប់ស្កាត់ កែលម្អ និងមានវិធានការ ដើម្បីប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា ដើម្បីពង្រឹងអភិបាលកិច្ចល្អ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងការពារសុវត្ថិភាពសាធារណៈ និងរួមចំណែកដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គម។

ក្នុងឆ្នាំ២០២០ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានសម្រេចនូវសមិទ្ធផលនានា ជាច្រើនដូចរៀបរាប់ខាងក្រោម៖

## ខ-សមិទ្ធផលការងារ

### ១-សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ

១-១-ការងាររដ្ឋបាល

-ទទួលលិខិតចូលពីក្រសួង-ស្ថាប័ននានាចំនួន៩០៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៨៩៤ច្បាប់។

-រៀបចំពិធីទទួលជួបសវនាការការងារជូនថ្នាក់ដឹកនាំក្រសួងជាមួយភ្ញៀវអន្តរជាតិនានា។

-រៀបចំប្រជុំតាមកម្មវិធីប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង នៅទីស្តីការក្រសួង។

-រៀបចំធ្វើសេចក្តីជូនដំណឹង លិខិតបង្គាប់ការ។

-រៀបចំបូកសរុបរបាយការណ៍របស់អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ និងរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស រយៈពេល៩ខែ និងប្រចាំឆ្នាំសម្រាប់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ។

-តាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធ Facebook page។

-ចូលរួមពិធីបុណ្យជាតិ-អន្តរជាតិ សន្និបាតបូកសរុបលទ្ធផលការងារ ពិធីមីទ្ទីញ សិក្ខាសាលា គោរពវិញ្ញាណក្ខន្ធ និងទទួល-ជូនដំណើរគណៈប្រតិភូជាន់ខ្ពស់បរទេសមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា។

-ចូលរួមប្រជុំនានា ចំនួន១១លើក។

**១.២.ការងារបុគ្គលិក និងធនធានមនុស្ស**

-ធ្វើសេចក្តីសម្រេច ១)ស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យរបស់ក្រសួង ២)ស្តីពីការបង្កើតលេខាធិការដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយប្រចាំក្រសួង ៣)ស្តីពីការបង្កើតគណៈកម្មាធិការតាំងស៊ប់បំពេញសិទ្ធិនៅក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការរបស់ក្រសួង និង ៤)ស្តីពីការបង្កើតគណៈកម្មការដំឡើងថ្នាក់ឋានន្តរស័ក្តិ ជូនមន្ត្រីរាជការស៊ីវិលប្រចាំឆ្នាំ២០២១ ។

-ធ្វើសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ឱ្យចូលបម្រើការងារនៅទីស្តីការក្រសួង និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២១។

-ទទួលប្រកាសរបស់ក្រសួងមុខងារសាធារណៈស្តីពីការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២៩៣រូប ប្រចាំឆ្នាំ២០២០។

-ធ្វើប្រកាសស្តីពីការតែងតាំង ចាត់តាំង និងការងារផ្សេងៗទាក់ទងនឹងបុគ្គលិក ចំនួន ១០ ប្រកាស។

**១.៣.ការងារបណ្តុះបណ្តាល**

-រៀបចំបណ្តុះបណ្តាលមន្ត្រីរាជការចំនួន២០រូបស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ នៅទីស្តីការក្រសួង។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន៤រូប ទៅបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ ដើម្បីការកែទម្រង់នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សឹង្ហបុរី។

-ចាត់បញ្ជូនមន្ត្រីរាជការចំនួន២រូប ទៅបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការអេឡិចត្រូនិកថ្មី(E passport) នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-ចាត់បញ្ជូនមន្ត្រីរាជការក្របខ័ណ្ឌឆ្នាំ២០១៩ ចំនួន៦រូប ទៅបណ្តុះបណ្តាលដំបូង នៅសាលាភូមិន្ទរដ្ឋបាល។

**១.៤.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

-ទូទាត់ឯកសារបេសកកម្មក្នុងក្រសួងជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការប្រចាំខែ។

-ទូទាត់រាជទេយ្យបុរេប្រទាន។

-ទូទាត់ចំណាយសន្និបាតបូកសរុបលទ្ធការងារឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តការងារបន្តឆ្នាំ២០២០របស់ក្រសួង។

-ទូទាត់ថ្លៃប្រើប្រាស់សេវានានា

-រៀបចំឯកសារស្នើសុំគោលការណ៍ជានាចំណាយនានា

-រៀបចំឯកសារទូទាត់ការចំណាយនានា

-រៀបចំឯកសារតារាងសរុបផែនការលទ្ធកម្មប្រចាំឆ្នាំ២០២០។

-រៀបចំឯកសារគម្រោងកម្មវិធីចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ២០២១។

-បែងចែកប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយរាល់បេសកកម្ម និងសំណើផ្សេងៗជូន ថ្នាក់ដឹកនាំនាយកដ្ឋានក្រោមឱវាទក្រសួង។

-ជួសជុលសម្ភារការិយាល័យ គ្រឿងយន្ត និងបរិក្ខាបច្ចេកទេសក្នុងទីស្តីការក្រសួង។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបណ្តាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-

ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

### ១.៥.ការងារផែនការ និងស្ថិតិ

-រៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២១-២០២៣ របស់ក្រសួង។

-រៀបចំគម្រោងផែនការថវិកាប្រចាំឆ្នាំ២០២០ ។

-ធ្វើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួង ។

-រៀបចំគម្រោងផែនការថវិកាសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-ធ្វើការរៀបចំបញ្ចូលទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងទៅតាមវិស័យរបស់ក្រសួង សម្រាប់ឆ្នាំ២០២០។

-បន្តរៀបចំបញ្ចូលទិន្នន័យតារាងរបាយការណ៍សមិទ្ធកម្មអនុវត្តថវិកាកម្មវិធី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ តាមអគ្គនាយកដ្ឋានទាំងបី និងតាមមន្ទីរ។

-ត្រៀមរៀបចំតារាងរបាយការណ៍សមិទ្ធកម្មអនុវត្តថវិកាកម្មវិធី សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

### ១.៦.ការងារសហប្រតិបត្តិការអន្តរជាតិ

-ចូលរួមទទួលគណៈប្រតិភូដែលបានមកជួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំក្រសួង ចំនួន៤លើក។

-សម្របសម្រួលលិខិត និងចូលរួមក្នុងកម្មវិធីបដិសណ្ឋារកិច្ចជូនគណៈប្រតិភូអធិការកិច្ចទីក្រុងហូជីមិញមកបំពេញទស្សនកិច្ចផ្លូវការ នៅកម្ពុជា កាលពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

-សម្របសម្រួលលិខិតស្តីពីដំណើរទស្សនកិច្ចការងារ របស់គណៈប្រតិភូជាន់ខ្ពស់ក្រសួង នៅវៀតណាម ពីថ្ងៃទី២៦ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពឥស្សរជនជាន់ខ្ពស់បរទេសចំនួន២លើក។

-ចាត់មន្ត្រីរាជការចំនួន២រូបចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការអេឡិចត្រូនិចថ្មី(E passport) នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-ចូលរួមពិធីបុណ្យជាតិនៃប្រទេសជាមិត្តចំនួន៥លើក។

-ចូលរួមពិធីទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ឡាវ។

-រៀបចំគ្រឿងឥស្សរិយយសសហមេត្រីចំនួន២គ្រឿង ជូនឥស្សរជនជាន់ខ្ពស់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានស្នាដៃក្នុងការរួមចំណែកបំពេញភារកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

-ចូលរួមកិច្ចអន្តរក្រសួង និងប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម(JC) លើកទី១៨ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

### ២.១.ការងារនីតិកម្ម

-រៀបចំប្រជុំ និងចូលរួមប្រជុំនៅទីស្តីការក្រសួង និងក្រសួង-ស្ថាប័នផ្សេងចំនួន៣៧លើក។

-បញ្ចូលឯកសារច្បាប់ចំនួន៧២ច្បាប់ ទៅក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ចូលរួមជំនួបពិភាក្សាការងារលើការគ្រប់គ្រងបណ្ណសារ របស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ណសារ ជាមួយនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋាននីតិកម្ម នៅទីស្តីការក្រសួងចំនួន១លើក។

-ចូលរួមពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពស្រាវជ្រាវ នៅទីស្តីការក្រសួងចំនួន១លើក។

-ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅខេត្តកំពង់ធំចំនួន២លើក ដោយមានអ្នកចូលរួមចំនួន១១២នាក់ (ស្ត្រីចំនួន២៩នាក់)។

-ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ភូមិបាល នៅខេត្តកែបចំនួន១លើក ដោយមានអ្នកចូលរួមចំនួន៣២០នាក់ (ស្ត្រីចំនួន២៣៦នាក់)។

-ចុះស្ទង់មតិប្រជាពលរដ្ឋអំពីការយល់ដឹងលើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅខេត្តព្រះសីហនុចំនួន៥លើក ដោយមានអ្នកចូលរួមចំនួន១៥៨នាក់ (ស្ត្រីចំនួន៦២នាក់)។

**២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់**

-ចុះផ្សព្វផ្សាយច្បាប់ចំនួន១០២លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៦លើក និងមន្ទីររាជធានី-ខេត្តចំនួន៩៦លើក ដោយមានអ្នកចូលរួមចំនួន២៥,៣៤១នាក់ (ស្ត្រីចំនួន១០,៥៣៣នាក់) និងបានទទួលសំណួរចំនួន១,៥២២សំណួរ។

**២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល**

ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី លើសេចក្តីព្រាងព្រះរាជក្រឹត្យចំនួន៤លើក សេចក្តីព្រាងច្បាប់ចំនួន៣២លើក សេចក្តីព្រាងអនុក្រឹត្យចំនួន៣៤លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តចំនួន១៦លើក។

**២.៤.ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា**

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គរបស់រដ្ឋសភា លើសេចក្តីព្រាងច្បាប់ចំនួន៣៣លើក ការបោះឆ្នោតជ្រើសតាំងចំនួន២លើក ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន១លើក និងការសម្រេចអំពីសុពលភាពចំនួន១លើក។

-ចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ចំនួន៤០លើក។

## ៣.សកម្មភាពការងារអធិការកិច្ច

**៣.១.ការងារអធិការកិច្ចលើវិស័យសេដ្ឋកិច្ច**

១.ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋក្នុងការិយបរិច្ឆេទ ២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធនៅតាមបណ្តាមន្ទីរ-អង្គភាព ក្នុងខេត្តចំនួន១១។

២.ធ្វើសេចក្តីណែនាំជូនបណ្តាក្រសួង-ស្ថាប័ន ឱ្យជួយជំរុញកែលម្អចំណុចខ្វះខាតដល់មន្ទីរ-អង្គភាព ដែលស្ថិតក្រោមឱវាទបានចំនួន ១០លិខិត។

៣.ទទួលលិខិតឆ្លើយតបស្តីពីការកែលម្អចំណុចខ្វះខាតពីក្រសួង ស្ថាប័ន អង្គភាពចំនួន ៦ លិខិត។

**៣.២.ការងារអធិការកិច្ចលើវិស័យរដ្ឋបាលទូទៅ**

១.ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរួមមាន៖

-ការិយបរិច្ឆេទ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួងចំនួន១ និងមន្ទីរ-អង្គភាពក្នុងខេត្តចំនួន៣។

-ការិយបរិច្ឆេទ២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅតាមបណ្តាមន្ទីរ-អង្គភាពក្នុងខេត្តចំនួន៤។

២.ទទួលរបាយការណ៍ពីក្រសួងផ្សេងៗចំនួន៨ របាយការណ៍ជូនជ្រាបពីក្រសួងចំនួន៣ អង្គភាពចំនួន១ និងមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១៩។

**៣.៣.ការងារអធិការកិច្ចលើវិស័យសង្គមកិច្ច**

១.ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ ២០១៨ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅក្រសួងចំនួន៣។

២.ធ្វើលិខិតជូនដំណឹងស្តីពីការជំរុញឱ្យកែលម្អនូវចំណុចខ្វះខាតដែលប្រតិភូបានរកឃើញ ក្នុងការិយបរិច្ឆេទ ២០១៨ ទៅក្រសួងចំនួន១ និងមន្ទីរ-អង្គភាពក្នុងខេត្តចំនួន។

៣.ទទួលលិខិតឆ្លើយតបស្តីពីការជំរុញការកែលម្អនូវចំណុចខ្វះខាតដែលប្រតិភូបានរកឃើញពីក្រសួង-ស្ថាប័ន និងមន្ទីរ-អង្គភាពចំនួន៦លិខិត។

**៣.៤.ការងារតាមដានការអនុវត្តច្បាប់**

១.នាយកដ្ឋានបានចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងការិយបរិច្ឆេទ២០១៩ ចំនួន៤លើក។

២. មន្ទីររាជធានី-ខេត្តបានចុះតាមដានត្រួតពិនិត្យការអនុវត្តច្បាប់ បានចំនួន១១លើក។

៣.ធ្វើសេចក្តីជូនដំណឹងស្តីពីការជំរុញកែលម្អចំណុចខ្វះខាតទៅតាមក្រសួង-ស្ថាប័នសរុបចំនួន២៦ រួមមាន៖ ថ្នាក់ជាតិចំនួន១៦លើក និងថ្នាក់ក្រោមជាតិចំនួន១០លើក។

៤.ទទួលលិខិតឆ្លើយតបរបស់ក្រសួង-ស្ថាប័នសរុបចំនួន៥លិខិត រួមមានថ្នាក់ជាតិចំនួន២លិខិត និងថ្នាក់ក្រោមជាតិចំនួន៣លិខិត។

**៣.៥.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន១២៩បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៨បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន១០១បណ្តឹង)៖

-ពាក្យបណ្តឹងដែលកំពុងត្រូវបានពិនិត្យមានចំនួន១បណ្តឹង(ឆ្នាំ២០២០ ចំនួន១បណ្តឹង)។

-ពាក្យបណ្តឹងដែលត្រូវបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន២១បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១៩បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន២បណ្តឹង ក្នុងនោះឆ្នាំ២០១៩ ចំនួន៦បណ្តឹង ឆ្នាំ ២០២០ ចំនួន១៥បណ្តឹង)។

-ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការមានចំនួន៣បណ្តឹង។

-ពាក្យបណ្តឹងដែលមន្ទីររាជធានី-ខេត្តសម្រេចតម្កល់ទុកមិនចាត់ការមានចំនួន៥បណ្តឹង។

-ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងបានបោះបង់ចោលមានចំនួន១បណ្តឹង។

-ពាក្យបណ្តឹងដែលកំពុងត្រូវបានសម្របសម្រួលនៅថ្នាក់ក្រសួងចំនួនចំនួន២បណ្តឹង។

-ពាក្យបណ្តឹងដែលបានអង្កេតស្រាវជ្រាវចប់មានចំនួន៧បណ្តឹង។

-ពាក្យបណ្តឹងដែលកំពុងអង្កេតស្រាវស្រាវចំនួន៥៤បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន២៣បណ្តឹង និងមន្ទីររាជធានី-ខេត្តចំនួន៣១បណ្តឹង។

-ពាក្យបណ្តឹងដែលត្រូវបានត្រៀមចុះអង្កេតស្រាវស្រាវចំនួន៣បណ្តឹង។

-ពាក្យបណ្តឹងដែលបានទទួលការឆ្លើយតបមានចំនួន៩បណ្តឹង ។

-ក្រសួងបានបញ្ចប់ការដោះស្រាយចំនួន៣៣បណ្តឹង។

## ៤-សកម្មភាពការងារសវនកម្មផ្ទៃក្នុង

-ចុះតាមដានអនុសាសន៍របស់សវនករ ក្នុងការិយបរិច្ឆេទ២០១៨ នៅតាមបណ្ដាសវនដ្ឋានចំនួន២ ។

-ចុះធ្វើសវនកម្ម ក្នុងការិយបរិច្ឆេទ២០១៩ នៅតាមទីសវនដ្ឋានចំនួន២មន្ទីរ។

-ចូលរួមវគ្គបណ្ដុះបណ្ដាលអនឡាញលើគោលការណ៍ណែនាំស្ដីពីសវនកម្មសមិទ្ធកម្ម សវនកម្មលើគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន ។

## ៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច

-រៀបចំសេចក្ដីព្រាងបឋមនូវបទបញ្ជាផ្ទៃក្នុង វិធីសាស្រ្តជ្រើសរើសសិក្ខាកាម គ្រូឧទ្ទេស សាស្ត្រាចារ្យ និងយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

-លើកស្លាកសញ្ញាវិទ្យាស្ថាន និងបំពាក់ឧបករណ៍មូលដ្ឋាននៅសាលសិក្សា។

-កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងវិទ្យាស្ថាន។

-ធ្វើស៊ីញ(និមិត្តសញ្ញាវិទ្យាស្ថាន) និងស្លាកឈ្មោះ សម្រាប់មន្ត្រីរាជការវិទ្យាស្ថាន។

-រៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២១-២០២៣។

-ធ្វើផែនការសកម្មភាពឆ្នាំ២០២១ ។

-រៀបចំកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈអធិការកិច្ចឆ្នាំ២០២១ ។

-លើកសំណើសុំ និងប្រកាសជ្រើសរើសគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ចចំនួន៩រូប សម្រាប់វិទ្យាស្ថានជាតិអធិការកិច្ច។

-ចុះសិក្សាស្រាវជ្រាវអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារអធិការកិច្ចនៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន១២លើក។

-រៀបចំសេចក្ដីព្រាងទម្រង់ចុះឈ្មោះចូលរៀនតាមប្រព័ន្ធអនឡាញ (Online)។

## ៦.ការងារផ្សេងៗ

### ៦.១.សកម្មភាពការងារយេនឌ័រ

-ក្រុមការងារបច្ចេកទេសយេនឌ័រក្រសួងបានរៀបចំពិធីអបអរសាទរខួបទី១០៩ ទិវាអន្តរជាតិនារី៨មីនា ក្រោមប្រធានបទ «មានសន្តិភាពមានការលើកកម្ពស់យេនឌ័រ» នៅទីស្ដីការក្រសួង។

-ចាត់បញ្ជូនមន្ត្រីជាស្ត្រីចំនួន២រូប ទៅបណ្ដុះបណ្ដាលស្ដីពីស្ត្រីភាពជាអ្នកដឹកនាំ នៅសាលាភូមិន្ទរដ្ឋបាល។

-ចាត់បញ្ជូនមន្ត្រីជាស្ត្រីចំនួន៤រូប ទៅបណ្ដុះបណ្ដាលស្ដីពីការអភិវឌ្ឍន៍ ភាពជាអ្នកដឹកនាំ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-សឹង្ហបូរី។

-សម្របសម្រួលជាមួយមន្ទីរពេទ្យព្រះកេតុមាលាបញ្ជូនអ្នកជំងឺចំនួន៧នាក់ ទទួលការព្យាបាលតាមការចុះអនុស្សរណៈ យោគយល់ជាមួយគ្នា។

-ចាត់ប្រតិភូចុះសួរសុខទុក្ខស្ត្រីជាមន្ត្រីរាជការសម្រាលមាតុភាពចំនួន៧នាក់ និងប្រគល់ជូនថវិកាឧបត្ថម្ភរបស់លោកជំទាវឧបនាយករដ្ឋមន្ត្រី ចំពោះស្ត្រីចំនួន៥០ម៉ឺនរៀល និងរបស់ក្រុមការងារបច្ចេកទេសយេនឌ័រ ក្រសួងម្នាក់ ២០ម៉ឺនរៀល បន្ថែមលើប្រាក់ឧបត្ថម្ភរបស់ក្រសួង ។

### ៦.២.សកម្មភាពការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងបានត្រៀមការចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយកងកម្លាំងជួរមុខវរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ និងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨២៧ នៃគណៈបញ្ជាការនគរបាលជាតិប្រចាំទិសភូមិភាគ៣។ តែដោយសារការរីករាលដាលនៃជំងឺកូវីដ១៩ គម្រោងចុះសួរសុខទុក្ខត្រូវផ្អាក។

## ៦.៣. សមាគមសង្គហមិត្តភាព

សមាគមសង្គហមិត្តភាពរបស់ក្រសួងដែលបានបង្កើតនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧បានឧបត្ថម្ភថវិកាចំនួនមួយលានរៀលជូនឯកឧត្តម វ៉ាត ហេង ទីប្រឹក្សាក្រសួង ដើម្បីចូលបុណ្យសពភរិយាគាត់ លោកជំទាវ ឡេង សឿនដែលបានទទួលមរណភាព នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២០។

## ៦.៤.សកម្មភាពក្រុមការងារតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-ប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាបន្តលើសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច ដោយមានការចូលរួមពីតំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ និងសមាជិកក្រុមការងារតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅទីស្ដីការក្រសួងចំនួន៣លើក។

-ប្រជុំ ក្រុមការងារតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិនិត្យ ដើម្បីពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច និងការងារផ្សេងៗ ចំនួន៤លើក។

-ចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចលើកទី៣ ទី៤ និងទី៥ នៅទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន៣លើក។

-ចូលរួមការពារសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច ក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច នៅទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន២លើក។

-ប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីមុខងារ ភារកិច្ចរបស់សវនកម្ម និង អធិការកិច្ចនៅទីស្ដីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន២លើក។

-ប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងជំនួយស្មារតី សម្រាប់កិច្ចប្រជុំអន្តរក្រសួងចង្អៀតលើសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច នៅទីស្ដីការក្រសួងចំនួន១១លើក។

-ដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចពិភាក្សាផ្លាស់ប្ដូរបទពិសោធន៍លើបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការងារអធិការកិច្ចជាមួយអគ្គអធិការកិច្ចរដ្ឋាភិបាល សាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីក្រុងហូជីមិញចំនួន១លើក។

-ប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ចនៅទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន២លើក។

-ប្រជុំអន្តរក្រសួងចង្អៀតដើម្បីពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ចនៅទីស្ដីការក្រសួងចំនួន៣លើក។

## ៦.៥.សកម្មភាពការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

ស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួងចំនួន១៣២នាក់។

## ៦.៦.សកម្មភាពការងារអ្នកនាំពាក្យក្រសួង

-ធ្វើសន្និសីទសារព័ត៌មាន នៅទីស្ដីការ គណៈរដ្ឋមន្ត្រី ដើម្បីផ្សព្វផ្សាយពីប្រវត្តិរបស់ក្រសួង តួនាទីភារកិច្ច និងវឌ្ឍនភាពការងារឆ្នាំ២០១៩ និងទិសដៅភារកិច្ចឆ្នាំ២០២០ ដោយផ្សាយផ្ទាល់តាមផេកហ្វេសប៊ុករបស់

អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា អង្គភាពសារព័ត៌មានFreshNews និងបណ្តាញសារព័ត៌មានទូរទស្សន៍ កាសែត វិទ្យុ និងទូរទស្សន៍ អនឡាញ ជាច្រើនទៀតផងដែរ។

-ប្រមូលទិន្នន័យដែលទាក់ទងនឹងសារជារណៈមតិ បានលើកឡើងពាក់ព័ន្ធនឹងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលមាននៅតាមបណ្តាញសារព័ត៌មាន និងបណ្តាញសង្គមមកពិនិត្យ និងឆ្លើយតប។

**៦.៧.សកម្មភាពការងារគេហទំព័រ MONASRI.gov.kh និង MONASRI App**

ធ្វើបច្ចុប្បន្នភាពគេហទំព័រក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និង គេហទំព័ររបស់លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី និង វិទ្យាស្ថានជាតិអធិការអធិការកិច្ច។

## គ-បញ្ហាប្រឈម

ទន្ទឹមនឹងលទ្ធផលទទួលបានខាងលើ ក្រសួងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

១.ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅមិនទាន់អនុម័តនៅឡើយ។

២.ការដោះស្រាយថវិកា និងប្រេងឥន្ធនៈសម្រាប់បេសកកម្ម នៅមានការខ្វះខាត និងយឺតយ៉ាវ។

៣. កង្វះមធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យាសម្រាប់ចុះបេសកកម្ម។

៤.សមត្ថភាពរបស់មន្ត្រីរាជការអធិការកិច្ចមួយចំនួនតូចនៅមានកម្រិត។

៥.ពុំទាន់មានដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យអធិការកិច្ចឱ្យបានទូលំទូលាយ។

៦.កិច្ចសហការជាមួយអគ្គាធិការ អធិការតាមក្រសួង ស្ថាប័ន នៅមានកម្រិត។

៧.កិច្ចសហការរបស់ក្រសួង-ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមួយចំនួន លើការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ និងការងារអង្កេតស្រាវជ្រាវពាក្យបណ្តឹងនៅមានកម្រិត។

៨. កង្វះសម្ភារ បរិក្ខា និងអនាម័យ ដោយសារនៅតាមនាយកដ្ឋាន តុ កៅអី ម៉ាស៊ីនថតចំលង បន្ទប់ទឹក បង្គន់ ។ល។ចាប់ផ្តើមខូចខាត និងចាស់ទ្រុឌទ្រោមជាបន្តបន្ទាប់។

៩. របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យឆ្លងប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ចចុះហត្ថលេខាយល់ព្រមលើលទ្ធផលអធិការកិច្ច។

១០. នៅមានភាពមិនច្បាស់លាស់ និងស្រពិចស្រពិលអំពីតួនាទីអធិការកិច្ច ជាពិសេសអធិការកិច្ចផ្អែកលើហានិភ័យក្រោយពីការចេញអនុក្រឹត្យលេខ ១៦៨អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដោយសារតួនាទីរបស់ក្រសួង ស្រដៀងគ្នានឹងស្ថាប័នមួយចំនួន ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គាធិការតាមក្រសួង ស្ថាប័ន។

១១. សូចនាករ វាស់វែងបាន នៅមានកំរិត ក្នុងលទ្ធផលការងារ។

១២. ថវិកាក្រសួង ជាពិសេសប្រាក់ និងប្រេងសម្រាប់បេសកកម្ម និងខ្ទង់មួយចំនួនទៀតត្រូវកាត់បន្ថយដោយបញ្ហាកូវីដ-១៩ ដែលអាចនាំឱ្យសកម្មភាព និងសមិទ្ធផលក្រសួងឆ្នាំ២០២១មានការថយចុះ។

១៣. វិន័យការងារ និងក្រមសីលធម៌របស់មន្ត្រីរាជការមួយចំនួននៅមានការខ្វះខាត។

១៤. ការងារដោះស្រាយពាក្យបណ្តឹង នៅមានភាពយឺតយ៉ាវ ភាពស្មុគស្មាញ ដោយសារឧបសគ្គមួយចំនួន។

១៥. វិទ្យាស្ថានជាតិអធិការកិច្ចខ្វះគ្រូ និងឯកសារមេរៀនគោលដែលជាលក្ខណៈជាតិ។

១៦. ភារកិច្ច និងសកម្មភាពតាមផ្នែក ការិយាល័យ ឬនាយកដ្ឋានមួយចំនួន មិនសូវមានដំណើរការមមាញឹក។

## ឃ.ទិសដៅការងារបន្ត

ដើម្បីចូលរួមគាំទ្រ និងអនុវត្តតាមយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមានទិសដៅ គោលនយោបាយ និងយុទ្ធសាស្ត្រច្បាស់លាស់អនុវត្តតាមបេសកកម្មតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ខ្លួនស្របតាមសភាពការជាក់ស្តែង ប្រកបដោយប្រសិទ្ធភាព ដោយត្រូវផ្តោតលើសកម្មភាពអាទិភាពដូចខាងក្រោមៈ

## ១. រដ្ឋបាលកិច្ចការទូទៅ

### ១-១-ការងាររដ្ឋបាល

-បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិអន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

-បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ។

-បន្តទំនាក់ទំនងកិច្ចសហការជាមួយរដ្ឋបាលថ្នាក់កណ្តាល គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសជាមួយរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី។

-បន្តគ្រប់គ្រងកិច្ចការរដ្ឋបាលក្រសួងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងបន្តកែលម្អ ដោយធ្វើការសម្របសម្រួលគ្រប់បណ្តាអង្គភាព និងមន្ទីររាជធានី-ខេត្ត ជាពិសេសបន្តចូលរួមគ្រប់កំណែទម្រង់រដ្ឋបាលសាធារណៈឱ្យស្របតាមតួនាទី ភារកិច្ចរបស់ក្រសួង និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១-២-ការងារបុគ្គលិក និងធនធានមនុស្ស

-បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស។

-បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗរបស់រាជរដ្ឋាភិបាល។

-បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ។

-ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី-ខេត្តឱ្យបានទាន់ពេលវេលា។

### ១-៣-ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

-ត្រៀមរៀបចំទូទាត់ប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ប្រចាំខែ ឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំធានាចំណាយប្រេងឥន្ធនៈប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ធានាចំណាយសម្ភារថែទាំអគារ សង្ហារឹម ឧបករណ៍ដឹកជញ្ជូន និងសម្ភារប្រើប្រាស់ប្រចាំឆ្នាំ២០២១។

-ត្រៀមរៀបចំឯកសារស្នើសុំគោលការណ៍ធានាចំណាយការងារជួសជុលលាបថ្នាំបន្ទប់អគារទីស្ដីការ ក្រសួង (ABC) និងជួសជុលស្ថាបនាអគារឱ្យសន្តិសុខស្នាក់នៅប្រចាំឆ្នាំ២០២១។

-ត្រៀមបែងចែកប្រេងឥន្ធនៈ សម្ភារការិយាល័យ សម្ភារបច្ចេកទេស និងដោះស្រាយសំណើផ្សេងៗ។

-ត្រៀមបែងចែកសម្ភារអនាម័យតាមបណ្ដានាយកដ្ឋាន។

-ត្រៀមចូលរួមផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបណ្ដាមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្ត។

**១-៤-ការងារផែនការ និងស្ថិតិ**

-បន្តរៀបចំសម្របសម្រួលលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ របស់ក្រសួង។

-បន្តបញ្ចូលទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ និងពិនិត្យឡើងវិញជាបណ្ដើរៗ។

-ពិនិត្យតាមដាន និងវាយតម្លៃលើប្រតិទិនការងារសម្រាប់ការិយាល័យដើម្បីអនុវត្តឆ្នាំ២០២០។

-រៀបចំតារាងតាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។

-ត្រៀមចូលរួមវគ្គបណ្ដុះបណ្ដាលលើការងារកសាងផែនការឱ្យកាន់តែមានប្រសិទ្ធភាព។

-រៀបចំរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-កំពុងបន្តរៀបចំគម្រោងផែនការថវិកាឆ្នាំ២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

-រៀបចំរបាយការណ៍សមិទ្ធកម្មតាមដានការអនុវត្តកម្មវិធីឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី-ខេត្តនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

**១-៥-ការងារសហប្រតិបត្តិការអន្តរជាតិ**

-បន្តទំនាក់ទំនង និងសហប្រតិបត្តិការជាមួយស្ថានទូតចិន និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីត្រៀមជំរុញអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងស្ថាប័នទាំងពីរ។

-បន្តសហការជាមួយវិទ្យាស្ថានសន្ទនាមេគង្គ(MDI) និងវិទ្យាស្ថានខុងជឺ នៃរាជបណ្ឌិត្យសភាកម្ពុជា។

-បន្តទំនាក់ទំនងពង្រឹងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍។

-បន្តទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-បន្តការសិក្សាស្រាវជ្រាវបណ្ដាប្រទេសជាសមាជិកអាស៊ាន និងអង្គការអន្តរជាតិ។

-ត្រៀមចូលរួមអនុវត្តការងារដែលថ្នាក់ដឹកនាំប្រគល់ជូន។

# ២-ការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

**២-១-ការងារនីតិកម្ម**

-ចូលរួមសិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង។

-បន្តកសាងសេចក្ដីព្រាងច្បាប់ស្ដីពីអធិការកិច្ច និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

-បន្តបញ្ចូលច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងបណ្ណាល័យអេឡិចត្រូនិច។

-ចុះស្ទង់មតិប្រជាពលរដ្ឋពាក់ព័ន្ធនឹងការយល់ដឹងផ្នែកច្បាប់ នៅតាមបណ្តាខេត្តគោលដៅ។

**២-២-ការងារអប់រំផ្សព្វផ្សាយច្បាប់**

-រៀបចំឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ផ្គត់ផ្គង់ការផ្សព្វផ្សាយច្បាប់។

-សិក្សាស្រាវជ្រាវឯកសារ ឬលិខិតបទដ្ឋានពាក់ព័ន្ធនឹងច្បាប់។

-ចុះផ្សព្វផ្សាយច្បាប់នៅតាមបណ្តាខេត្តគោលដៅ ដែលបានកំណត់ក្នុងផែនការ។

-ចុះសិក្សាស្រាវជ្រាវមុននឹងក្រោយការផ្សព្វផ្សាយច្បាប់។

**២-៣-ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា**

-ចូលរួមប្រជុំអន្តរក្រសួង និងតាមក្រសួង-ស្ថាប័ន។

-ចូលរួមស្តាប់សម័យប្រជុំពេញអង្គ វិសាមញ្ញ នៅរដ្ឋសភា-ព្រឹទ្ធសភា។

-ចុះអមដំណើរសមាជិកព្រឹទ្ធសភា និងរដ្ឋសភា តាមភូមិភាគ និងមណ្ឌលរាជធានី-ខេត្ត។

-សិក្សាស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តសម្រាប់ការងារវេទិការសាធារណៈ។

-ចុះរៀបចំវេទិការសាធារណៈ នៅតាមបណ្តាខេត្តគោលដៅ។

## ៣.ការងារអធិការកិច្ច

**៣.១.ការងារអធិការកិច្ច(វិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)**

-បន្តអនុវត្តការងារអធិការកិច្ចដែលពុំទាន់បានបញ្ចប់ក្នុងឆ្នាំ២០២០។

-រៀបចំ និងកែសម្រួលផែនការប្រតិបត្តិអធិការកិច្ច ឱ្យស្របតាមស្ថានភាពការងារជាក់ស្តែង។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពប្រចាំឆ្នាំ២០២១។

-ប្រមូលចងក្រងឯកសារគតិយុត្តទាំងឡាយដែលមានប្រយោជន៍ដល់ការងារអធិការកិច្ច។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

**៣.២.ការងារតាមដានការអនុវត្តច្បាប់**

-បន្តចុះតាមដានត្រួតពិនិត្យរាល់ការអនុវត្តច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី។

-ត្រៀមរៀបចំសេចក្តីជូនដំណឹង ស្តីពីការជំរុញកែលម្អលើចំណុចខ្វះខាតទៅបណ្តាក្រសួង-ស្ថាប័ន។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២១។

-ប្រមូលចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ចុះការងារតាមដាន។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

**៣.៣.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

-បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ។

-បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង។

-ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២១។

-អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

## ៤.ការងារសវនកម្មផ្ទៃក្នុង

-បន្តអនុវត្តការងាររបស់ខ្លួនស្របតាមអនុក្រឹត្យលើលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងប្រកាសលេខ០៧៣ ទរពអ.ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋាននៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

-រៀបចំបញ្ចប់នូវបទបញ្ជាផ្ទៃក្នុង រៀបចំវិធីសាស្រ្តនៃការជ្រើសរើសសិក្ខាកាម គ្រូឧទ្ទេស សាស្រ្តាចារ្យ និងយន្តការ តាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់វិទ្យាស្ថាន។

-កែលម្អរចនាសម្ព័ន្ធគ្រប់គ្រង និងរបៀបរបបបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព។

-ពង្រឹងសមត្ថភាពមន្ត្រីរាជការវិទ្យាស្ថានទៅលើមុខជំនាញពាក់ព័ន្ធ។

-ស្នើសុំបង្កើតក្រុមគ្រូបង្គោលវិជ្ជាជីវៈអធិការកិច្ចសម្រាប់វិទ្យាស្ថាន។

-ស្នើសុំបង្កើតអង្គភាពថវិកាវិទ្យាស្ថានជាតិអធិការកិច្ចដើម្បីសម្រួល និងពន្លឿនចរន្តការងារឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព។

-ពង្រឹងការគ្រប់គ្រងចំណូល ចំណាយ ផ្គត់ផ្គង់សម្ភារ បរិក្ខារ និងសារពើភ័ណ្ឌរបស់វិទ្យាស្ថាន។

-ពង្រឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងអនាម័យរបស់វិទ្យាស្ថាន។

-បកប្រែឯកសារសំខាន់ៗពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-ស្រាវជ្រាវ និងប្រមូលផ្តុំឯកសារ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធនឹងវិស័យអធិការកិច្ច។

-ស្ទង់មតិអំពីការគ្រប់គ្រង និងការអភិវឌ្ឍន៍ការងារធិការកិច្ច។

-ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចដល់មន្ត្រីរាជការក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួង ស្ថាប័ននានា។

-រៀបចំកែលម្អកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចសម្រាប់ឆ្នាំ២០២២។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្ណាស្ថានទូតនានា។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ។

-ពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា។

-បង្កើត និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យារបស់វិទ្យាស្ថាន។

-រៀបចំ និងបង្កើនប្រសិទ្ធភាពគ្រប់គ្រងបណ្ណាល័យ។

## ៦.ការងារផ្សេងៗ

### ៦.១.ការងារយេនឌ័រ

-ក្រុមការងារបញ្ជ្រាបយេនឌ័រសំដៅលើកកម្ពស់សមត្ថភាពផ្នែកបទដ្ឋានគតិយុត្តិ ផ្សព្វផ្សាយច្បាប់ចរាចរណ៍ណែនាំ និងអនុសាសន៍សំខាន់ៗរបស់ថ្នាក់ដឹកនាំ។

-រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ស្ថាប័ន និងបញ្ជ្រាបយេនឌ័រតាមវិស័យ។

-រៀបចំផែនការសកម្មភាពជាប្រចាំទទួលបាននូវថវិកាគាំទ្រ ស្មារតីឧបត្ថម្ភគាំទ្រពីថ្នាក់ដឹកនាំ ធ្វើឱ្យក្រុមការងារសម្រេចបានការងារអនុវត្តន៍ជាប្រចាំ តាមការណែនាំរបស់ក្រសួងកិច្ចការនារី និងផែនការអភិវឌ្ឍន៍ជាតិអនុលោមតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ៦.២.ការងារចងសម្ព័ន្ធមេត្រីភាព

ក្រសួងនឹងចូលរួមយ៉ាងសកម្មថែមទៀត ក្នុងការពង្រឹងសម្ព័ន្ធមេត្រីភាពជាមួយកងវរសេនាតូចនគរបាលព្រំដែន ទាំងពីរអង្គភាព ឱ្យកាន់តែជិតស្និទ្ធ។

### ៦.៣.ការងារសមាគមសង្គហមិត្តភាព

-ពង្រឹងការប្រមូលវិភាគទានពីសមាជិកដើម្បីយកមកដំណើរការសមាគម។

### ៦.៤.ការងារក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

-បន្តប្រជុំ ដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅគ្រប់ដំណាក់កាល។

-បន្តរៀបចំគ្រប់លិខិតបទដ្ឋានគតិយុត្តដែលថ្នាក់ដឹកនាំប្រគល់ជូន។

-ពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តជាអាទិភាពដែលបានចែងក្នុងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

### ៦.៥.ការងារគណៈកម្មការគ្រឿងឥស្សរិយយសក្រសួង

បន្តស្នើសុំគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនក្រសួង។

### ៦.៦.ការងារអ្នកនាំពាក្យក្រសួង

-បង្កើនប្រសិទ្ធិភាព ក្នុងកិច្ចការងារគ្រប់គ្រង និងតាមដានសាធារណៈមតិ ដើម្បីការពារភាពត្រឹមត្រូវ របស់ថ្នាក់ដឹកនាំ និងស្ថាប័ន តាមរយៈការបញ្ចេញព័ត៌មានពិត បន្សាបព័ត៌មានក្លែងក្លាយដែលមានចរិកធ្វើឱ្យប៉ះពាល់កិត្តិយសថ្នាក់ដឹកនាំ និងស្ថាប័ន។

### ៦.៧.ការងារគេហទំព័រ MONASRI.GOV.KH និង MONASRI App

-ធ្វើការតាមដានការចុះផ្សាយព័ត៌មាននៅក្នុងទំព័រហ្វេសប៊ុកសំខាន់ទាំង៣ ដើម្បីបញ្ចូលក្នុង Website ឱ្យបានទាន់ពេលវេលា។

-ធ្វើការ backup ទិន្នន័យនៅក្នុង Website ជាប្រចាំ ដើម្បីរក្សាទុករាល់ទិន្នន័យដែលមានកន្លងមកឱ្យមានសុវត្ថិភាព។

-រៀបចំទម្រង់ Website របស់មួយទៀតជាភាសាអង់គ្លេស។

## ខ-សេចក្តីសន្និដ្ឋាន

ទោះជាមានការប្រឈមខ្លះ ក៏ក្រសួងបានជម្នះ និងបំពេញតួនាទីទៅតាមច្បាប់អនុញ្ញាត ហើយយើងបានឃើញច្បាស់ថា ការងាររបស់យើង ពិតជាជួយធានាការពង្រឹងប្រសិទ្ធភាពការងារស្ថាប័ន អង្គភាពរដ្ឋ ធានាសុវត្ថិភាព និងសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋ និងនាំមកនូវតម្លាភាព កាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាតម្រូវឱ្យអនុវត្តកិច្ចសន្យា រវាងក្រុមហ៊ុននានា ជាមួយរដ្ឋបានល្អ ជួយកាត់បន្ថយ និងលុបបំបាត់ ការកឹបកេង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅជាដើម។

លទ្ធផលដែលសម្រេចបានកន្លងមកនេះបានបង្ហាញថាក្រសួងយើងមានសារៈសំខាន់ និងរួមចំណែកដល់ការជំរុញអភិបាលកិច្ចល្អ។ កត្តាជាគន្លឹះដែលនាំឱ្យសម្រេចបាននូវលទ្ធផលខាងលើ គឺដោយសារមានការគាំទ្រ និងការដឹកនាំប្រកបដោយបញ្ញាញាណដ៏ត្រឹមត្រូវ និងភ្លឺស្វាង របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ដែលតែងតែនៅជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង។

លើសពីនេះក្រសួងដំណើរការទៅប្រកបដោយប្រសិទ្ធភាព និងជោគជ័យ អាស្រ័យដោយមានការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែគាំទ្ររាល់សកម្មភាពការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

យើងសង្ឃឹមថា ក្នុងឆ្នាំ២០២១ ខាងមុខ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ នឹងខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។ ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

# ឧបសម្ព័ន្ធ ៣. របាយការណ៍បូកសរុបលទ្ធផលសន្និបាតសង្ខេប

## របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

(អានដោយឯកឧត្តមបណ្ឌិត **ចាប សុថារិទ្ធ** រដ្ឋលេខាធិការ)

សូមគោរពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** នាយករដ្ឋមន្ត្រី
ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋាន
ឯកឧត្តម នាយកខុទ្ទកាល័យ
ឯកឧត្តម លោកជំទាវ លោក លោកស្រី
អង្គសន្និបាតទាំងមូល ជាទីមេត្រី

ក្នុងរយៈពេលពេញមួយថ្ងៃនេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០២០ និងលើកទិសដៅឆ្នាំ ២០២១ ដែលគ្រោងបញ្ចប់នៅពេលល្ងាចនាថ្ងៃទី២ខែកុម្ភៈ នេះ។

ដោយសារការគោរពបទបញ្ជារបស់រាជរដ្ឋាភិបាល ទប់ស្កាត់ និងការពារជម្ងឺកូវីដ ១៩ សន្និបាតក្រសួងឆ្នាំនេះ ត្រូវបានធ្វើឡើងក្នុងរូបភាព តូចជាងឆ្នាំមុន។ អង្គសន្និបាតត្រូវបានរៀបចំឡើងក្នុងរូបភាពផ្ទៃក្នុងក្រសួងតែប៉ុណ្ណោះ ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំក្រសួង ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត សរុបចំនួន ២៥០ នាក់ និងបានប្រព្រឹត្តទៅដោយរលូនតាមកម្មវិធីដែលបានគ្រោងទុក។

នៅពេលព្រឹកបន្ទាប់ពី ឯកឧត្តម ឆេង សារឿន រដ្ឋលេខាធិការប្រចាំការបានអានរបាយការណ៍សង្ខេបបូកសរុបលទ្ធផលការងារ ឆ្នាំ ២០២០ និងទិសដៅឆ្នាំ ២០២១មក លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី បានថ្លែងសុន្ទរកថាបើកសន្និបាត ដោយបានបញ្ជាក់ពីប្រវត្តិសង្ខេបរបស់ក្រសួង និងតួនាទីភារកិច្ចស្នូលចំបងៗរបស់ក្រសួង។ លោកជំទាវបានសម្តែងនូវមោទនភាព កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ ការទទួល អង្កេត និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។ លោកជំទាវក៏បានផ្តល់ការណែនាំ ដល់អង្គសន្និបាត ដើម្បីបន្តការពិភាក្សា លើរបាយការណ៍ និងពិភាក្សាតាមបទបង្ហាញនីមួយៗក្នុងកិច្ចប្រជុំរួម(Planary Session)។

នៅសម័យប្រជុំពេញអង្គពេលព្រឹក ប្រធានមន្ទីរ ខេត្តបាត់ដំបង ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តពោធិសាត់ ខេត្តតាកែវ និងខេត្តត្បូងឃ្មុំបានឡើងចាប់អារម្មណ៍ ដោយបានលើកឡើងពីសមិទ្ធផលការងារ

បទពិសោធន៍ការងារ និងការប្រឈមមួយចំនួន រួមមាន កង្វះមធ្យោបាយដឹកជញ្ជូន កង្វះបុគ្គលិក និងកង្វះការបណ្តុះបណ្តាលបច្ចេកទេសជាពិសេសការសរសេររបាយការណ៍ និងកំណត់ហេតុ។

ក្រោយពីសម្រាកពិសាអាហារសម្រន់ពេលព្រឹក លោកជំទាវឧបនាយករដ្ឋមន្ត្រីបានដឹកនាំអង្គសន្និបាតផ្ទាល់ដោយបានធ្វើកិច្ចប្រជុំរួម ដោយបើកទូលាយ ឱ្យមានការចូលរួមជាបទអន្តរាគមន៍ ជាការលើកយោបល់ និងសំណួរ នានាពីអង្គសន្និបាតទាំងមូល។ កម្មវិធីទី១ គឺការចូលរួមបញ្ចេញយោបល់ឬ បទអន្តរាគមន៍របស់មន្ទីរទរពអ រាជធានី ខេត្តមួយចំនួន។ ជាការឆ្លើយតប គណៈអធិបតី ដែលរួមមានលោកជំទាវកិត្តិសង្គហបណ្ឌិត រួមជាមួយឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការក្រសួងបានកត់ត្រាទុកជាធាតុចូល និងបានឆ្លើយតបពន្យល់ និងបកស្រាយជូនអង្គសន្និបាតទៅតាមវិស័យទទួលខុសត្រូវរៀងៗខ្លួនបានយ៉ាងច្បាស់ និងក្បោះក្បាយ។ ក្រោយមកនាយកវិទ្យាស្ថានជាតិអធិការកិច្ចបានធ្វើបទបង្ហាញលទ្ធផលការងារ និងទិសដៅវិទ្យាស្ថានជាតិអធិការកិច្ច និងពិភាក្សាលើបទបង្ហាញនោះ។

ក្រោយពីសម្រាកពិសាបាយថ្ងៃត្រង់រួមសន្និបាតបានបន្តទៅតាមកម្មវិធីដែលបានគ្រោយទុក ដោយមានបទអន្តរាគមន៍ពី អគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ បទអន្តរាគមន៍របស់អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា បទអន្តរាគមន៍របស់អគ្គនាយកដ្ឋានអធិការកិច្ច និងបទអន្តរាគមន៍របស់ ក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងការពិភាក្សាលើបទអន្តរាគមន៍ទាំងនោះ។

អង្គសន្និបាតបានរកឃើញការប្រឈមមួយចំនួន ដែលក្រសួងត្រូវជួបប្រទះ និងរួមគ្នាដោះស្រាយជាបណ្តើរៗ ទៅតាមលទ្ធភាពដែលអាចធ្វើបាន។

ទោះជាមានការប្រឈមខ្លះ ជាពិសេសដោយសារបញ្ហានៃការរាលដាលជំងឺកូវីដ-១៩ ក្តី ក៏ជារួម សន្និបាតបានវាយតម្លៃ ខ្ពស់ចំពោះជោគជ័យ នៃឆ្នាំ ២០២០ ដោយថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខិតខំពុះពាររាល់ការលំបាក ប្រឹងប្រែងអនុវត្តការងារប្រកបដោយប្រសិទ្ធភាព សមត្ថភាព និងមនសិការទទួលខុសត្រូវ ខ្ពស់ និងដោយសារមានការគាំទ្រ និងកិច្ចសហការល្អពីគ្រប់មជ្ឈដ្ឋាន ទាំងស្ថាប័នរដ្ឋ ស្ថាប័នឯកជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងប្រទេស។

ជាទិសដៅ ក្នុងឆ្នាំ ២០២១ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គ្រប់លំដាប់ថ្នាក់ ប្តេជ្ញាខិតខំប្រឹងប្រែងជាបន្តទៀត ដើម្បីដោះស្រាយ និងកាត់បន្ថយឱ្យបានជា អតិបរមា នូវចំណុចខ្វះខាតរបស់ក្រសួង ក៏ដូចជាបាតុភាពអសកម្មនានាដែលកើតមានក្នុងសង្គម។

ក្រសួងសូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួង ស្ថាប័ននានា រដ្ឋបាលដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាសហគមន៍ និងប្រជាពលរដ្ឋ សូមបន្តចូលរួមសហការ ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីសម្រេចបានជោគជ័យ និងសមិទ្ធផលថ្មីៗ បន្ថែមទៀត ជូនជាតិមាតុភូមិនៃយើង។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំបាទសូមគោរពអញ្ជើញ លោកជំទាវកិត្តសង្គហបណ្ឌិត មេត្តាថ្លែងសុន្ទរកថាបិទសន្និបាត សូមគោរពអញ្ជើញ។

# ឧបសម្ព័ន្ធ ៤. សុន្ទរកថាបើកសន្និបាត

របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ថ្ងៃអង្គារ៍ ៥រោច ខែមាឃ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹង ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១
ភោជនីយដ្ឋានទន្លេបាសាក់២ (លេខ ៥៣៤ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ)

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ជាបឋម ខ្ញុំមានសេចក្តីរីករាយ និងសូមស្វាគមន៍ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រសួងទាំងអស់ដែលបានចូលរួមក្នុងពិធីបើកសន្និបាតប្រចាំឆ្នាំរបស់ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនាពេលនេះ។

យើងជួបជុំគ្នាក្នុងសន្និបាត ដែលមានរយៈពេលពេញមួយថ្ងៃនេះមានគោលបំណងត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបលទ្ធផលការងារដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០២០កន្លងមក ដោយលើកឡើងពីសមិទ្ធផលគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងមន្ទីរនៅរាជធានី ខេត្ត និងការប្រឈម និងវិធានការណ៍ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ សម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២១ ដើម្បីសម្រេចបានលទ្ធផលទៅតាម ផែនការ និងយុទ្ធសាស្ត្រដូចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន។

សន្និបាតយើងធ្វើឡើងចំពេលដែលប្រទេសយើង ក៏ដូចជាប្រទេសនានាក្នុងតំបន់ និងពិភពលោកកំពុងជួបប្រទះនូវគ្រោះមហន្តរាយនៃការរាលដាលនៃជំងឺកូវីដ-១៨ ដែលកំពុងរាតត្បាត និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាសកល នាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរ នៃការធ្វើដំណើរ សេវាកម្ម ពាណិជ្ជកម្ម និងការវិនិយោគ ជាហេតុរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយឡែក វិបត្តិកូវីដ១៩ក៏បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់ប្រតិបត្តិការការងាររបស់ក្រសួងយើងផងដែរជាពិសេសបេសកកម្មទាំងក្នុង និងក្រៅប្រទេស លទ្ធកម្ម និងការបណ្តុះបណ្តាល ដោយសាររាជរដ្ឋាភិបាលបានកាត់បន្ថយការចំណាយលើមុខសញ្ញាជាច្រើន ចាប់ពីដើមឆ្នាំ ២០២០មក ក្នុងគោលបំណងត្រៀមទប់ទល់ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។

ដោយសារបញ្ហារក្សាសុវត្ថិភាពក្នុងដំណាក់កាលគ្រោះនៃជំងឺកូវីដ-១៩ ទើបសន្និបាតឆ្នាំនេះត្រូវបានរៀបចំឡើងដោយទ្រង់ទ្រាយតូចជាងឆ្នាំមុន និងមានការចូលរួមតែពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង ទាំងនៅថ្នាក់កណ្តាល ទាំងថ្នាក់រាជធានី ខេត្ត ក្នុងក្រសួងយើងតែប៉ុណ្ណោះ។ ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែង

អំណរគុណ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលមានបានចំណាយពេលដ៏មានតម្លៃមកចូលរួមក្នុងពិធីនេះ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គឺជាស្ថាប័នរដ្ឋដែលជាសេនាធិការផ្ទាល់របស់រដ្ឋាភិបាលមានប្រវត្តិយូរយាមកហើយ និងបានវិវត្ត ផ្លាស់ប្តូរជាហូហែរ ទៅតាមស្ថានការណ៍នយោបាយនៅកម្ពុជា។ យើងពិតជានៅចងចាំបានថា កាលពីឆ្នាំ១៩៨១ នៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា **"ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋ"** ដែលជាស្ថាប័នគ្រប់គ្រងការត្រួតពិនិត្យ និងអធិការកិច្ច ត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ និងដោះស្រាយបាតុភាពអសកម្ម នានាជាពិសេសដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាជន។ ក្រោយមក នៅឆ្នាំ១៩៨៧ ក្រសួងត្រួតពិនិត្យកិច្ចការរដ្ឋត្រូវប្តូរឈ្មោះជា **"ក្រសួងត្រួតពិនិត្យ"** វិញ។ ពេលនោះគ្មានស្ថាប័នទទួលបន្ទុកវិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភាទេ។

ក្រសួងត្រួតពិនិត្យ ស្ថិតនៅចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលបច្ចុប្បន្នយើងហៅថារដ្ឋាភិបាល ឬគណៈរដ្ឋមន្ត្រី និងមានបណ្តាញរបស់ខ្លួននៅតាមក្រសួង ខេត្ត ក្រុង ខណ្ឌ ស្រុក ស្រុកទីរួមខេត្ត ដែលមានឈ្មោះថា គណៈកម្មាធិការត្រួតពិនិត្យក្រសួង ខេត្ត ក្រុង ខណ្ឌ ស្រុក ទីរួមខេត្ត ដើម្បីធ្វើការងារត្រួតពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ពលរដ្ឋ ដែលស្ថិតក្នុងមូលដ្ឋានរបស់ខ្លួន។

ក្រោយពីការបោះឆ្នោតសកលឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលចម្រុះ ក្នុងនីតិកាលទី ១ នៃរដ្ឋសភា (១៩៩៣-១៩៩៨) ស្ថាប័នទទួលបន្ទុកទំនាក់ទំនងរដ្ឋសភា និងស្ថាប័នទទួលបន្ទុកអធិការកិច្ច ត្រូវបានបង្កើតឡើងដាច់ដោយឡែកពីគ្នា ដោយ **"រដ្ឋលេខាធិការដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា"** (ពេលនោះយើងមិនទាន់មានស្ថាប័នព្រឹទ្ធសភាទេ) ជាស្ថាប័នមួយ និង **"អគ្គលេខាធិការដ្ឋានអធិការកិច្ច"** ជាស្ថាប័នផ្សេងមួយទៀត។ ស្ថាប័នទាំងពីរស្ថិតក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រីដូចគ្នា។ ក្រោយមកនៅឆ្នាំ ១៩៩៩ ស្ថាប័នទាំងពីរខាងលើត្រូវបានប្របាច់បញ្ចូលគ្នាទៅជា"ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច" ដែលកំពុងដំណើរការរហូតមកដល់សព្វថ្ងៃ។

ក្រសួងយើងមានភារកិច្ច ដឹកនាំគ្រប់គ្រង សម្របសម្រួលការងារ តាមរយៈទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើអធិការកិច្ច លើគ្រប់វិស័យក្នុងព្រះរាជាណាចក្រកម្ពុជា។ ភារកិច្ចសំខាន់របស់ក្រសួង គឺត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ ទប់ស្កាត់អំពើពុករលួយ ភាពអយុត្តិធម៌ក្នុងសង្គម និងការរំលោភបំពានដោយអំណាច ដើម្បីបំរើប្រយោជន៍បុគ្គល និងក្រុមគ្រួសារ និងការពារសិទ្ធរបស់ពលរដ្ឋ និងសុវត្ថិភាពសាធារណៈ ពោលគឺពង្រឹងអភិបាលកិច្ចល្អ ដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព របស់រាជរដ្ឋាភិបាល។

ដូច្នេះ ការងារទី១ របស់ក្រសួងគឺ **ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា** ដែលរួមមានការសម្របសម្រួល ធ្វើទំនាក់ទំនងរវាងរាជរដ្ឋាភិបាល ជាមួយស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា និងចូលរួមតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល លើកកម្ពស់ការយល់ដឹងពីច្បាប់ និងការអនុវត្តន៍ច្បាប់ ដោយធ្វើការផ្សព្វផ្សាយច្បាប់យ៉ាងទូលំទូលាយ ជូនដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសឱ្យបានយល់។ ក្រៅពីការងារខាងលើ ក្រុមការងារក្រសួងបានចុះទៅដល់គ្រប់ខេត្ត ក្រុង ស្រុក ទីប្រជុំជន ជនបទដាច់ស្រយាល និងសហគមន៍នានា ដើម្បីបើកវេទិកាសាធារណៈ អប់រំ ផ្សព្វផ្សាយច្បាប់ ធ្វើការស្ទាបស្ទង់មតិ ដើម្បីស្វែងយល់ពីទុក្ខ

លំបាករបស់ប្រជាពលរដ្ឋ ផ្សព្វផ្សាយរាល់អនុសាសន៍ ដ៏ថ្លៃថ្លារបស់ថ្នាក់ដឹកនាំ ពិសេសកម្មវិធីនយោបាយ ផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជូនដល់ប្រជាពលរដ្ឋ ហើយពាំនាំនូវសំណូមពររបស់ប្រជាពលរដ្ឋ ជូនរាជរដ្ឋាភិបាលដើម្បីដោះស្រាយ។

ចំណែកការងារទី២គឺ **ការងារអធិការកិច្ច** ដែលត្រូវអនុវត្តតាមស្ថាប័ន និងអង្គភាពនានាជាប្រចាំ ដែលនេះជាភារកិច្ច ដ៏សំខាន់ទាក់ទងនឹងការពង្រឹងការអនុវត្តន៍ច្បាប់ សំដៅជានាប្រឆាំងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា នៅក្នុងជួររដ្ឋបាលសាធារណៈ ក៏ដូចជាផ្នែកឯកជន ដើម្បីធានាការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃថវិកា និងទ្រព្យសម្បត្តិរដ្ឋ ការពារសុវត្ថិភាពសាធារណៈ និងការពារសិទ្ធរបស់ប្រជាពលរដ្ឋ។

ក្រៅពីការងារខាងលើ ក្រសួងនៅមានភារកិច្ចច្រើនទៀត ដូចជាការតាមដានការអនុវត្តច្បាប់ ការទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ ដោះស្រាយពាក្យបណ្តឹង បណ្តុះបណ្តាលជំនាញអធិការកិច្ចតាមរយៈវិទ្យាស្ថានជាតិអធិការកិច្ច និងរដ្ឋបាលកិច្ចការទូទៅដើម្បីទ្រទ្រង់ដំណើរការ និងពង្រឹងប្រសិទ្ធភាពការងារក្រសួង។

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចមានទស្សនៈវិស័យគឺ៖ ***«អភិវឌ្ឍស្ថាប័ន ឱ្យក្លាយជារដ្ឋបាលទំនើបមួយ ប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីធ្វើជាភ្នែក ជាត្រចៀករបស់រាជរដ្ឋាភិបាល បំរើប្រជាពលរដ្ឋ ការពារសុវត្ថិភាពសាធារណៈ ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ស្ថាប័ន និងប្រជាពលរដ្ឋ ពង្រឹងតម្លាភាព អភិបាលកិច្ចល្អ និងនីតិរដ្ឋ»*** ។

ដើម្បីប្រែក្លាយទស្សនវិស័យខាងលើឱ្យទៅជាការពិត ក្រសួងមានបេសកកម្ម គឺ៖ ***«បំពេញការងារ ដោយយកច្បាប់ជាគោល ក្នុងការផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋ ធ្វើអធិការកិច្ច តាមដានការអនុវត្តច្បាប់ និងដោះស្រាយបណ្តឹង ដើម្បីសម្រេចលទ្ធផលដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្ររបស់ក្រសួង ក្នុងគោលដៅទប់ស្កាត់បាតុភាពអសកម្ម អំពើពុករលួយ និងការរំលោភដោយអំណាច ដើម្បីបំរើប្រជាពលរដ្ឋ និងបង្កើនជំនឿជឿជាក់មកលើរាជរដ្ឋាភិបាល»***។

ក្នុងន័យនេះ យុទ្ធសាស្ត្រ និងផែនការសកម្មភាពត្រូវបង្កើតឡើងដើម្បីធ្វើឱ្យបេសកកម្មនេះទទួលបានជោគជ័យ ។

### *អង្គសន្និបាតទាំងមូលជាទីមេត្រី*

ការធ្វើអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ និងបង្កើនប្រសិទ្ធភាពការងារពោលគឺសំដៅទៅលើការកាត់បន្ថយ និងទប់ស្កាត់អំពើពុករលួយ ព្រោះអំពើពុករលួយធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរណាស់ដល់ប្រទេសជាតិ ដូចជាបង្កការខាតបង់ថវិការដ្ឋ ទ្រព្យសម្បត្តិសាធារណៈ រាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ច បង្កឧបសគ្គដល់ធុរកិច្ច និងការបាត់បង់ដល់ការប្រកួតប្រជែង ដោយសេរី និងយុត្តិធម៌ និងរំខានដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿមកលើរាជរដ្ឋាភិបាល។

អភិបាលកិច្ចល្អជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជម្រុញ និងគាំទ្រដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍនមួយប្រកបដោយនិរន្តរភាព។ អភិបាលកិច្ចដែលប្រកបដោយសុភនិដ្ឋ័យ គឺជាអភិបាលកិច្ចល្អដោយការចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល។ ដោយយល់ឃើញពីសារៈសំខាន់

នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថា "អភិបាលកិច្ចល្អគឺជាបុរេលក្ខខណ្ឌសំខាន់បំផុត ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌សង្គម"។

ការទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ និងការជម្រុញអភិបាលកិច្ចល្អទាមទាឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងវិស័យរដ្ឋ និងឯកជន។ ដោយសារការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយត្រូវផ្តោតទៅលើអភិក្រមជាសារវន្តចំនួន ៣ គឺៈ ការអប់រំបង្ការទប់ស្កាត់ជាមុន ការអនុវត្តច្បាប់ និងការចូលរួមគាំទ្រពីមហាជន។ ដូច្នេះការងារអធិការកិច្ច និងការពង្រឹងការអនុវត្តច្បាប់ មិនអាចផ្តាច់ចេញពីការអប់រំផ្សព្វផ្សាយច្បាប់ជូនដល់មហាជន និងការចូលរួមរបស់ប្រជាជនបានឡើយ។ ដូច្នេះ ការងារស្នូលដ៏សំខាន់របស់ក្រសួង គឺធានាការដឹកនាំគ្រប់គ្រងរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។

ចាប់តាំងពីការបង្កើតស្ថាប័ននេះមក ក្រសួងសម្រេចបានលទ្ធផលជាច្រើន ជាពិសេសក្នុងការងារស្នូលដូចជា អធិការកិច្ច ការទទួល និងដោះស្រាយពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការចុះស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការសម្របសម្រួលបញ្ចប់ទំនាស់រ៉ាំរ៉ៃ បានជាច្រើនករណី ការតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏មានភារកិច្ចធ្វើការអប់រំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គង ក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាពគ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកែលម្អរ ជម្រុញលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាល ពីដំណាក់កាលទី១ ដល់ទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដែលមានបួនដំណាក់កាល។ ដោយឡែក រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានប្រកាសដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈគោលនយោបាយសម្រាប់ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍប្រទេសជាតិសម្រាប់រយៈពេល៥ឆ្នាំជាបន្តទៀត។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤មានអភិបាលកិច្ចល្អជាស្នូល និងមានមុំបួនគឺ ១) ការអភិវឌ្ឍន៍ធនធានមនុស្ស ២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច ៣) ការអភិវឌ្ឍន៍វិស័យឯកជន និងការងារ និង ៤) ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ន។ យុទ្ធសាស្ត្រថ្មីនេះបានពង្រីកនូវវិសាលភាព សម្រិតសម្រាំងបន្ថែម និងធ្វើអាទិភាពូបនីយកម្មមុំនីមួយៗនៃចតុកោណយុទ្ធសាស្ត្រទាំង៤ ព្រមទាំងកែលម្អរបៀបវារៈ គោលនយោបាយ និងយន្តការអនុវត្តមួយចំនួនឲ្យកាន់តែល្អប្រសើរឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះចាំបាច់ទាំងឡាយក្នុងចក្ខុវិស័យប្រែក្លាយឋានៈរបស់ប្រទេសកម្ពុជា ពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ព្រមទាំងនាំប្រទេសជាតិយើង ឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ខាងមុខ។

ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយមានកំណត់នូវអាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ទៅតាមមុំ ឬ

វិស័យនីមួយៗ ដើម្បីទទួលបានជោគជ័យទៅតាមផែនការ។ លើសពីនេះទៀត រាជរដ្ឋាភិបាលក៏បានត្រៀមលក្ខណៈជាស្រេច ដើម្បីធ្វើកំណែទម្រង់នានា ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ត្រីរាជការស៊ីវិល និងវិស័យឯកជន ដើម្បីទទួលបានផលចំណេញជាអតិបរិមា ពីការធ្វើសមាហរណកម្មសេដ្ឋកិច្ចរបស់កម្ពុជា ទៅក្នុងសហគមសេដ្ឋកិច្ចអាស៊ាន ក្នុងតំបន់ផ្សេងទៀត និងក្នុងសកលលោក។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានសង្គតិភាពផងដែរ ជាមួយនឹងឯកសារគោលនយោបាយ តាមវិស័យដ៏ទៃទៀត របស់រាជរដ្ឋាភិបាល ដូចជា៖ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ និងក្របខ័ណ្ឌគោលនយោបាយសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចឌីជីថល ២០២០-២០៤០ ជាដើម។

ដូច្នេះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺជាឯកសារមេគ្គុទ្ទេសក៍ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់រយៈពេលវែងសំដៅជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផល នៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទរបស់ជាតិ ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ សំដៅពង្រឹង អភិបាលកិច្ចល្អ និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយដែលពិតជាស្របតាមគោលដៅយុទ្ធសាស្ត្រទី ៤ នៃ"**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" គឺ "បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបំរើប្រជាជនឱ្យបានកាន់តែប្រសើរឡើង ក៏ដូចជាលើកកម្ពស់បរិយាកាសធុរកិច្ច និងស្ថានភាពអំណោយផលសម្រាប់វិនិយោគ។

ជារួម នៅឆ្នាំ ២០២០ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចសម្រេចបានជោគជ័យ និងសមិទ្ធផលជាច្រើន ក្នុងការបំពេញភារកិច្ចដែលរាជរដ្ឋាភិបាលបានប្រគល់ជូន ដូចដែលបានលើកឡើងក្នុងរបាយការណ៍ដែលបានចែកជូនអង្គសន្និបាត។ យើងពិតជាមានមោទនភាព និងអំណរសាទរចំពោះលទ្ធផលការងារគ្រប់ផ្នែក គ្រប់វិស័យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ខិតខំសម្រេចបាន ហើយយើងប្តេជ្ញានឹងបន្តការងារឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យថ្មីៗថែមទៀត។

ជាការពិតណាស់ សមិទ្ធផលទាំងនេះ កើតឡើងចេញជាផ្លែផ្កាបាន ដោយសារការមានការដឹកនាំដ៏ត្រឹមត្រូវ និងផែនការ និងយុទ្ធសាស្ត្រច្បាស់លាស់ រួមនឹងការចូលរួមយ៉ាងសកម្មពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងដែលសុទ្ធតែជាតួអង្គសំខាន់ៗមិនអាចខ្វះបាន និងការគាំទ្រ និងកិច្ចសហការពីក្រសួង ស្ថាប័ន និងអង្គភាពនានា។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !***

ដើម្បីសម្រេចបានជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដូចបានលើកឡើងខាងលើនេះ ទាមទារឱ្យមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងសមត្ថភាព និងបទពិសោធន៍ និងគោរពច្បាប់ និងក្រមសីលធម៌មន្ត្រីរាជការ និងខិតខំបំពេញការងារទៅតាមការចាត់តាំង និងតួនាទីរបស់ខ្លួនគ្រប់ៗគ្នា។

ទន្ទឹមនេះ មន្ត្រីរាជការក៏ត្រូវមានលក្ខណៈសម្បត្តិថ្លៃថ្នូ ស័ក្តិសមជាអ្នកបម្រើដ៏ល្អ របស់ប្រជាជន ដោយផ្លាស់ប្តូរឥរិយាបទ ប្រែក្លាយខ្លួនទៅជាអ្នកផ្តល់សេវាដ៏មានប្រសិទ្ធភាព និងជាដៃគូរអភិវឌ្ឍន៍ដែលអាចទុកចិត្ត

បាន សំដៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើនប្រសិទ្ធផលសេវាកម្មសាធារណៈ។ ជាមួយគ្នានេះ មន្ត្រីរាជការក្រសួងទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់**សម្តេចតេជោនាយករដ្ឋមន្ត្រីគឺ៖ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និងបាវនា២ គឺ "**កែទម្រង់ខាងក្នុង និងបង្កើតមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**" ដែលយើងត្រូវចង ចាំកុំឲ្យភ្លេចខ្លួន។

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរថ្នាក់ដឹកនាំ និងជាមន្ត្រីរាជការក្នុងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមទាំងមន្ទីររាជធានី ខេត្តទាំងអស់ ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងឆ្នាំ ២០២០កន្លងទៅ ដោយទទួលនូវជោគជ័យគួរជាទីពេញចិត្ត។ ខ្ញុំក៏សូមអរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៅបណ្តាក្រសួង-ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យការងារទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការតាមដានការអនុវត្តច្បាប់ និងការទទួល និងដោះស្រាយបណ្តឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

ក្នុងឱកាសសន្និបាតរយៈពេលពេញមួយថ្ងៃនេះ ខ្ញុំសូមអំពាវនាវសូមឯកឧត្តម លោកជំទាវ លោក លោកស្រីដែលចូលរួមទាំងអស់ត្រូវបង្កើនស្មារតី យកចិត្តទុកដាក់ ប្រើប្រាស់ពេលវេលាដ៏មានប្រយោជន៍នេះដើម្បីផ្លាស់ប្តូរបទពិសោធន៍ លើកឡើងពីចំណុចល្អៗ និងចំណុចមិនទាន់បានកែលម្អ បញ្ហាប្រឈមទាំងឡាយ ព្រមទាំងលើកនូវដំណោះស្រាយដ៏សមស្របនិងប្រកបដោយប្រសិទ្ធភាព ដើម្បីដាក់ផែនការ និងសកម្មភាព សម្រាប់អនុវត្តបន្ត។

មុននឹងបញ្ចប់ ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី និងសមាជិក សមាជិកានៃអង្គសន្និបាត ទាំងអស់ដែលបានអញ្ជើញចូលរួមក្នុងពិធី នាពេលនេះសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លាតឃ្លៀងឡើយ។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យអង្គសន្និបាតសម្រេចបានជោគជ័យ និង**សូមប្រកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០** និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១ របស់**ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាប់ពីពេលនេះតទៅ**។

***សូមអរគុណ !***

# ឧបសម្ព័ន្ធ ៥. សុន្ទរកថាបិទសន្និបាត

របស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០ និងទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២១
របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
ថ្ងៃអង្គារ៍ ៥រោច ខែមាឃ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹង ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១
ភោជនីយដ្ឋានទន្លេបាសាក់២ (លេខ ៥៣៤ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ)

**ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គសន្និបាត ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្ដីរីករាយក្រៃលែង ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងពិធីបិទសន្និបាតប្រចាំឆ្នាំ២០២០-២០២១ របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានបូកសរុបលទ្ធផលការងារក្រសួងបានសម្រេច ក្នុងឆ្នាំ២០២០កន្លងមក និងដាក់ចេញនូវទិសដៅសម្រាប់ អនុវត្តបន្តក្នុងឆ្នាំ២០២១។ សន្និបាតដែលមានរយៈពេលពេញមួយថ្ងៃនេះសម្រេចបានលទ្ធផលគួរជាទីមោទនៈ។

ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ រួមមានថ្នាក់ដឹកនាំ មន្ត្រីរាជការ ទាំងនៅថ្នាក់កណ្ដាល ទាំងថ្នាក់រាជធានី ខេត្តដែលបានចូលរួមក្នុងសន្និបាតនេះ។

ក្រោយពីដំណើរការពេញមួយថ្ងៃមក សន្និបាតយើងបានដំណើរការយ៉ាងរលូន និងទទួលបានការចូលរួមយ៉ាងសកម្ម រួមមានការធ្វើបទបង្ហាញតាមផែន និងវិស័យចំបងៗ ក្នុងក្រសួង និងលើកឡើងនូវបទពិសោធន៍ល្អៗ ការប្រឈមនានា និងដំណោះស្រាយ ប្រកបដោយភាពជាក់ស្ដែង និងលទ្ធភាពដែលមាន និងទទួលបាននូវលទ្ធផលជាផ្លែផ្កាគួរឱ្យកោតសរសើរ។

នេះបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ ពីស្មារតីទទួលខុសត្រូវ និងការខិតខំបំពេញការងាររបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជា ថ្នាក់ ដឹកនាំ និងមន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងរាជធានី-ខេត្ត ដែលបានខិតខំ ប្រឹងប្រែងបំពេញការងារ រួមគ្នាយ៉ាងសស្រាក់សស្រាំ រៀបចំ និងចូលរួមធ្វើបទបង្ហាញ ពិភាក្សា ផ្លាស់ប្ដូរយោបល់ល្អៗ ដោយប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ ការងារជាក់ស្ដែងក្នុងគោលបំណងស្វែងរកឲ្យឃើញបញ្ហាប្រឈម ហើយបានដាក់ចេញជាផែនការសកម្មភាពសម្រាប់អនាគត។

តាមរយៈលទ្ធផលការងារដែលបានសម្រេច ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រី រាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានប្រឹងប្រែងបំពេញភារកិច្ចស្នូលរបស់ខ្លួន ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងដោយមានកិច្ចសហការ ការគាំទ្រទទួលពីស្ថាប័នពាក់ព័ន្ធ ដោយទទួលបានលទ្ធផលគួរជាទីពេញចិត្ត។ នេះជា

មោទនភាព និងកិត្តិយសដ៏ធំធេង ដោយក្រសួងយើងទទួលបានជោគជ័យលើការងារជាច្រើនក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួន។

ខ្ញុំក៏សូមថ្លែងនូវអំណរគុណ និងការកោតសរសើរដោយស្មោះ ចំពោះគណៈកម្មការរៀបចំសន្និបាត ដែលដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ **ឆេង សារឿន** រួមជាមួយ លោកជំទាវ **សុភ័ក្ត ថាវី** ឯកឧត្តម **ហួត ហាក់** និងឯកឧត្តម **ចាប សុថារិទ្ធ**ដែលបានបំពេញការងារយ៉ាងសកម្មដោយបានរៀបចំសន្និបាតឆ្នាំនេះបានល្អប្រសើរ ប្រកបដោយការទទួលខុសត្រូវខ្ពស់ និងទទួលបានជោគជ័យ។

ខ្ញុំសូមអបអរសាទរ និងគាំទ្រទាំងស្រុងនូវរបាយកាណ៍បូកសរុបការងារឆ្នាំ២០២០ និងទិសដៅ សម្រាប់ឆ្នាំ២០២១ ដែលអង្គសន្និបាតបានពិភាក្សា និងសម្រេច។

*អង្គពិធីទាំងមូលជាទីមេត្រី*

រាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធសាស្ត្រចតុកោណ ដែលមានបួនដំណាក់កាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដើម្បីអភិវឌ្ឍប្រទេសជាតិ លើគ្រប់វិស័យ ដោយកំណត់អាទិភាព សូចនាករ និងក្របខ័ណ្ឌពេលវេលាច្បាស់លាស់ សម្រាប់អនុវត្ត និងយន្តការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផ្អែកលើកលទ្ធផលការងារ ព្រមទាំងមានកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ដើម្បីទទួលបានជោគជ័យ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩- ២០២៣ ជាការឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឱ្យបាននូវចក្ខុវិស័យកម្មវិធីនយោបាយអភិវឌ្ឍជាតិ ប្រកបដោយចីរភាព ឆ្លើយតបទៅនឹងបរិការណ៍អភិវឌ្ឍសេដ្ឋកិច្ច-សង្គម បញ្ហាប្រឈម និងកាលានុវត្តភាពទាំងឡាយដែលជាបញ្ហារួមរបស់សង្គមជាតិយើង ដើម្បីឈានទៅសម្រេចបាននូវគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា។

កម្ពុជាសម្រេចបាននូវសមិទ្ធផលជាច្រើន លើគ្រប់វិស័យជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់អត្រា ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលប្រហែល២០ឆ្នាំកន្លងមកដែលធ្វើឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយមូលដ្ឋាន នៃកំណើនសេដ្ឋកិច្ចជាតិក៏កាន់ តែមានពិពិធកម្មច្រើនឡើង ភាពក្រីក្រត្រូវបានកាត់បន្ថយមកនៅត្រឹមក្រោម១០% និងគម្លាតនៃចំណូលក្នុងចំណោមប្រជាជនស្ថិត ក្នុងកម្រិតទាប តាមរយៈការបែងចែកផល នៃកំណើនសេដ្ឋកិច្ចដល់ប្រជាជនគ្រប់ស្រទាប់ ជាពិសេសការអនុវត្តគោលនយោបាយដំឡើងបៀវត្សមន្ត្រីរាជការ និងប្រាក់ឈ្នួលអប្បបរមាជាមួយនឹងការគិតគូរពីសុខុមាលភាពរបស់កម្មករ ការតភ្ជាប់បណ្តាញអគ្គិសនីនិង បណ្តាញទឹកស្អាតក្នុងតម្លៃទាប ការពង្រីកវិសាលភាពបេឡាជាតិ របបសន្តិសុខសង្គម និងមូលនិធិសមធម៌។

ឆ្នាំ២០២០កន្លងទៅ និងឆ្នាំ២០២១នេះ កម្ពុជាក៏ដូចជាប្រទេសនានាក្នុងតំបន់ និងពិភពលោកបាន និងកំពុងជួបប្រទះនូវគ្រោះមហន្តរាយនៃការរាលដាលនៃជំងឺកូវីដ-១៨ ដែលកំពុងរាតត្បាត និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរជាសកល នាំឱ្យមានការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ និងបង្កជាការរាំងស្ទះទៅដល់តម្រូវការ ព្រមទាំងលំហូរ នៃការធ្វើដំណើរ សេវាកម្ម ពាណិជ្ជកម្ម និងការវិនិយោគ ជាហេតុរំខានទៅលើគ្រប់វិស័យនៃសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

ដោយឡែក វិបត្តិកូវីដ១៩ក៏បានជះឥទ្ធិពលអវិជ្ជមានជាច្រើនដល់ប្រតិបត្តិការការងាររបស់ក្រសួងយើងផងដែរជាពិសេសបេសកកម្មទាំងក្នុង និងក្រៅប្រទេស ប្រេងឥន្ធនៈ លទ្ធកម្ម និងការបណ្តុះបណ្តាល ដោយសារ

រាជរដ្ឋាភិបាលបានកាត់បន្ថយការចំណាយលើមុខសញ្ញាជាច្រើន ចាប់ពីដើមឆ្នាំ ២០២០មក ក្នុងគោលបំណង ត្រៀមទប់ទល់ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩។

ជាគោលដៅយុទ្ធសាស្ត្រសម្រាប់អាណត្តិថ្មីនេះ រាជរដ្ឋាភិបាលកម្ពុជាផ្តោតអាទិភាពទៅលើការកែទម្រង់ អភិបាលកិច្ចសំដៅពង្រឹងស្ថាប័នសាធារណៈ និងកសាងរដ្ឋបាលស្អាតស្អំ ការវិនិយោគលើមូលធនមនុស្ស ការបង្កើតបរិយាកាសអំណោយផលសម្រាប់ធុរកិច្ច និងការវិនិយោគ ព្រមទាំងការពង្រឹងភាពជាដៃគូក្នុង ការអភិវឌ្ឍជាមួយគ្រប់ដៃគូដែលមានការពាក់ព័ន្ធ ពិសេសការពង្រឹងសមត្ថភាពកម្ពុជា សម្រាប់សមាហរណកម្ម ទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក ដែលទាំងអស់នេះ នឹងធ្វើឱ្យប្រជាជនគ្រប់ៗរូបមានកម្រិតជីវភាពកាន់តែ ប្រសើរឡើងឥតឈប់ឈរ ហើយរស់នៅយ៉ាងសុខដុមរមនាក្នុងសង្គមកម្ពុជាមួយ ដែលគោរពគុណធម៌ តម្លៃ មនុស្ស សេរីភាពប្រជាធិបតេយ្យ នីតិរដ្ឋ និងយុត្តិធម៌សង្គម។

ដូចប្រសាសន៍សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលលោកបានលើកឡើងថា រាជរដ្ឋាភិបាលនឹងបន្តអនុវត្ត នូវវិធានការមុតស្រួច និងជាក់ស្តែងនានា សំដៅពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជារួមមានៈ កាត់បន្ថយថ្លៃ ឡូជីស្ទីក ជំរុញការតភ្ជាប់ផ្នែកដឹកជញ្ជូន អភិវឌ្ឍថាមពល ពង្រឹងបច្ចេកវិទ្យា និងឌីជីថល កាត់បន្ថយថ្លៃអគ្គិសនី និងធានាស្ថិរភាព នៃការផ្គត់ផ្គង់ បន្តធ្វើសាមញ្ញកម្ម និងស្វ័យប្រវត្តិកម្មនីតិវិធីគយ កាត់បន្ថយចំណាយនៃការធ្វើ ធុរកិច្ច ទាំងផ្លូវការ និងក្រៅផ្លូវការ ជំរុញការកែទម្រង់ និងទំនើបកម្មប្រព័ន្ធពន្ធ ដោយឈរលើគោលការណ៍ យុត្តិធម៌ សមធម៌សេវាល្អ អភិបាលកិច្ចល្អ និងអនុលោមភាព និងជំរុញលើកកម្ពស់ការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលក្នុងអាណត្តិថ្មីនេះ បានរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ច ឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ តាមរយៈ ក្របខ័ណ្ឌគោលនយោបាយសម្រាប់អភិវឌ្ឍ សេដ្ឋកិច្ចឌីជីថល ២០២០-២០៤០ ដែលគ្រោងរៀបចំបង្កើតមូលដ្ឋាន និងថ្នាលសម្រាប់ការពង្រីកផ្នែក វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដោយ ផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍវិស័យឌីជីថល ទាំងផ្នែករឹង និងទន់ ការរៀបចំអភិវឌ្ឍធនធានមនុស្ស និងជំនាញស្របតាមបរិការណ៍ថ្មីព្រមទាំងការបង្កើតក្របខ័ណ្ឌគតិយុត្តិ និង បទប្បញ្ញត្តិគាំទ្រដែលមានការពាក់ព័ន្ធ។

ដោយឡែក ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនៅក្នុងដំណាក់កាលនៃ ការវិវត្តន៍វិស័យឌីជីផល និងដើម្បីបំរើសេវាកម្មឱ្យកាន់តែល្អប្រសើរជូនប្រជាពលរដ្ឋ ក្រសួងបានតម្លើងកម្មវិធី ទទួលពាក្យបណ្តឹងអនឡាញ និងបណ្ណាល័យអេឡិចត្រូនិក (អ៊ីបណ្ណាល័យ) ដែលប្រជាពលរដ្ឋ អាចនឹងដាក់ ពាក្យបណ្តឹង និងមើលឯកសារច្បាប់នានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គសន្និបាតទាំងមូលជាទីមេត្រី !*

ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ និងសុវត្ថិភាពសាធារណៈ និងជម្រុញអភិបាលកិច្ចល្អ ប្រទេសជាច្រើន ក្នុងពិភពលោក កំពុងប្រើប្រាស់យន្តការគ្រប់គ្រងវិស័យអធិការកិច្ច ឬត្រួតពិនិត្យដោយមានក្រសួង ឬស្ថាប័ន ទទួលបន្ទុកអធិការកិច្ច និងច្បាប់អធិការកិច្ចដែលមានខ្លឹមសារ និងវិសាលភាពខុសៗគ្នា ទៅតាមស្ថានភាពជាក់ ស្តែងនៃប្រទេសនិមួយៗ។

ដោយឡែក នៅព្រះរាជាណាចក្រកម្ពុជា យើងមានច្បាប់ស្តីពីការបង្កើតក្រសួងតាមរយៈព្រះរាជក្រម លេខ នស/រកម/០៦៩៥/០៥ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងអនុក្រឹតលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ១២ ខែមករា

ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបទដ្ឋានគតិយុត្តិមួយចំនួនទៀត។

ច្បាប់ស្តីពីអធិការកិច្ច និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតកំពុងស្ថិតនៅជាសេចក្តីព្រាង និងមិនទាន់ត្រូវបានអនុម័តនៅឡើយ។ ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់របស់ក្រសួង បានខិតខំបំពេញភារកិច្ចយ៉ាងមុះមុតដោយប្រើប្រាស់ធនធានបញ្ញាញាណក្នុងក្រសួង ដោយមិនបានពឹងផ្អែកជំនាញការបរទេសឡើយ។ ដោយឆ្លងកាត់ការប្រជុំ ពិភាក្សា និងការពារសេចក្តីព្រាងច្បាប់នោះ រាប់សិបដង មកទល់ពេលនេះ ច្បាប់នោះកំពុងស្ថិតក្នុងកិច្ចប្រជុំចង្អៀត ដើម្បីសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន មុននឹងបន្តនីតិវិធីទៅតាមលំដាប់លំដោយ ជាបន្តទៀត។ យើងពិតជាមានការលំបាកក្នុងការតាក់តែងច្បាប់ស្តីពីអធិការកិច្ច ដោយសារកង្វះធនធាន បច្ចេកទេស និងភាពរសើប និងជំទាស់ជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួន ដែលទាមទាឱ្យយើងធ្វើការពន្យល់ ការពារ និងសម្របសម្រួល។ ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណ ដល់ក្រុមការងារតាក់តែងច្បាប់យើងដែលដឹកនាំដោយលោកជំទាវ **សុខ ទិត្យាយ** និង ឯកឧត្តម **ហួត ហាក់** រួមជាមួយក្រុមការងារ និងតំណាងក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី ដែលបានជួយជ្រុំជ្រែង តាក់តែង តាំងពីចំណុចសូន្យ ផ្តល់យោបល់ សម្រួលខ្លឹមសារ និងការពារច្បាប់អធិការកិច្ចរហូតមក។

ជារួម ក្រសួងយើងបានបោះជំហាន វិវត្តបណ្តើរៗ និងប្រែប្រួលមុខមាត់កាន់តែប្រសើរ ដូចដែលយើងបានឃើញស្រាប់។ យើងធ្លាប់មានទីតាំងតូចចង្អៀត និងអគារចាស់ទ្រុឌទ្រោម ដែលឥឡូវឈានមកមានទីតាំងល្អ ចំកណ្តាលបេះដូងនៃរាជធានីភ្នំពេញ មានអគាររដល់ទៅ៤ ដែលក្នុងនោះ អគារ ឌី (D) មានកំពស់៧ជាន់ ទំហំ ១៨ម៉ែត្រ គុណនឹង ៤៨ម៉ែត ទើបតែសាងសង់ចប់ និងប្រគល់ជូនកាលពីចុងឆ្នាំ ២០១៩។ ដោយឡែកថវិកាក្រសួងក៏ត្រូវបានកើនជាលំដាប់ ដោយសារយើងមានសកម្មភាព និងសមិទ្ធផលកាន់តែច្រើន និងមានវិទ្យាស្ថានជាតិអធិការកិច្ច ដែលកំពុងឈានជាជំហានៗ ពីបណ្តុះបណ្តាលមន្ត្រីរាជការក្រសួងយើង និងឈានទៅបណ្តុះបណ្តាលមន្ត្រីរាជការដែលពាក់ព័ន្ធនឹងការងារអធិការកិច្ចមកពីក្រសួង ស្ថាប័ន ក្រៅទៀត។

ទោះជាយើងទទួលបានជោគជ័យ ជាច្រើនក្នុងការងារក្តី ក៏ក្រសួងនៅមានការប្រឈមជាច្រើន ដូចជា៖ ទី១) នៅតាមស្ថាប័នរដ្ឋមួយចំនួនមិនទាន់ឱ្យតម្លៃការងារអធិការកិច្ច និងមិនចង់សហការ ដោយសារគេយល់ថាក្រុមបេសកកម្មយើង ទៅរកចាប់កំហុសគេ ទី២) ក្រសួង ស្ថាប័នរដ្ឋមួយចំនួនមានភារកិច្ចស្រដៀងគ្នា ឬជាន់គ្នាដែលធ្វើឱ្យមានក្រុមបេសកកម្មច្រើនត្រួតគ្នា ដែលធ្វើឱ្យគេពិបាកទទួល និងខាតពេលវេលា ទី៣) ក្រសួងនៅខ្វះខាតធនធាន និងមធ្យោបាយធ្វើដំណើរ ដើម្បីបំពេញបេសកកម្ម ទី៤) សមាជិកក្រុមការងារចុះធ្វើបេសកកម្មខ្លះមិនបានអនុវត្ត តាមក្រមសីលធម៌វិជ្ជាជីវៈពេញលេញនៅឡើយ ទី៥) ការងារអធិការកិច្ច ជាពិសេសការដោះស្រាយពាក្យបណ្តឹង គឺជាការងារដែលលំបាក ស្មុគស្មាញមានភាពរសើប និងភាពចំរូងចម្រាស់ច្រើន ដែលទាមទារការតស៊ូ សមត្ថភាព និងជំនាញច្បាស់លាស់ ពីបច្ចេកទេសអធិការកិច្ច និងសមត្ថភាពផ្នែកច្បាប់ ព្រមទាំងក្រមសីលធម៌ស្អាតស្អំ និងការប្រឈមផ្សេងទៀតដូចដែលបានចែងក្នុងរបាយការណ៍សន្និបាត។

ទោះជាមានការប្រឈមខ្លះយ៉ាងណាក្តី ក្រសួងបានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ដោយទទួលខុសត្រូវក្នុងនាមរាជរដ្ឋាភិបាល ដែលបានប្រគល់បេសកកម្មឲ្យដឹកនាំ និងគ្រប់គ្រងរាល់កិច្ចការសម្របសម្រួល និងធ្វើទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងធ្វើការងារអធិការកិច្ច លើគ្រប់វិស័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការងារក្នុងវិស័យអធិការកិច្ច ជាចំបងរួមមាន៖ ការត្រួតពិនិត្យលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅតាមបណ្តាក្រសួង ស្ថាប័ននានា ការងារតាមដានការអនុវត្តច្បាប់ លិខិតបទដ្ឋាន

គតិយុត្ត និងអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាល សំដៅជួយកាត់បន្ថយបាតុភាពអសកម្មនានា និងការងារទទួលពាក្យបណ្តឹង ការងារអង្កេតស្រាវជ្រាវ ដើម្បីទប់ស្កាត់ ការរំលោភដោយអំណាច និងរួមចំណែកប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ក្រសួងបានចុះធ្វើការងារអធិការកិច្ច និងអង្កេតស្រាវជ្រាវ នៅតាមក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ និងបានធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច។

ក្រសួងសម្រេចបានលទ្ធផលជាច្រើន ក្នុងការងារអធិការកិច្ច ដូចជា៖ ការងារទទួលពាក្យបណ្តឹង (បណ្តឹងតវ៉ា និងបណ្តឹងបរិហារ) ការងារស៊ើបអង្កេតករណីបណ្តឹងពាក់ព័ន្ធទំនាស់ដីធ្លី ការងារសម្របសម្រួលបញ្ចប់ទំនាស់ពុំរ៉ៃ បានជាច្រើនករណី ការងារតាមដានការអនុវត្តច្បាប់ ការកែលម្អរចំណុចខ្វះខាតរបស់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ លើកិច្ចការរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ ជម្រុញប្រសិទ្ធិភាព ផលិតភាព និងគុណភាពសេវាសាធារណៈ ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។ លើសពីនេះក្រសួងក៏បានអប់រំ ណែនាំ បង្ការ ទប់ស្កាត់ និងកែលម្អរកំហុសឆ្គងក្នុងការអនុវត្តការងាររបស់ក្រសួង-ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមួយចំនួន ដើម្បីកែលម្អរ និងលើកកម្ពស់អភិបាលកិច្ចល្អដែលជាស្នូល នៃយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។

ជារួម ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានផ្សព្វផ្សាយការយល់ដឹងនិងការអប់រំដល់ប្រជាពលរដ្ឋ ឱ្យយល់ដឹងពីច្បាប់គោលមួយចំនួន ជួយពង្រឹងប្រសិទ្ធភាពការងាររបស់ស្ថាប័ន-អង្គភាពរដ្ឋ ធានាសុវត្ថិភាពសាធារណៈ និងសិទ្ធជូនប្រជាពលរដ្ឋ នាំមកនូវតម្លាភាព និងកាត់បន្ថយបាននូវបាតុភាពអសកម្មនានា ដូចជាការអនុវត្តមិនត្រឹមត្រូវ នៃច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងកិច្ចសន្យារវាងក្រុមហ៊ុនឯកជន ជាមួយរដ្ឋ ជួយកាត់បន្ថយ និងលុបបំបាត់ការកឹបកេងថវិកា និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋខុសទិសដៅ និងចូលរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី !**

ដោយប្រទេសកម្ពុជា ចាប់ពីពាក់កណ្តាលឆ្នាំ២០២០ និងឆ្នាំ២០២១នេះត្រូវរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយជម្ងឺកូវីដ-១៩ ក្រសួងយើងក៏ទទួលផលប៉ះពាល់ដែរ ដោយបញ្ហាថវិកា។ តែទោះជាយ៉ាងណាក្តី ដោយផ្អែកតាមការពិភាក្សាក្នុងសន្និបាត និងដើម្បីឲ្យសម្រេចបាននូវគោលដៅដែលក្រសួងចង់បាន ខ្ញុំសូមស្នើឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ត្រូវផ្តោតលើអនុសាសន៍ដូចខាងក្រោមនេះ៖

១. យើងត្រូវមានការសន្សំសំចៃ ក្នុងការចំណាយ ដោយថវិកាក្រសួងត្រូវបានថយចុះច្រើន ដោយយោងលិខិតលេខ០០៣សហវ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយ សម្រាប់អនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។ រដ្ឋបានសម្រេចកាត់ខ្ទង់ចំណាយ ដូចខាងក្រោម ចំនួន ៥០% រួមមាន ប្រេងឥន្ទនៈ សម្ភារការិល័យ ឯកសណ្ឋាន សម្ភារ និងបរិក្ខារបច្ចេកទេសសង្ហារឹម សម្ភារព័ត៌មានវិទ្យា សោហ៊ុយបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស សោហ៊ុយទទួលភ្ញៀវជាតិ សោហ៊ុយទទួលភ្ញៀវអន្តរជាតិ ការប្រជុំ ការធ្វើសិក្ខាសាលា ការទិញវត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ បេសកកម្មក្នុង និងក្រៅប្រទេស។ ដោយឡែកចំណែកការទិញរថយន្ត គឺកាត់១០០ភាគរយ។

២. យើងត្រូវអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ចដូចខាងក្រោមៈ

- ហាមចុះធ្វើអធិការកិច្ចជាប្រចាំដូចមុនលើកលែងតែមានពាក្យបណ្តឹង។
- ចុះធ្វើតែអង្គភាពណាដែលមានហានិភ័យខ្ពស់ ដូចជាអង្គភាពរកចំណូល និងចំណាយថវិកាច្រើនដែលអាចទាក់ទងនឹងអំពើពុករលួយ ឬកិបកេងប្រវញ្ច។
- ផ្នែកដ៏ទៃទៀត ជាពិសេសការផ្សព្វផ្សាយច្បាប់ ការចុះដោះស្រាយពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់ត្រូវធ្វើបន្តជាធម្មតា។

៣. ពង្រឹងវិន័យការងារ និងក្រមសីលធម៌ ដោយត្រូវវត្តមានឱ្យបានជាប់ និងបន្តបំពេញការងារជាធម្មតា ដោយត្រូវប្រើប្រាស់ពេលវេលាឱ្យមានប្រយោជន៍ ដូចជាតាមដានព័ត៌មាន និងស្រាវជ្រាវឯកសារ ដើម្បីពង្រឹងសមត្ថភាព។

៤. ដោយសារការផ្សព្វផ្សាយច្បាប់ ជាតម្រូវការចាំបាច់ ក្រុមការងារក្រសួងត្រូវបន្តការអប់រំ និងផ្សព្វផ្សាយច្បាប់ឲ្យបានទូលំទូលាយ គ្រប់២៥ រាជធានី-ខេត្ត ជាពិសេសទៅតាមទីប្រជុំជន និងជនបទដាច់ស្រយ៉ាល និងជម្រុញការងារសិក្សាស្ទាបស្ទង់មតិ (Survey) ដោយបណ្តុះបណ្តាលពីវិធីសាស្ត្រ នៃការសិក្សាស្ទាបស្ទង់ និងការវិភាគទិន្នន័យដល់មន្ត្រីដែលពាក់ព័ន្ធដើម្បីធ្វើរបាយការណ៍នៃលទ្ធផលដែលរកឃើញពីការស្ទាបស្ទង់ទាំងនោះ។

៥. ត្រូវបន្តជម្រុញឆ្លងសេចក្តីព្រាងច្បាប់អធិការកិច្ច ដែលក្រសួងបានតាក់តែងរួច ដោយបន្តសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យច្បាប់នេះត្រូវបានអនុម័ត។ ត្រូវតាក់តែងសេចក្តីប្រកាសរបស់ក្រសួងដើម្បីតម្រង់ទិសការងារដោយមិនបាច់រង់ចាំច្បាប់អធិការកិច្ចដូចជាៈ ស្តង់ដារអធិការកិច្ច នីតិវិធីអធិការកិច្ច ក្រមសីលធម៌មន្ត្រីអធិការកិច្ច នីតិវិធីនៃការតាមដានការអនុវត្តច្បាប់ នីតិវិធីនៃការដោះស្រាយពាក្យបណ្តឹង នីតិវិធីនៃការផ្សព្វផ្សាយច្បាប់ ។ល។

៦. ត្រូវអនុវត្តបន្តនូវកម្មវិធី ទទួលពាក្យបណ្តឹងអនឡាញ និងបណ្ណាល័យ អេឡិចត្រូនិក (e-Library) ដែលតាមរយៈកម្មវិធីទាំងនោះ ប្រជាពលរដ្ឋ អាចដាក់ពាក្យបណ្តឹង និងអាចមើលឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានាតាមកុំព្យូទ័រ និងទូរស័ព្ទដៃបានយ៉ាងងាយស្រួល។ ការអនុវត្តកម្មវិធីគឺជាការសម្រួលការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

៧. ត្រូវពង្រឹងប្រសិទ្ធភាព ក្នុងបេសកកម្មចុះធ្វើអធិការកិច្ច ការអង្កេត ស្រាវជ្រាវពាក្យបណ្តឹង និងការតាមដានការអនុវត្តច្បាប់ តាមរយៈការរកព័ត៌មានឲ្យមានតុល្យភាពច្បាស់លាស់ មានភស្តុតាង និងឯកសារសំអាងគ្រប់គ្រាន់ទាំងអង្គហេតុ និងអង្គច្បាប់។ រាល់ពាក្យបណ្តឹងដែលបញ្ជូនទៅសមត្ថកិច្ចពាក់ព័ន្ធពិនិត្យដោះស្រាយ ត្រូវតាមដាន ស៊ើបសួរព័ត៌មានអំពីវឌ្ឍភាព នៃការដោះស្រាយឲ្យបានច្បាស់លាស់ និងទាន់ពេលវេលា រួចជូនព័ត៌មានទៅដើមបណ្តឹងវិញ។

៨. មន្ត្រីរាជការក្រសួង ជាពិសេសមន្ត្រីអធិការកិច្ចត្រូវបន្តពង្រឹងសមត្ថភាពដើម្បីផ្តល់សេវាប្រកបដោយប្រសិទ្ធភាព ដើម្បីជំរុញតម្លាភាព និងគណនេយ្យភាព និងរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ អភិវឌ្ឍសមត្ថភាពឱ្យបានទូលំទូលាយ ដើម្បីធានានូវប្រសិទ្ធភាព នៃសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ។

៩. មន្ត្រីរាជការក្នុងក្រសួង និងមន្ទីរទាំងអស់ត្រូវស្វែងយល់អំពីច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការងារស្នូលរបស់ក្រសួង ដើម្បីបង្កើនសមត្ថភាព និងមានលទ្ធភាព បកស្រាយ ពន្យល់ ពិភាក្សាវែកញែក

ក្នុងការបំពេញភារកិច្ច ជាពិសេសក្នុងការងារអធិការកិច្ច ដោះស្រាយពាក្យបណ្ដឹង តាមដានការអនុវត្តច្បាប់និងផ្សព្វផ្សាយច្បាប់។

១០. វិទ្យាស្ថានជាតិអធិការកិច្ច ត្រូវពង្រឹងគុណភាពបណ្ដុះបណ្ដាល ជាពិសេសពង្រឹងសមត្ថភាពគ្រូ។ ព្រោះយើងជាស្ថាប័នស្នូលលើវិស័យអធិការកិច្ច យើងត្រូវតែច្បាស់ជាងគេ។ យើងត្រូវបង្កើតជាមេរៀនដែលជារបស់យើងមិនមែនចម្លងទាំងស្រុងពីប្រទេសណាមួយនោះឡើយ។ វិទ្យាស្ថានជាតិអធិការកិច្ចត្រូវចំខឹមសារកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បឋម ថ្នាក់មធ្យម និងថ្នាក់ឧត្ដម លើជំនាញអធិការកិច្ច និងជំនាញពាក់ព័ន្ធ។ វិទ្យាស្ថានក៏ត្រូវបណ្ដុះបណ្ដាលមុខជំនាញផ្សេងបន្ថែម ក្រៅពីអធិការកិច្ច ដូចជា ជំនាញអប់រំផ្សព្វផ្សាយច្បាប់ ជំនាញផ្នែកការសិក្សាស្រាវជ្រាវ ជំនាញវាយតម្លៃ ជំនាញផ្នែកស្មាបស្មង់មតិ និងជំនាញផ្សេងៗទៀត ដែលជាតម្រូវការចាំបាច់របស់ក្រសួង។

១១. ត្រូវបន្តធ្វើការកែទម្រង់ផ្ទៃក្នុងក្រសួងជាបណ្ដើរៗ ដើម្បីអនុវត្តថវិកាតាមកម្មវិធី និងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវធ្វើឲ្យបានហ្មត់ចត់ ច្បាស់លាស់ ជាពិសេសការប្រើប្រាស់កញ្ចប់ថវិកា ឱ្យមានប្រសិទ្ធភាព គណនេយ្យភាព និងសមស្របតាមបទដ្ឋានគតិយុត្ត។

១២. ក្នុងពេលបំពេញបេសកកម្មចុះធ្វើអធិការកិច្ច មន្ត្រី ឬភ្នាក់ងារអធិការកិច្ច ត្រូវគោរពឲ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់ នូវក្រមសីលធម៌មន្ត្រីរាជការអធិការកិច្ច ដែលបានដាក់ចេញរួចហើយ។ ត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ ដោយយកច្បាប់ជាធំ។ ត្រូវមានឯកសណ្ឋាន ដូចដែលក្រសួងបានណែនាំរួចហើយ និងត្រូវអនុវត្តឱ្យបានល្អ តាមអភិក្រមទាំងប្រាំ របស់**សម្ដេចតេជោនាយករដ្ឋមន្ត្រី** គឺ៖ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងបាវនា២ គឺ "**កែទម្រង់ខាងក្នុង និងបង្កើតមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ**" ដែលត្រូវចងចាំជានិច្ច។

១៣. ទោះជាមានស្ថាប័នច្រើន មានភារកិច្ចស្រដៀងគ្នា ឬត្រួតគ្នាក៏ដោយ យើងត្រូវតែពន្យល់ពីសារៈសំខាន់នៃការងារអធិការកិច្ច ដែលជាស្ថាប័នត្រួតពិនិត្យ ជម្រុញអភិបាលកិច្ចនិងប្រសិទ្ធភាពការងារ ដល់ស្ថាប័នផ្សេងៗទៀតឱ្យយល់ និងត្រូវកែទស្សនៈដែលខុសឆ្គងពី "**ការងារត្រួតគ្នា**" ទៅជា "**ការងារបំពេញបន្ថែមគ្នាទៅវិញទៅមក**" ដើម្បីរាជរដ្ឋាភិបាលតែមួយ។

១៤. មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ចនៅរាជធានី-ខេត្ត ពង្រឹងកិច្ចសហការ និងទំនាក់ទំនងឱ្យបានល្អជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីរួមគ្នាបំពេញការងារ ជាពិសេសការដោះស្រាយពាក្យបណ្ដឹង។

ខ្ញុំពិតជាមានមោទនភាព និងសូមកោតសរសើរ វាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ ក៏ដូចជាមន្ត្រីរាជការក្រុមការងារនៃគណៈកម្មការរៀបចំសន្និបាត ដែលបានខិតខំបំពេញការងារយ៉ាងសកម្ម និងដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើឱ្យសន្និបាតក្រសួងឆ្នាំនេះបានទទួលជោគជ័យគួរជាទីពេញចិត្ត។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងបណ្ដាក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំរួមចំណែក ក្នុងកិច្ចសហការជាមួយក្រសួង ដើម្បីបំពេញការងារជូនរាជរដ្ឋាភិបាល និងបំរើប្រជាជន លើវិស័យទំនាក់ទំនង សម្របសម្រួលជាមួយរដ្ឋសភា ព្រឹទ្ធសភា ការងារផ្សព្វផ្សាយច្បាប់ ការងារអធិការកិច្ច ការទទួល និងដោះស្រាយបណ្ដឹងនានា ដើម្បីរួមចំណែកពង្រឹងអភិបាលកិច្ចល្អ ដែលជាឧត្តមប្រយោជន៍របស់សង្គមជាតិទាំងមូល។

មុននឹងបញ្ចប់ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអបអរសាទរចំពោះលទ្ធផលដែលអង្គសន្និបាតសម្រេចបានក្នុងរយៈពេលពេញមួយថ្ងៃនេះ និងជឿជាក់យ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នឹងបន្តអនុវត្តភារកិច្ចដោយយកចិត្តទុកដាក់ខ្ពស់ ដើម្បីបង្កើតសមិទ្ធផលថ្មីៗថែមទៀតជូនរាជរដ្ឋាភិបាលដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍របស់ជាតិ។

ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបិទ**សន្និបាតបូកសរុបការងារ ក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចឆ្នាំ២០២០ និងទិសដៅការងារឆ្នាំ២០២១ចាប់ពីពេលនេះតទៅ។**